សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# យុត្តិធម៌សម្រាប់អនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **កញ្ញា. កប ចន្ធូ**
**លោក. ខួន សេដ្ឋាវីរៈ**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឃឹម ម៉ាណែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំ **កប ចន្ធូ** និង **ខួន សេដ្ឋាវីរៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ជំនាន់ទី១៥ នៃមហាវិទ្យាល័យរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០២២។

**សូមគោរពលំឱនកាយ សំដែងនូវការគោរពកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

**លោកឪពុក លឹម វិញ** **លោកឪពុក តែម វេន**

**អ្នកម្ដាយ លឹម ទូច** **អ្នកម្ដាយ ហឹង សារ៉ែម**

ដែលជាអ្នកមានគុណបំណាច់ដ៏ធំធេង និងឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបាន ដែលលោកបានផ្ដល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មាន ទំនុកបម្រុង គាំពារ និងលើកទឹកចិត្តកូនៗគ្រប់បែបយ៉ាង ដោយមិនដែលត្អូញត្អែរ រអ៊ូរទាំឡើយ។ ជាការតបស្នងសងគុណលោកទាំងពីរ ក្នុងនាមយើងខ្ញុំជាកូនៗសូមប្ដេជ្ញាចិត្តក្នុងការសម្រេចនូវកិច្ចការសារណាមួយនេះឱ្យបានល្អប្រសើរ បំពេញតួនាទីជាកូនកតញ្ញូចំពោះឪពុកម្ដាយ និងធ្វើជាបុគ្គលដែលចូលរួមចំណែកជួយប្រទេសជាតិឱ្យមានការអភិវឌ្ឍឈានទៅមុខជាលំដាប់។

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោកស្រីសាស្ត្រាចារ្យ **ឃឹម ម៉ាណែត** ដែលបានជួយណែនាំបង្ហាត់បង្ហាញ ផ្ដល់នូវគំនិតល្អៗ និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងចំណាយពេលវេលាដ៏មានតម្លៃរបស់លោកស្រី ក្នុងការដឹកនាំទាំងពីដើមរហូតបញ្ចប់ការសិក្សាស្រាវជ្រាវ និងចងក្រងនូវស្នាដៃនេះឡើង។

លោកស្រី **ចិន មុនី** ជាមន្ត្រី នៃក្រសួងយុត្តិធម៌ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរនាក់បានចូលជួបពិភាក្សា និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយផ្ដល់ជាគំនិតយោបល់ និងបានពន្យល់ណែនាំ ដែលនាំឱ្យសារណាមួយនេះកាន់តែមានភាពល្អប្រសើរ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមគោរពអរគុណ និងបួងសួងដល់វត្ថុសក្ដិសិទ្ធិ និងប្រសិទ្ធពរចំពោះលោកឪពុក អ្នកម្ដាយដែលជាអ្នកមានគុណូបការៈរបស់យើងខ្ញុំ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមទទួលបាននូវពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមទទួលនូវការគោរពដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

# **អារម្ភកថា**

យើងខ្ញុំឈ្មោះ **គប ចន្ធូ** និង **ខួន សេដ្ឋាទីរៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំទី៤ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការសិក្សា រៀនសូត្រ ទទួលយកចំណេះវិជ្ជាពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ យើងខ្ញុំទាំងពីរនាក់ត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ដោយយើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានមួយស្តីពី "**យុត្តិធម៌សម្រាប់អនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស**" មករៀបចំជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈនេះដោយមានគោលបំណងដើម្បីសិក្សា និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើយុត្តិធម៌ នៅក្នុងនីតិវិធីនៃដំណាក់កាលនីមួយៗដែលអនុវត្តចំពោះអនីតិជនពេលដែលអនីតិជនប្រព្រឹត្តបទល្មើស។ កិច្ចការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើ កិច្ចការពារអនីតិជនដែលបានប្រព្រឹត្តបទល្មើសស្របជាមួយនឹងនីតិវិធីដែលមានលក្ខណៈកុមារមេត្រី ដែលធ្វើយ៉ាងណាធានាដល់ការការពារឧត្តមប្រយោជន៍ និងយុត្តិធម៌សម្រាប់អនីតិជន។ បន្ថែមពីនេះទៅទៀតសារណាមួយនេះអាចលេចចេញជាផ្លែផ្កាទៅបាន ព្រោះមានការជួយជ្រោមជ្រែង ពន្យល់ និងណែនាំ ពីសំណាក់លោកស្រីសាស្ត្រាចារ្យ **ឃឹម ម៉ាណែត** ដែលលោកស្រីសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ តម្រង់ទិស ក៏ដូចជាចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងដំបូន្មានល្អៗ ដល់ការសរសេរសារណាមួយនេះឡើង។

ចំពោះសារណាមួយនេះ យើងខ្ញុំបានខិតខំពិនិត្យផ្ទៀងផ្ទាត់ អក្ខរាវិរុទ្ធ ខ្លឹមសារ កែសម្រួលអត្ថបទ និងពាក្យពេចន៍ដោយម៉ត់ចត់ហើយក្តី ក៏កំហុសខុសឆ្គងនៅតែអាចកើតមានឡើងជាក់ជាពុំខាន អាស្រ័យហេតុនេះយើងខ្ញុំសូមធ្វើការអភ័យទោសរាល់កំហុសខុសឆ្គងដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះលើឃ្លាប្រយោគ ពាក្យពេចន៍ និងអក្ខរាវិរុទ្ធ។ ជាមួយគ្នានេះដែរយើងក៏ខ្ញុំសូមស្វាគមន៍ចំពោះមតិរិះគន់ និងការកែលម្អក្នុងន័យស្ថាបនា ដើម្បីញ៉ាំងឱ្យស្នាដៃបន្តបន្ទាប់ទៀតកាន់តែមានភាពល្អប្រសើរបន្ថែម។

ជាចុងក្រោយក្នុងនាមយើងខ្ញុំជាអ្នករៀបរៀង និងតាក់តែងនូវស្នាដៃនេះឡើង យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាស្នាដៃមួយនេះនឹងក្លាយជាប្រយោជន៍ ចំពោះអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់យកទៅសិក្សាស្វែងយល់បន្ថែមអំពីយុត្តិធម៌សម្រាប់អនីតិជន។ យើងខ្ញុំសូមគោរពជូនពរដល់ សិស្ស និស្សិត និងមិត្តអ្នកអានអត្ថបទសារណាមួយនេះទាំងអស់ ឱ្យជួបតែសេចក្តីសុខ និងជោគជ័យលើការសិក្សា ក៏ដូចជាជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**....................................................................................................................១

**ជំពូកទី១**

**សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន**

**ផ្នែកទី១ ទិដ្ឋភាពទូទៅ**...........................................................................................................៧

១.១. សារៈសំខាន់នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន.....................................................................៧

១.២. គោលបំណង..........................................................................................................................៧

១.៣. វិសាលភាព.............................................................................................................................៨

**ផ្នែកទី២ ទិដ្ឋភាពច្បាប់**.............................................................................................................៨

២.១. និយមន័យយុត្តិធម៌អនីតិជន ...................................................................................................៨

២.២. គោលការណ៍ជាមូលដ្ឋានសម្រាប់អនីតិជន ..............................................................................៩

២.៣. សិទ្ធិក្នុងនីតិវិធី ......................................................................................................................១០

២.៤. ការកំណត់អំពីលក្ខខណ្ឌនៃការទទួលខុសត្រូវលើបទល្មើស.....................................................១១

២.៤.១. លក្ខខណ្ឌអាយុក្រោម១៤ ឆ្នាំ ..........................................................................................១១

២.៤.២. លក្ខខណ្ឌអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ...............................................................១២

២.៥. លក្ខខណ្ឌទាក់ទងនឹងកាលៈទេសៈនៃបទល្មើស .....................................................................១៣

២.៦. លក្ខខណ្ឌនៃបុគ្គលិកលក្ខណៈ .................................................................................................១៦

**ជំពូកទី២**

**ការទទួលបានយុត្តិធម៌នៅគ្រប់ដំណាក់កាលនៃនីតិវិធីសម្រាប់កុមារ**

**ផ្នែកទី១ ដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌**....................................................១៨

១.១. ការចាប់ខ្លួន ............................................................................................................................១៩

១.២. ការឃាត់ខ្លួន............................................................................................................................១៩

១.៣. កាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការជូនដំណឹង ........................................................២១

១.៤. ការស្តាប់ចម្លើយ .....................................................................................................................២១

១.៥. បញ្ជីស្តីពីការឃាត់ខ្លួន និងកំណត់ហេតុស្តីពីការឃាត់ខ្លួន ........................................................២២

**ផ្នែកទី២ ដំណាក់កាលអយ្យការ និងការចោទប្រកាន់** ........ ២៣
២.១. ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ........ ២៣
២.២. ការស្ដាប់ចម្លើយអនីតិជន ........ ២៤
២.៣. ការបង្វែរក្នុងដំណាក់កាលអង្គការអយ្យការ ........ ២៥
២.៣.១. លក្ខខណ្ឌអប្បបរមានៃការបង្វែរ ........ ២៥
២.៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការបង្វែរ ........ ២៦
២.៣.៣. នីតិវិធីក្នុងការបង្វែរ ........ ២៦
២.៣.៤. ការបង្កើតផែនការបង្វែរ ........ ២៧
២.៣.៥. ការបរាជ័យក្នុងផែនការបង្វែរ ........ ២៩
**ផ្នែកទី៣ ដំណាក់កាលចៅក្រមស៊ើបសួរ** ........ ៣០
៣.១. ការជូនដំណឹងអំពីការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការពិនិត្យ ........ ៣១
៣.២. ការស្ដាប់ចម្លើយ និងជំនួយរបស់មេធាវី ........ ៣១
៣.៣. អំណាចលើការបង្វែរ ........ ៣២
៣.៤. ថិរវេលានៃការឃុំខ្លួនអនីតិជន ........ ៣៣
៣.៥. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៤
៣.៦. ការបង្គាប់ដោះលែងឱ្យនៅក្រៅឃុំ ........ ៣៥
៣.៧. ការលើកលែងការចោទប្រកាន់ ........ ៣៦
**ផ្នែកទី៤ ដំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ** ........ ៣៦
៤.១. សមត្ថកិច្ចក្នុងការជំនុំជម្រះ ........ ៣៧
៤.២. នីតិវិធីមុនពេលសវនាការលើរឿងក្ដីអនីតិជន ........ ៣៨

**ជំពូកទី៣**

**វិធានការអនុវត្តទោសចំពោះអនីតិជន**

**ផ្នែកទី១ វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ៣៩
១.១. ទណ្ឌកម្មព្រហ្មទណ្ឌ ........ ៣៩
១.២. ទោសដែលអាចអនុវត្តចំពោះអនីតិជន ........ ៣៩
១.២.១. មូលទោស ........ ៣៩
១.២.២. ការប្រកាសទោសបន្ថែម ........ ៤២

១.២.៣. ការងារសហគមន៍ ...................................................................................... ៤៣
១.២.៤. ស្ថានសម្រាលទោសចំពោះអនីតិជន...................................................................... ៤៤
**ផ្នែកទី២ ការអនុវត្តទោស និងការផ្តល់នីតិសម្បទាអនីតិជនឡើងវិញ** ........................ ៤៧
២.១. ការអនុវត្តទោសចំពោះអនីតិជន.............................................................................. ៤៧
២.១.១. ការអនុវត្តទោសដាក់ពន្ធនាគារ ........................................................................... ៤៧
២.១.២.សិទ្ធិរបស់អនីតិជនអំឡុងពេលអនុវត្តទោស ............................................................ ៤៨
២.១.៣. ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ........................................................................ ៤៨
២.២. ការផ្តល់ និងការស្តារនីតិសម្បទា.............................................................................. ៥០
២.២.១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ......................................................... ៥០
២.២.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់............................................ ៥១
២.២.៣. សមត្ថកិច្ចគ្រប់គ្រងមណ្ឌលឃុំនីតិសម្បទា.............................................................. ៥២
២.២.៤. ភ្នាក់ងារក្នុងមណ្ឌលឃុំនីតិសម្បទា......................................................................... ៥៣
២.៣. ការដោះលែងដោយមានលក្ខខណ្ឌ........................................................................... ៥៥
**សេចក្តីសន្និដ្ឋាន**........................................................................................................ ៥៦
**អនុសាសន៍**................................................................................................................ ៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស និងមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូល។ ក្នុងនោះដែរយើងឃើញថា រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់ ហើយច្បាប់ជាច្រើនត្រូវបានអនុម័ត ក៏ដូចជាត្រូវបានធ្វើវិសោធនកម្មឱ្យកាន់តែស៊ីជម្រៅ និងកាន់តែលម្អិតជាងមុនបន្ថែមទៀតដើម្បីធានាដល់ការការពារសណ្តាប់ធ្នាប់សាធារណៈ និងបង្ការរាល់បទល្មើសនានាដែលកើតមាននៅក្នុងសង្គម។ បើទោះបីជាមានច្បាប់ក៏ដោយ ក៏បទល្មើសនៅតែកើតមានជាបន្តបន្ទាប់ក្រោមរូបភាព និងលក្ខណៈផ្សេងៗគ្នា ដែលបទល្មើសខ្លះត្រូវបានប្រព្រឹត្តឡើងដោយនីតិជន រីឯបទល្មើសខ្លះទៀតត្រូវបានប្រព្រឹត្តឡើងដោយអនីតិជន។ ចំពោះពាក្យថា នីតិជន សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ រីឯពាក្យថាអនីតិជន ដែលត្រូវបានគេហៅថាកុមារ គឺជាជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយសព្វថ្ងៃនេះយើងសង្កេតឃើញថាមានកុមារជាច្រើនបានចូលរួមចំណែកក្នុងការប្រព្រឹត្តបទល្មើស ដែលបទល្មើសភាគច្រើនគឺ ពាក់ព័ន្ធនឹងគ្រឿងញៀន ឆបោក លួច ប្លន់ រំលោភ មនុស្សឃាត ឃាតកម្ម និងបទល្មើសផ្សេងៗទៀតជាដើម។ ដោយសារតែកុមារបានប្រព្រឹត្តបទល្មើស និងមានវត្តមានក្នុងពន្ធនាគារជាបន្តបន្ទាប់ រាជរដ្ឋាភិបាលក៏បានព្យាយាមរិះរកវិធានការនានាដើម្បីទប់ស្កាត់ និងផ្តល់ការការពារចំពោះកុមារដែលបានប្រព្រឹត្តបទល្មើស។

ជាការពិតណាស់ កម្ពុជាបានរៀបចំនូវ បញ្ញត្តិ យុទ្ធសាស្ត្រ បទដ្ឋានគតិយុត្ត និងវិធានការនានា ដើម្បីផ្តល់ការការពារចំពោះកុមារដែលបានប្រព្រឹត្តបទល្មើស។ ក្នុងនោះ យើងឃើញថា កម្ពុជាបានបង្កើតឱ្យមានច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលច្បាប់នេះត្រូវបានរៀបចំឡើងដោយអនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងច្បាប់ និងវិធានការផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកុមារ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានប្រកាសឱ្យប្រើកាលពីឆ្នាំ២០១៦ កន្លងមកនេះឃើញថា ការអនុវត្តមានភាពល្អប្រសើរជាងមុនក៏ដូចជាបានឆ្លើយតប និងបំពេញបន្ថែមនូវភាពខ្វះចន្លោះក្នុងការអនុវត្តនីតិវិធីយុត្តិធម៌ចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស។ តាមរយៈនៃច្បាប់នេះបានផ្តល់នូវករណីពិសេសសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសឱ្យទទួលបាននូវការការពារសិទ្ធិ ការកំណត់នីតិភាពនៃការទទួលខុសត្រូវ និងនីតិវិធីនៃការអនុវត្តទោសលើអនីតិជនឱ្យបានសមស្រប។ ជាគោលការណ៍អនីតិជនមានសិទ្ធិទទួលបានការគោរពសិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជនរបស់ពួកគេនៅគ្រប់ដំណាក់កាលនៃនីតិវិធីច្បាប់ទាំងអស់ដែលសិទ្ធិនេះ គឺត្រូវអនុវត្តចាប់ពីដំណាក់កាលដំបូងនៃការអនុវត្តច្បាប់រហូតដល់មានសេចក្តីសម្រេចចូលជាស្ថាពរ ឬរហូតដល់អនីតិជនត្រូវរួចផុតពីការត្រួតពិនិត្យ ការឃុំឃាំង ឬវិធានការផ្សេងទៀតប្រសិនបើអនីតិជននោះត្រូវបានផ្តន្ទាទោស។ ជាងនេះទៅទៀតអនីតិជនដែលត្រូវរកឃើញថាបាន ឬមិនបានប្រព្រឹត្តបទល្មើសក៏ទទួលបានសិទ្ធិ និងការជំនុំជម្រះ

ដោយយុត្តិធម៌ព្រមទាំងទទួលបានការការពារបន្ថែមដោយយោងទៅតាមអាយុ ភាពចាស់ទុំ និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីរបស់ពួកគេផងដែរ។ ក្នុងករណីដែលអនីតិជនត្រូវបានរកឃើញថាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចំពោះការដាក់ពន្ធនាគារទៅលើអនីតិជន គឺធ្វើបានតែវិធានការចុងក្រោយ ឬសម្រាប់តែករណីពិសេសតែប៉ុណ្ណោះ ក្នុងន័យនេះបើអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំបានប្រព្រឹត្តបទល្មើស តុលាការគួរពិចារណាលើវិធានការបង្វែរចំពោះអនីតិជនជាមុន មុននឹងជ្រើសយកវិធានការផ្សេងមកអនុវត្ត ប៉ុន្តែប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ហើយចំពោះការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជននេះផងដែរគឺ ត្រូវតែបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារនោះ ព្រោះថាការទទួលខុសត្រូវរបស់អនីតិជនមិនអាចស្ថិតនៅលើគោលការណ៍ស្មើភាពដូចទៅនឹងនីតិជនបាននោះទេហើយច្បាប់ក៏បានកំណត់នូវគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយដាច់ដោយឡែកសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសផងដែរ ព្រោះដើម្បីជាការការពារអនីតិជនកុំឱ្យប៉ះពាល់ទៅដល់សិទ្ធិ ក៏ដូចជាបង្កនូវការលំបាកដល់អនីតិជន ។

ចំពោះប្រធានបទ "**យុត្តិធម៌សម្រាប់អនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស**" គឺជាប្រធានបទមួយដែលមានសារៈសំខាន់សម្រាប់សិស្ស និស្សិតធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់ពីអនីតិជនដែលបានប្រព្រឹត្តបទល្មើស។ តាមរយៈប្រធានបទខាងលើនេះ ខ្ញុំសង្ឃឹមថានឹងចូលរួមចំណែកជាចំណេះដឹងដល់ការអនុវត្តច្បាប់ឱ្យកាន់តែច្បាស់ទាក់ទងនឹងការការពារកុមារ ក៏ដូចជាចូលរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងក្នុងមជ្ឈដ្ឋានពលរដ្ឋកម្ពុជា រួមទាំងអនីតិជនដែលបានប្រព្រឹត្តបទល្មើសឱ្យយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងនីតិវិធីដែលតួអង្គក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រព្រឹត្តមកលើខ្លួនចំពោះអ្វីដែលត្រូវធ្វើ និងអ្វីដែលត្រូវហាមឃាត់។ ដូច្នេះប្រធានបទនេះនឹងផ្តល់នូវខ្លឹមសារ និងផលប្រយោជន៍ជាច្រើនដល់អ្នកសិក្សាឱ្យកាន់តែយល់ច្បាស់អំពីយុត្តិធម៌ដែលអនីតិជនទទួលបាននៅពេលដែលខ្លួនប្រព្រឹត្តបទល្មើសអ្វីមួយ ក៏ដូចជាអាចចូលរួមចំណែកទុកជាឯកសារសម្រាប់ឱ្យនិស្សិតជំនាន់ក្រោយៗ បានសិក្សាស្រាវជ្រាវ ។ តើប្រធានបទដែលបានលើកឡើងខាងលើនេះបានរួមចំណែកអ្វីខ្លះសម្រាប់ការពារប្រយោជន៍អនីតិជនដែលប្រព្រឹត្តបទល្មើស? តើប្រធានបទខាងលើនេះបានផ្តល់ជាប្រយោជន៍អ្វីខ្លះដល់អ្នកសិក្សាស្រាវជ្រាវ និងសង្គមជាតិទាំងមូល?

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ផ្អែកទៅតាមលំនាំបញ្ហាខាងលើ យើងអាចមើលឃើញថា កុមារដែលយើងហៅថាអនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលមិនទាន់មានលក្ខណៈវិនិច្ឆ័យបានច្បាស់លាស់ ក៏ដូចជាមានសមត្ថភាពនៃយល់ដឹងចំពោះអំពើដែលខ្លួនបានប្រព្រឹត្តមានកម្រិតនៅឡើយ ដូច្នេះក្នុងករណីដែលអនីតិជនបានប្រព្រឹត្តអំពើ

ទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម តុលាការមិនអាចសម្រេចផ្តន្ទាទោសលើអនីតិជនដូចទៅនឹងនីតិជនបានឡើយ ព្រោះជាគោលការណ៍គេមិនអាចឱ្យជនដែលពុំទាន់គ្រប់អាយុ និងមិនអាចពិចារណាពីសភាពធ្ងន់ធ្ងរនៃអំពើដែលខ្លួនប្រព្រឹត្តមកទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ លុះត្រាតែកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃអនីតិជននោះតម្រូវ ទើបតុលាការអាចសម្រេចទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជននោះបាន។

ហេតុដូច្នេះ ប្រធានបទស្តីពី "**យុត្តិធម៌សម្រាប់អនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស**" ត្រូវបានជ្រើសរើស និងធ្វើការតាក់តែងឡើងដើម្បីផ្តល់ឱ្យសិស្ស និស្សិតជំនាន់ក្រោយ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវអាចធ្វើការស្រាវជ្រាវលើប្រធានបទឱ្យកាន់តែច្បាស់លាស់ និងស៊ីជម្រៅបន្ថែមទៀតទៅលើការការពារ និងការទទួលបានសិទ្ធិបែបណាខ្លះចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស? តើគួរតែមានវិធានការ និងនីតិវិធីបែបណាខ្លះសម្រាប់អនុវត្តលើអនីតិជនពេលដែលរកឃើញថាបាន ឬមិនបានប្រព្រឹត្តបទល្មើស? តើគួរអនុវត្តទោសបែបណាខ្លះ នៅពេលដែលរកឃើញថា អនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំមានគោលបំណងមួយចំនួន ៖

ទី១ ស្វែងយល់អំពីការការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍អនីតិជនដែលប្រព្រឹត្តបទល្មើសដោយការសិក្សាឱ្យបានច្បាស់លាស់ទៅលើអាយុ និងបទល្មើសរបស់អនីតិជន ជៀសវាងធ្វើឱ្យអនីតិជនបាត់បង់អនាគត

ទី២ ស្វែងយល់បន្ថែមទាក់ទងនឹងយុត្តិធម៌សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការទទួលបានសិទ្ធិ ជំនួយ ការបង្វែរ និងនីតិវិធីនៃការអនុវត្តគ្រប់ដំណាក់កាលលើអនីតិជន

ទី៣ ចូលរួមចំណែកដល់ការគាំទ្រ ដល់ការស្តារនីតិសម្បទាចំពោះអនីតិជនដើម្បីអាចឱ្យអនីតិជនបានធ្វើការ អប់រំ កែប្រែ ទទួលបានការគាំពារ ថែទាំ ឬការដាក់កម្រិតទោសឱ្យបានសមស្របនឹងលក្ខខណ្ឌអាយុជាក់ស្តែងរបស់អនីតិជន

ទី៤ ស្វែងយល់ឱ្យកាន់តែច្បាស់អំពី វិធានការ ក៏ដូចជានីតិវិធីដែលតុលាការអនុវត្តមកលើអនីតិជន

ទី៥ ស្វែងយល់ឱ្យកាន់តែច្បាស់អំពីការប្រកាស និងអនុវត្តទោសមកលើអនីតិជន

ទី៦ ចូលរួមការលើកកម្ពស់ ការអនុវត្តច្បាប់ ក៏ដូចជាការលើកកម្ពស់សិទ្ធិកុមារ

ទី៧ ដើម្បីចូលរួមចំណែកក្នុងការការពារប្រយោជន៍អនីតិជន ដោយសារតែការអនុវត្តក្នុងសង្គមជាក់ស្តែងនូវមានចន្លោះប្រហោង តួយ៉ាងក្នុងដំណាក់កាលនគរបាលយុត្តិធម៌ដែលបានធ្វើការចាប់ ឬឃាត់ខ្លួនអនីតិជន

មិនបានសិក្សាលម្អិតទៅលើលក្ខខណ្ឌដែលត្រូវឃាត់ខ្លួនអនីតិជន និងមិនបានជូនដំណឹងទៅឪពុក ម្ដាយឱ្យដឹងភ្លាមៗ[1]

ទី៨ ដើម្បីទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវលើប្រធានបទខាងលើបន្តឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។

## ១.៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំនៃការសិក្សាស្រាវជ្រាវនេះ មានកំណត់ និងវិសាលភាពលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ២០១១ អនុសញ្ញាស្ដីពីសិទ្ធិកុមារ ឯកសារ បទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងយុត្តិធម៌សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស។ ក្រៅពីនេះក្រុមយើងខ្ញុំក៏បានពឹងផ្អែកលើឯកសារថ្មីៗ ដែលបានចុះស្រាវជ្រាវ ពីនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន នៃក្រសួងយុត្តិធម៌បន្ថែមដូចជា របាយការណ៍ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជន។

ចំពោះដែនកំណត់នៃការស្រាវជ្រាវលើប្រធានបទនេះថា តើវិធានគតិយុត្តដែលអនុវត្តចំពោះអនីតិជនមានសារៈសំខាន់អ្វីខ្លះ តើវាមានអានុភាពគតិយុត្តយ៉ាងដូចម្ដេច? លទ្ធផលនៃការស្រាវជ្រាវផ្ដល់ប្រយោជន៍អ្វីខ្លះដល់អ្នកសិក្សា ហើយតើយើងគួរពិភាក្សាលើប្រធានបទនេះត្រង់ចំណុចណាខ្លះ និងផ្ដល់ប្រយោជន៍អ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទដែល យើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវ បានផ្ដល់នូវសារៈសំខាន់៖

- មានសារៈសំខាន់ចំពោះកុមារ គឺផ្ដល់ឱ្យកុមារទទួលបាននូវការពារ និងការពិចារណា រកហេតុផលឱ្យបានច្បាស់លាស់មុននឹងសម្រេចដាក់ទោសលើកុមារ ដើម្បីជៀសវាងផលប៉ះពាល់ចំពោះអនាគតកុមារទៅថ្ងៃខាងមុខ
- មានសារៈសំខាន់ចំពោះសង្គម ព្រោះកុមារជាធនធានក្នុងការបន្តវេនសម្រាប់អភិវឌ្ឍសង្គម កាលណាបើកុមារបន្តជាប់ពន្ធធនាគារច្រើននោះសង្គមនឹងបាត់បង់ធនធាន ដូចនេះសង្គមត្រូវរិះរកគ្រប់មធ្យោបាយដោយការបង្កើតច្បាប់ យុទ្ធនាការនានា ដើម្បីការពារដល់កុមារគ្រប់ដំណាក់កាលទាំងអស់
- មានសារៈសំខាន់ចំពោះប្រព័ន្ធច្បាប់ ព្រោះធ្វើឱ្យច្បាប់នូវកម្ពុជាកាន់តែមានអ្នកយល់ដឹង ហើយការអនុវត្តក៏កាន់តែមានប្រសិទ្ធិភាព

[1] យល់ដឹងអំពីច្បាប់ "ប្រធានបទការឃាត់ខ្លួន"

- មានសារៈសំខាន់ចំពោះខ្ញុំ សម្រាប់ប្រធានបទនេះបានជំនួយស្មារតី និងផ្តល់ជាប្រយោជន៍ដល់ចំណេះដឹង យ៉ាងច្រើនសម្រាប់ខ្ញុំ ព្រោះខ្ញុំបានស្វែងយល់ និងស្រាវជ្រាវលើប្រធានបទនេះយ៉ាងយកចិត្តទុកដាក់
- ព័ត៌មានផ្សេងៗដែលបានមកពីការស្រាវជ្រាវបានផ្តល់ជាបទពិសោធន៍ក្នុងការសរសេរ អាន និងផ្តល់បំណិនបន្ថែមដើម្បីឱ្យយល់ពីខ្លឹមសារនៃប្រធានបទខាងលើកាន់តែច្បាស់ដែលនាំឱ្យការពន្យល់បានល្អ និងក្បោះក្បាយ។

## ១.៦. វិធីសាស្ត្រស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ លើប្រធានបទនេះដើម្បីឱ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមានលក្ខណៈវិទ្យាសាស្ត្រ និងមានកម្រិតជឿជាក់អាចទទួលយកបានដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

ការកំណត់អថេរដើម្បីកំណត់ទិសដៅស្វែករកទិន្នន័យយើងត្រូវកំណត់អថេរជាមុន ដែលមានទាំងអថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

***អថេរឯករាជ្យ*** សំដៅលើច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដូចជា៖

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

២. ក្រមនីតិវិធីព្រហ្មទណ្ឌ

៣. ក្រមព្រហ្មទណ្ឌ

៥. ច្បាប់ស្តីពីពន្ធនាគារ

៦. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

៧. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

៨. សេចក្តីណែនាំទាក់ទងនឹងការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជន

៩. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។

***អថេរមិនឯករាជ្យ*** សំដៅលើយន្តការ និងដំណើរការនៃការអនុវត្តការងារយុត្តិធម៌អនីតិជន របស់នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន នៃអគ្គនាយកដ្ឋានព្រហ្មទណ្ឌ។

*ការប្រមូលទិន្នន័យ*

កិច្ចស្រាវជ្រាវនេះ ត្រូវបានរៀបចំចងក្រងឡើងដោយឆ្លងកាត់នូវពីរដំណាក់កាលគឺ៖
ទី១ ដំណាក់កាលទី១៖ ស្វែងរកអត្ថបទច្បាប់ សៀវភៅសារណា និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលមានស្រាប់
ទី២ ដំណាក់កាលទី២៖ ចុះប្រមូលទិន្នន័យតាមបែបគុណវិស័យដោយចុះទៅជួបសំណេះសំណាលផ្ទាល់ជាមួយមន្ត្រីដែលអនុវត្តការងារកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន ដើម្បីទទួលបានបទពិសោធន៍ ក៏ដូចជាទទួលបានចំណេះដឹងឱ្យកាន់តែស៊ីជម្រៅទាក់ទងនឹងវិស័យយុត្តិធម៌អនីតិជនបន្ថែមទៀត។

*ការវិភាគទិន្នន័យ*

ទិន្នន័យដែលយើងខ្ញុំប្រមូលបានមកនឹងធ្វើការវិភាគតាមបែបពិពណ៌នា ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីលក្ខខណ្ឌច្បាប់ដែលទាក់ទងនឹងដំណើរការយុត្តិធម៌ក្នុងដំណាក់កាលនៃនីតិវិធីដែលអនុវត្តលើកុមារ រួមទាំងការអនុវត្តទោសលើកុមារដោយភាពសមស្រប ដើម្បីទុកជាជំនួយជួយដល់ការការពារផលប្រយោជន៍របស់កុមារពេលដែលសង្ស័យថាប្រព្រឹត្តបទល្មើស ឬត្រូវបានរកឃើញថា ប្រព្រឹត្តបទល្មើស ។

## ១.៧. រចនាសម្ព័ន្ធការសិក្សាស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះត្រូវបានចែកចេញជា ១កថាខណ្ឌ និង៣ជំពូកគឺ៖
កថាខណ្ឌទី១ និយាយអំពី៖ សេចក្តីផ្តើមដែលបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្រ្តស្រាវជ្រាវ និងរចនាសម្ព័ន្ធស្រាវជ្រាវ។

**ជំពូកទី១ សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន**

**ជំពូកទី២ ការទទួលបានយុត្តិធម៌នៅគ្រប់ដំណាក់កាលនៃនីតិវិធីសម្រាប់កុមារ**

**ជំពូកទី៣ វិធានការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១

# សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# ជំពូកទី១

# សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាសមិទ្ធផលដ៏ធំធេងនៃកិច្ចសហប្រតិបត្តិការអស់រយៈពេលជិត១៤ (ដប់បួន) ឆ្នាំ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័ន ព្រមទាំងដៃគូពាក់ព័ន្ធ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស ក៏ដូចជាធានានូវសង្គតិភាព ភាពរលូន និងស៊ីសង្វាក់ទៅនឹងច្បាប់ដែលមានស្រាប់សម្រាប់ការអនុវត្តចំពោះអនីតិជន។

## ផ្នែកទី១ ទិដ្ឋភាពទូទៅ

### ១.១. សារៈសំខាន់នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនគឺជា ឧបករណ៍ដ៏សំខាន់បំផុតសម្រាប់ផ្តល់ការយល់ដឹង និងការអនុវត្តឱ្យកាន់តែច្បាស់ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ទៅលើកិច្ចការពារ និងការគ្រប់គ្រងលើវិស័យយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជនប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យអ្នកអនុវត្តច្បាប់បានយល់ដឹងអំពីនីតិវិធីសម្រាប់អនុវត្តលើអនីតិជន ក៏ដូចជាការអនុវត្តនូវវិធានបង្វែរលើអនីតិជនចេញពីប្រព័ន្ធតុលាការដែលជាគោលការណ៍ចម្បងក្នុងការអនុញ្ញាតឱ្យអនីតិជនដែលប្រព្រឹត្តបទល្មើសទៅរស់នៅក្នុងសហគមន៍បានធម្មតា ដែលនេះដើម្បីក្នុងគោលបំណងបម្រើឧត្តមប្រយោជន៍កុមារ ក៏ដូចជាធ្វើឱ្យគ្រប់នីតិវិធីដែលពាក់ព័ន្ធនឹងអនីតិជនដែលប្រព្រឹត្តបទល្មើសមានលក្ខណៈកុមារមេត្រី និងខិតខំបញ្ចៀសនូវផលប៉ះពាល់ជាអវិជ្ជមានចំពោះកុមារជាពិសេសក្នុងបញ្ជីថ្កោលទោស។

### ១.២. គោលបំណង

នៅក្នុងសង្គមមួយយើងសង្កេតឃើញថា ច្បាប់ពិតជាមានសារៈសំខាន់ណាស់ក្នុងការយកទៅគ្រប់គ្រងសង្គមឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ ក៏ដូចជាធានាបាននូវសន្តិភាព សុវត្ថិភាព និងការអភិវឌ្ឍ តាមរយៈការបង្កើតឱ្យមានច្បាប់នេះឯង។ តួយ៉ាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានតាក់តែងឡើងក្នុងគោលបំណងធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស ក៏ដូចជាគាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គមវិញ។ ក្នុងនោះដែរ ច្បាប់នេះក៏បានកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយម៉ត់ចត់ ដើម្បីកំណត់ឱ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន។ ក្នុងន័យនេះ គឺសំដៅលើវិធាន ឬយន្តការទាំងឡាយណាដែលផ្តល់នូវការការពារដល់ឧត្តមប្រយោជន៍ជូនទៅដល់អនីតិជន ក៏ដូចជាការប្រើប្រាស់នូវនីតិវិធីដោះស្រាយ

ណាមួយដោយមានការគោរពទៅដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរចំពោះអនីតិជនជាចម្បង។

### ១.៣. វិសាលភាព

ចំពោះច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាច្បាប់មួយដែលមានវិសាលភាពគ្របដណ្តប់លើករណីអនីតិជនដែលប្រព្រឹត្តបទល្មើស។ ប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលកន្លងមកផ្តោតលើការផ្តន្ទាទោសជាចម្បង ដែលនាំឱ្យមិនសូវមានភាពជោគជ័យក្នុងការស្តារនីតិសម្បទានៅក្នុងសង្គម និងសហគមន៍។ មានការទទួលស្គាល់ជាទូទៅថា ការផ្តន្ទាទោសអនីតិជនតាមរយៈដំណើរការរឿងក្តីព្រហ្មទណ្ឌ ពិតជាបណ្តាលឱ្យអនីតិជនធ្លាក់ចូលទៅនឹងរឿងក្តីព្រហ្មទណ្ឌ និងអាចបង្កឱ្យអនីតិជននោះមានការប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀត ហើយពេលខ្លះការប្រព្រឹត្តបទល្មើសថ្មី គឺអាចធ្ងន់ធ្ងរជាងបទល្មើសមុនទៀតក៏មាន[2]។ ដូច្នេះហើយចាំបាច់ត្រូវតែមាន ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មកឆ្លើយតបបន្ថែមទៅលើរឿងក្តីអនីតិជន ព្រោះថាច្បាប់នេះបានផ្តល់ការគាំទ្រដល់ឧត្តមប្រយោជន៍អនីតិជន ក៏ដូចជាផ្តល់កិច្ចការពារដល់អនីតិជនដែលប្រពឹត្តបទល្មើស និងជួយអភិវឌ្ឍប្រព័ន្ធយុត្តិធម៌អនីតិជនឱ្យកាន់តែច្បាស់លាស់ប្រកបដោយនិរន្តភាពដែលផ្តោតលើការយកចិត្តទុកដាក់ចំពោះវិធានការបង្វែរ ការស្តារនីតិសម្បទា ដែលជាសកម្មភាពចម្បងជាជាងការដាក់ទណ្ឌកម្មក្នុងពន្ធនាគារ។ បន្ថែមពីនេះ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់ជាជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារផងដែរគឺមានដូចជា វិធានការតាមដាន វិធានការពារ វិធានការឧបត្ថម្ភ វិធានការអប់រំ និងការដាក់ឱ្យបម្រើការងារសហគមន៍[3]។ ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺត្រូវមានវិសាលភាពអនុវត្តដោយឥតលម្អៀងចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬស្ថានភាពដទៃផ្សេងៗទៀតឡើយ។

## ផ្នែកទី២ ទិដ្ឋភាពច្បាប់

### ២.១. និយមន័យយុត្តិធម៌អនីតិជន

ដើម្បីអាចកំណត់និយមន័យនៃពាក្យ យុត្តិធម៌អនីតិជន យើងត្រូវធ្វើការស្វែងយល់ទៅលើពាក្យយុត្តិធម៌ និងពាក្យអនីតិជនជាមុនសិន។ ចំពោះពាក្យថាយុត្តិធម៌ ជាទ្រឹស្តីផ្នែកច្បាប់ ឬទស្សនវិជ្ជាដែលកំណត់ថាគេត្រូវតែគ្រប់គ្រងលើភាពត្រឹមត្រូវសមហេតុផល។ រីឯពាក្យថា អនីតិជន គឺជាពាក្យពេចន៍នៃវិស័យច្បាប់ដែលជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទូទៅនៃបទបញ្ញត្តិទូទៅដែលជាការកំណត់អាយុរបស់រូបវន្តបុគ្គលណាម្នាក់ដែលត្រូវបានគិតថាពុំមានសមត្ថភាពក្នុងការវិនិច្ឆ័យទៅលើសកម្មភាពរបស់ខ្លួន ដូចនេះនឹងត្រូវបានការពារដោយ

[2] សៀវភៅផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៨-២០១៩

[3] សៀវភៅស្តីពី ជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារកុមារនៅកម្ពុជា របស់អង្គការជីវិតនៅកម្ពុជា

ច្បាប់។ យោងតាមមាត្រា៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនបានចែងថា អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង១៨ (ដប់ប្រាំបី) ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស។

ជារួមមកវិញពាក្យថា យុត្តិធម៌អនីតិជនសំដៅដល់ការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយម៉ត់ចត់ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស[4]។

## ២.២. គោលការណ៍ជាមូលដ្ឋានសម្រាប់អនីតិជន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធទៅនឹងអនីតិជន ត្រូវធានាឱ្យមានការគោរពគោលការណ៍យកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា និងសេចក្ដីថ្លៃថ្នូរដល់អនីតិជន។ អនីតិជនមានសិទ្ធិក្នុងការសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវយកមកពិចារណាថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន។

ចំពោះការអនុវត្តការចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសលើអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន ហើយមិនត្រូវរើសអើងចំពោះអនីតិជន និងមិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងៗដែលឃោរឃៅ អមនុស្សធម៌ ក៏ដូចជាមិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន ក៏ដូចជាបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព។ ការផ្សព្វផ្សាយអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ។

ជារួមមកវិញ អាជ្ញាធរដែលមានសមត្ថកិច្ចលើរឿងក្ដីអនីតិជន ជាគោលការណ៍ត្រូវសមាមាត្រមិនត្រឹមតែទៅនឹងស្ថានទម្ងន់នៃបទល្មើសទេ តែអាស្រ័យទៅលើកាលៈទេសៈផ្ទាល់របស់អនីតិជន ដូចជា អាយុ រួមទាំងសេចក្ដីត្រូវការរបស់អនីតិជនផងដែរ។

ទាក់ទងនឹងការប្រើប្រាស់កម្មវិធីសហគមន៍ និងកម្មវិធីសមស្របផ្សេងៗសម្រាប់ការបង្វែរអនីតិជនចេញពីនីតិវិធីតុលាការត្រូវបានពិចារណាក្នុងរាល់ដំណាក់កាល។ ក្នុងករណីដែលការបង្វែរនោះមិនមានលក្ខណៈសមស្របទេនោះ ចំពោះការឃុំខ្លួនអនីតិជន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន[5] ។ ស្ថិតក្នុងករណីដែលឃុំខ្លួនអនីតិជនក្នុងមណ្ឌលគឺ ត្រូវធ្វើ

[4] មាត្រា ៤ នៃច្បាប់ស្ដីពីយុតិធម៌អនីតិជន ឆ្នាំ២០១៦

[5] មាត្រា៥ នៃព្រះរាជក្រមយោងខាងលើ

ឡើងដោយផ្តល់ការថែរក្សា ការពារ និងផ្តល់ជំនួយឧបត្ថម្ភផ្នែកអប់រំ ផ្នែកចិត្តសាស្ត្រ និងផ្នែកពេទ្យតាមការចាំបាច់ដើម្បីសម្រួលដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនចូលក្នុងសង្គមវិញ។ ដោយឡែកចំពោះការដកហូតសិទ្ធិសេរីភាពរបស់អនីតិជន ឬសម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌត្រូវធ្វើឡើងក្នុងករណីណាដែលចាំបាច់តែប៉ុណ្ណោះ ដូចទាក់ទងនឹងករណីអនីតិជនប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងបទល្មើសឃាតកម្ម រំលោភសេពសន្ថវៈ ឬក៏បទល្មើសធ្ងន់ធ្ងរផ្សេងៗទៀតជាដើម ។

## ២.៣. សិទ្ធិក្នុងនីតិវិធី

គ្រប់ដំណើរការនៃនីតិវិធីទាំងមូលត្រូវប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងអនុញ្ញាតឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានការសម្តែងមតិដោយសេរីពីសំណាក់អនីតិជន និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ក្នុងករណីដែលអនីតិជនជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសអនីតិជននឹងទទួលបានសិទ្ធិជាមូលដ្ឋាន ក្នុងនីតិវិធីដូចជា៖

១. សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី

២. សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង

៣. សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន

៤. សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល

៥. សិទ្ធិទទួលបានដំណឹងអំពីបទចោទប្រកាន់

៦. សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់

៧. សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី

៨. សិទ្ធឱ្យមានការចូលរួមពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តីប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន

៩. សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃកាលបើមានការចាំបាច់

១០. សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ

១១. សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ

១២. សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជន ជាជនបរទេស[6] ។

[6] មាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

គ្រប់ដំណើរការនៃនីតិវិធីទាំងមូលដែលមានខាងលើនេះត្រូវគោរពនូវសិទ្ធិជីវិតឯកជនរបស់អនីតិជនហើយត្រូវរក្សាទុកកំណត់ហេតុនានានៃរឿងក្តីអនីតិជនជាការសម្ងាត់ ដើម្បីជៀសវាងនូវព្យសនកម្មបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬដោយសារការជេរប្រមាថ។ ដូច្នេះការផ្សព្វផ្សាយរាល់ព័ត៌មានណាដែលទាក់ទងទៅនឹងរឿងក្តីអនីតិជន គឺមិនត្រូវបានអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយទេ លុះត្រាតែមានការអនុញ្ញាតពីចៅក្រមដែលត្រូវបានចាត់តាំងឱ្យកាន់រឿងក្តីអនីតិជនទើបការផ្សព្វផ្សាយនោះអាចធ្វើទៅបាន។ ចំពោះការអនុញ្ញាតរបស់អាជ្ញាធរអាចធ្វើទៅបានល្គឹកណាតែក្នុងគោលបំណង អប់រំ សិក្សាស្រាវជ្រាវ ឬក៏ផ្សព្វផ្សាយជាសាធារណៈ ប្រសិនបើយល់ថាជារឿងចាំបាច់ ប៉ុន្តែការអនុញ្ញាតនេះទៀតសោត គឺមិនត្រូវធ្វើឱ្យបែកធ្លាយនូវអត្តសញ្ញាណរបស់អនីតិជនឡើយ។

## ២.៤. ការកំណត់អំពីលក្ខខណ្ឌនៃការទទួលខុសត្រូវលើបទល្មើស

ជាគោលការណ៍នៅពេលដែលមានបទល្មើសមួយបានកើតឡើង គឺត្រូវតែមានបុគ្គលណាម្នាក់មកទទួលខុសត្រូវចំពោះបទល្មើសនោះ បើទោះបីជាអ្នកប្រព្រឹត្ត ជានីតិជនក្តី ឬអនីតិជនក្តី។ ក្នុងករណីដែលគេពិនិត្យឃើញថាបទល្មើសដែលបានកើតឡើងនោះ ប្រព្រឹត្តដោយអនីតិជន ដូចនេះត្រូវកំណត់ឱ្យបានច្បាស់លាស់ជាមុនទាក់ទងនឹងលក្ខខណ្ឌអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនមុននឹងសម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន។ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវបានកំណត់យកអាយុនៅពេលដែលអនីតិជនប្រព្រឹត្តបទល្មើស[7]។

ចំពោះការកំណត់អំពីកម្រិតអាយុនៃការទទួលខុសត្រូវនេះ គឺជាការប្រកាន់យក និងទទួលស្គាល់ជាផ្លូវការពីសំណាក់រដ្ឋថា អនីតិជននៅពេលដែលឈានទៅដល់អាយុតាមការកំណត់ទើបមានលទ្ធភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[8]។ បន្ថែមពីនេះទៀតក្នុងករណីដែលយល់ឃើញថា អនីតិជនដែលប្រព្រឹត្តបទល្មើស មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមធ្ងន់ធ្ងរ តុលាការអាចពិចារណាបង្វែរអនីតិជន ឬក៏ចាត់វិធានការសមស្របណាមួយដើម្បីជម្រុញការស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជននោះទៅក្នុងសង្គមវិញ។

### ២.៤.១. លក្ខខណ្ឌអាយុក្រោម១៤ ឆ្នាំ

យោងទៅតាមមាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន បានចែងថា អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់កំណត់។ ជាមួយគ្នាដែរ មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ដដែល ក៏បានចែងផងដែរថា ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់

[7] មាត្រា ៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[8] *សូមមើល* សៀវភៅព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ ហ៊ី សោភា, ទំព័រ៨០

បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម។ សូមបញ្ជាក់ផងដែរថា អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ[9]។

ដូចនេះ ស្ថិតតាមខ្លឹមសារខាងលើអាចសន្និដ្ឋានបានថា អាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរមានៃការទទួលត្រូវព្រហ្មទណ្ឌ ហើយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ពុំត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ ក្មេងស្រីម្នាក់ដែលមានអាយុ ១០ (ដប់) ឆ្នាំ កំពុងរត់លេងជាមួយនឹងក្មេងប្រុសម្នាក់ទៀតនៅក្បែរផ្ទះនាង ខណៈកំពុងរត់លេង ក្មេងស្រីម្នាក់នោះក៏មិនប្រយ័ត្ន ក៏បានរត់បុកក្មេងប្រុសដែលលេងជាមួយនាងឱ្យដួលបោកក្បាលត្រូវនឹងជញ្ជាំងផ្ទះ ដែលបណ្ដាលឱ្យក្មេងប្រុសនោះបែកក្បាល និងសន្លប់។ ស្ថិតក្នុងករណីនេះដែរក្មេងស្រីដែលបានប្រព្រឹត្តនោះ គឺមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ព្រោះថាក្មេងស្រីម្នាក់នោះទើបតែមានអាយុ ១០ (ដប់) ឆ្នាំប៉ុណ្ណោះដែលជាហេតុធ្វើឱ្យក្មេងស្រីនោះមិនទាន់មានការយល់ដឹង និងការវិនិច្ឆ័យបានច្បាស់លាស់នៅអំពើដែលនាងបានធ្វើនោះទេ។

សូមបញ្ជាក់ផងដែរថាអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកនៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលរារាំងមិនឱ្យតុលាការធ្វើការប្រកាសទោសទៅលើអនីតិជនបាននោះទេ។ ប៉ុន្តែមិនមានន័យថា បានរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្ដីសម្រេចនោះទេ។ ដែលតាមរយៈនេះមានន័យថា តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឱ្យចូលខ្លួនមកកាន់តុលាការបានផងដែរ តែក្នុងគោលបំណងដើម្បីប្រកាសសេចក្ដីសម្រេចដាក់ឱ្យអនុវត្តនូវវិធានការណាមួយដែលតុលាការបានធ្វើការសម្រេចមកលើអនីតិជនរូបនោះ ហើយវិធានការទាំងនោះរួមមាន វិធានការតាមដាន វិធានការអប់រំ វិធានការពារ និងវិធានការឧបត្ថម្ភ ឬក៏ប្រគល់អនីតិជននោះទៅឱ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬស្ថាប័នឯកទេស និងដាក់អនីតិជននោះឱ្យស្ថិតក្រោមការពាររបស់តុលាការបានផងដែរ[10]។

### ២.៤.២. លក្ខខណ្ឌអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំដែលបានប្រព្រឹត្តបទលហុ ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដោយមន្ត្រីនគរបាលមានសមត្ថកិច្ចគ្រាន់តែយកអនីតិជននោះធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរបន្ទាប់មកប្រគល់អនីតិជននោះឱ្យអ្នក

[9] មាត្រា ៣៩ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[10] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

តំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង។ ក្នុងករណីដែលអនីតិជនសារភាពនូវកំហុសរបស់ខ្លួន គេអាចអនុវត្តវិធានការសម្រុះសម្រួលគ្នារវាងភាគីដើម្បីបញ្ចប់វិវាទ។[11]

ក្នុងករណីដែលយល់ឃើញថា អនីតិជនប្រភេទខាងលើនេះបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ និងមានសមត្ថភាពនៃការទទួលខុសត្រូវ ក៏ដូចជាមានលទ្ធភាពយល់ដឹងពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចបញ្ជានូវរាល់អំពើទាំងនោះបានមានន័យថា អនីតិជនដែលបានប្រព្រឹត្តអំពើល្មើសនោះ គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត។ ក្នុងករណីនេះដែរ បើតុលាការសម្រេចឱ្យអនីតិជនដែលប្រព្រឹត្តអំពើល្មើសនោះមកទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន ក៏ការទទួលខុសត្រូវនេះមិនមានលក្ខណៈពេញលេញដូចទៅនឹងនីតិជនឡើយពោលគឺ ស្ថានភាពដែលអនីតិជនត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន ហើយដើម្បីអាចផ្តន្ទាទោសលើអនីតិជនបានលុះត្រាណាតុលាការធ្វើការត្រួតពិនិត្យពិចារណា ក៏ដូចជាថ្លឹងថ្លែងជាមុនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត ក៏ដូចជាពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់អនីតិជននោះផងដែរ ហើយកម្រិតនៃទោសដែលទទួលរង គឺត្រូវបន្ធូរបន្ថយមកត្រឹមពាក់កណ្តាលនៃទោសពីទោសធម្មតា មានន័យថាបើទោសធម្មតា ១០ឆ្នាំ នោះអនីតិជននឹងត្រូវទទួលទោសតែ ៥ឆ្នាំប៉ុណ្ណោះ។

ឧទាហរណ៍៖ ក្មេងប្រុសម្នាក់ អាយុ១៧ (ដប់ប្រាំពីរ) ឆ្នាំបានធ្វើសកម្មភាពរំលោភសេពសន្ថវៈទៅលើក្មេងស្រីអាយុ ១៤ (ដប់បួន) ឆ្នាំ ដែលសកម្មភាពក្មេងប្រុសរូបនេះបានប្រព្រឹត្តមិនអាចជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយអះអាងថាខ្លួនគ្មានចេតនា និងមិនដឹងពីអ្វីដែលខ្លួនបានប្រព្រឹត្តនោះទេ។ ដូចនេះចំពោះអំពើល្មើសដែលអនីតិជននោះបានប្រព្រឹត្ត គឺត្រូវទទួលទោស ហើយចំពោះទោសដែលអនុវត្តលើអនីតិជនរូបនោះ គឺត្រូវបន្ថយមកត្រឹមពាក់កណ្តាល បើធៀបទៅនឹងទោសដែលត្រូវអនុវត្តចំពោះនីតិជន។

ចំពោះករណីណាតម្រូវឱ្យជាប់ពន្ធនាគារមួយជីវិត គឺតុលាការនឹងកាត់បន្ថយទោសនោះមកត្រឹម ២០ឆ្នាំវិញ ក្នុងករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ។ ចំណែកទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយមកកណ្តាលផងដែរ ហើយក្រៅពីមូលទោស គឺអនីតិជន ក៏អាចប្រកាសទោសបន្ថែម និងទោសការងារសហគមន៍ទៅតាមសេចក្តីសម្រេចរបស់តុលាការផងដែរ។

## ២.៥. លក្ខខណ្ឌទាក់ទងនឹងកាលៈទេសៈនៃបទល្មើស

ដោយហេតុថា ច្បាប់ពុំបានកំណត់ច្បាស់លាស់ទាក់ទងនឹងនិយមន័យ ឬផ្តល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យកាលៈទេសៈនៃបទល្មើសឱ្យបានច្បាស់លាស់ ដូចនេះអាចឱ្យគេយល់ថា កាលៈទេសៈនៃបទល្មើស គឺសំដៅទៅលើកត្តារួមផ្សំនៃបទល្មើស។ ពោលគឺវាមានតួនាទីសម្រាប់កំណត់បទល្មើស និងកំណត់អំពីព្រំដែននៃទណ្ឌកម្ម

[11] មាត្រា ១៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ផងដែរ។ យើងអាចធ្វើការសិក្សាស្វែងយល់ និងពិចារណាតាមរយៈបទពិសោធន៍ជាក់ស្តែងរបស់ចៅក្រម និងការសម្រេចដាក់ទណ្ឌកម្មជាក់ស្តែងទៅលើអនីតិជនដែលជាជនល្មើសតាមរយៈកត្តារួមផ្សំដូចខាងក្រោម[12]៖

**មធ្យោបាយប្រព្រឹត្តបទល្មើស**

មធ្យោបាយប្រព្រឹត្តបទល្មើស សំដៅលើបណ្ដាវត្ថុ ឬសម្ភារ និងរួមបញ្ចូលទាំងឧបករណ៍ប្រព្រឹត្តបទល្មើសដែលអនីតិជននោះបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស។

ឧទាហរណ៍៖ ក្នុងករណីដែលអនីតិជនម្នាក់បានប្រព្រឹត្តអំពើហិង្សាទៅលើអនីតិជនម្នាក់ទៀត ដោយការប្រើប្រាស់អាវុធ ឬគំរាមកំហែងនឹងអាវុធ នោះវាជាសញ្ញាមួយដែលបញ្ជាក់យ៉ាងច្បាស់ពីអំពើដែលអនីតិជននោះបានប្រព្រឹត្តគឺ ផ្តល់នូវផលប៉ះពាល់ធ្ងន់ធ្ងរទៅដល់ជនរងគ្រោះដែលជាអនីតិជនដូចគ្នា ដូចនេះអំពើនោះជាសញ្ញាដែលបញ្ជាក់អំពីស្ថានទម្ងន់ទោសក្នុងបទហិង្សាដោយចេតនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២១៨។

**វិធីសាស្ត្រប្រព្រឹត្តបទល្មើស**

ទាក់ទងជាមួយនឹងវិធីសាស្ត្រប្រព្រឹត្តបទល្មើស ជាបែបផែននៃវិធីការប្រព្រឹត្តអំពើល្មើស ឬអាចនិយាយបានថា ការចេះប្រើវិធីសាស្ត្រ តិចនិច និងឧបាយកលក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ឧទាហរណ៍៖ អនីតិជនម្នាក់ដែលមានអាយុ ១៥ (ដប់ប្រាំ) ឆ្នាំបានប្រើឧបាយកលទុច្ចរិតទៅលើអនីតិជនម្នាក់ទៀតដើម្បីឱ្យអនីតិជននោះប្រគល់នូវវត្ថុមានតម្លៃ ដូចជា ក្រវិល ខ្សែករ ឱ្យមកខ្លួន ដែលនេះជាសញ្ញាមួយសម្រាប់កំណត់បទល្មើសនៃបទឆបោក ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៧៧។

**ពេលវេលាប្រព្រឹត្តបទល្មើស**

ពេលវេលាប្រព្រឹត្តបទល្មើសអាចជាពេលមួយ ឬរយៈពេលមួយជាកំណត់ដែលអំពើល្មើសច្បាប់ព្រហ្មទណ្ឌបានស្តែងចេញមកខាងក្រៅ។ មានន័យថាពេលវេលាប្រព្រឹត្តបទល្មើស ដែលបានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌក៏ដូចជាធាតុផ្សំយ៉ាងសំខាន់ដើម្បីកំណត់នូវបទល្មើសផ្ទាល់តែម្តង។

ឧទាហរណ៍៖ ការធ្វើសកម្មភាពលួចដោយអនីតិជន នៅពេលយប់។

**ទីកន្លែងប្រព្រឹត្តបទល្មើស**

ទាក់ទងនឹងទីកន្លែងប្រព្រឹត្តបទល្មើស សំដៅដល់ទីតាំង ឬដែនដីមួយដែលបានប្រព្រឹត្តបទល្មើស ឬសកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់សង្គម តាំងពីពេលចាប់ផ្តើម រហូតដល់បញ្ចប់ ឬជាដែនដីមួយ ទីតាំងមួយ

[12] មេរៀនសាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រ៧៣ ដល់ ៧៥

ដែលច្បាប់ព្រហ្មទណ្ឌបានចែងថា វាជាទីតាំងដែលសម្រាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ។

ឧទាហរណ៍៖ អនីតិជនឈ្មោះ គ បានចូលលួច គាស់ផ្ទះ លោក ក ដែលមានទីតាំងស្ថិតនៅខណ្ឌចំការមន។

**ទិដ្ឋភាពនានាជុំវិញបទល្មើស**

ទិដ្ឋភាពនានាជុំវិញបទល្មើស ជាការសរុបនូវរាល់ករណីលម្អិតនានាផ្នែកសត្យានុម័តជុំវិញការប្រព្រឹត្ត បទល្មើសដែលមានឥទ្ធិពលទៅលើកម្រិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស។ ទិដ្ឋភាពជុំវិញនៃបទល្មើសទាំងនោះត្រូវបានច្បាប់បញ្ញត្តិថាជាសញ្ញានៃស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសផងដែរ។

ឧទាហរណ៍៖ អនីតិជនអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ម្នាក់បានប្រព្រឹត្តបទល្មើសមនុស្សឃាតដោយអចេតនាដោយសារកាលៈទេសៈ ឬដោយសារតែស្ថានភាពចិត្តសាស្ត្ររបស់អនីតិជននោះបានក្លាយជាសញ្ញាណនៃការទទួលបាននូវស្ថានសម្រាលទោស[13] ព្រោះថា អ្នកដែលបានប្រព្រឹត្តបទល្មើសនោះ ជាអនីតិជនដែលពុំទាន់មានសមត្ថភាពយល់ដឹងបានច្បាស់លាស់ទៅលើអំពើរបស់ខ្លួនដូចទៅនឹងមនុស្សពេញវ័យដែលយើងហៅថា នីតិជននោះទេ។

***សូមបញ្ជាក់៖*** ថ្វីត្បិតតែកត្តារួមផ្សំទាំងអស់នោះ វាស្ថិតនៅក្នុងផ្នែកសត្យានុម័តនៃបទល្មើសក៏ពិតមែន ប៉ុន្តែក្នុងករណីជាច្រើនដែលកត្តាទាំងអស់នោះពុំមានឥទ្ធិពលផ្តល់ចរិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើសឡើយ។

អាស្រ័យដោយហេតុនេះហើយទើបបានជា នីតិករពុំបានធ្វើការបញ្ចូលទៅកត្តារួមផ្សំនៃ បទល្មើសជាក់ស្តែងពោលគឺ ពុំត្រូវបានចែងលម្អិតនៅក្នុងបទដ្ឋានគតិយុត្តផ្នែកដោយឡែក (ផ្នែកបទល្មើស)។ ផ្ទុយមកវិញ ក្នុងករណីដែលកត្តាដែលបានរៀបរាប់ខាងលើនោះមានឥទ្ធិពលដល់ចរិតគ្រោះថ្នាក់ដល់សង្គម និងបទល្មើសមានន័យថា នៅពេលដែលស្ថានភាពទាំងនេះវាមានអត្ថន័យសំខាន់ចំពោះបណ្តាបទល្មើសណាមួយនោះវាជាសញ្ញាពិសេសសម្រាប់បទល្មើសនោះនៅពេលដែលត្រូវបានដាក់បញ្ចូលទៅកត្តារួមផ្សំនៃបទល្មើសជាក់ស្តែង ក្រោយពីបានដាក់បញ្ចូលហើយវានឹងក្លាយជាសញ្ញាដែលមានលក្ខណៈដាច់ខាតសម្រាប់កំណត់នូវបទល្មើសនោះតែម្តង។

លក្ខណៈដាច់ខាតទាំងនេះអាចជាសញ្ញាសម្រាប់កំណត់អំពីទោស កំណត់អំពីស្ថានទម្ងន់ទោស រួមទាំងកំណត់អំពីព្រំដែននៃទណ្ឌកម្មផងដែរ។ ក្នុងន័យនេះ ដើម្បីអាចកំណត់ទណ្ឌកម្មទៅលើអនីតិជនបាន គឺត្រូវធ្វើការពិចារណាឱ្យបានច្បាស់លាស់ទាក់ទងនឹងកាលៈទេសៈនៃបទល្មើសដូចដែលបានលើកឡើងខាងលើមុននឹងសម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះអនីតិជន។

[13] មាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

## ២.៦. លក្ខខណ្ឌនៃបុគ្គលិកលក្ខណៈ

បុគ្គលិកលក្ខណៈរបស់អនីតិជនសំដៅដល់ អាយុ កម្រិតនៃការយល់ដឹង បញ្ញា អត្តចរិត របស់អនីតិជន ដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត [14] ។ ក្នុងករណីដែលតុលាការសម្រេចដាក់ទណ្ឌកម្មលើអនីតិជន ត្រូវពិចារណាលើ អាយុ កម្រិតនៃការយល់ដឹង របស់អនីតិជននោះជាមុនសិន។ បន្ថែមពីនេះ យោងតាមមាត្រា៦៤ "ចំណុច គ" នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជនបានចែងថា បុគ្គលិកលក្ខណៈរបស់អនីតិជនមានដូចជា អាយុកម្រិតនៃការយល់ដឹង និងអត្តចរិតរបស់អនីតិជននោះ។ ត្រង់ចំណុចនេះដែរយើងឃើញថា នីតិករ មានចេតនាចង្អុលបង្ហាញឱ្យឃើញយ៉ាងជាក់លាក់អំពីអត្ថន័យនៃពាក្យបុគ្គលិកលក្ខណៈនេះផ្ទាល់តែម្តង គឺក្នុងគោលដៅដើម្បីបញ្ចៀសកុំឱ្យអ្នកសិក្សា ឬអ្នកអនុវត្តច្បាប់មានការភណ្ឌច្រឡំទៅលើអត្ថន័យនៃពាក្យពេចន៍នេះហើយព្យាយាមធ្វើការបកស្រាយប្រាសចាកពីគោលគំនិតដើមរបស់ច្បាប់។ ទាញចេញពីខ្លឹមសារខាងលើអាចឱ្យគេយល់បានថា បុគ្គលិកលក្ខណៈរបស់អនីតិជនសំដៅលើសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននោះផ្ទាល់តែម្តងចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

ដូច្នេះតុលាការមុននឹងធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបាន គឺត្រូវពិចារណាអំពីការរីកចម្រើននៃរូបរាងកាយរបស់អនីតិជន ប្រាជ្ញា ស្មារតី និងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់អនីតិជននោះជាមុនសិន។ ដើម្បីអាចវាយតម្លៃបានថា អនីតិជនអាចយល់ដឹង ឬមិនអាចយល់ដឹងបាន គឺអាចវាយតម្លៃបានតាមរយៈពីររបប ដែលរួមមានរបបបែបធម្មជាតិ និងរបបបែបវេជ្ជសាស្ត្រ[15]។

**របបតាមបែបធម្មជាតិ**

ស្ថិតក្នុងរបបតាមបែបធម្មជាតិ គឺគេពិចារណាទៅលើផ្នែកសរីរាង្គដោយពិនិត្យទៅលើអាយុរបស់ជននោះរួមទាំងចំណេះដឹងរបស់គាត់ផងដែរ។ ការពិចារណានេះ គឺផ្អែកទៅលើការរីកចម្រើននៃផ្នែកសរីរាង្គដែលពាក់ព័ន្ធរួមមានបញ្ហាសរសៃប្រសាទ និងរាងកាយរបស់អនីតិជននេះឯង ពោលគឺ វ័យអនីតិជន គឺជាវ័យ ដែលកំពុងផ្លាស់ប្តូរទាំងរូបរាងកាយ ខួរក្បាល និងអារម្មណ៍ចិត្តគំនិត[16]។ អាស្រ័យហេតុនេះទើបក្នុងច្បាប់សន្មត់ថា អាយុ ១៤ (ដប់បួន) ឆ្នាំគឺអាចមានសមត្ថភាពយល់ដឹងបានខ្លះៗ ហើយដោយសារតែស្ថានភាពនៃការរីកចម្រើនផ្នែកខាងរូបរាងកាយនៃមនុស្ស និងការទទួលនូវឥទ្ធិពលផ្នែកខាងធម្មជាតិរួមមានដូចជា ពាក់ព័ន្ធជាមួយនឹងអាកាសធាតុសេដ្ឋកិច្ច និងសង្គមនេះឯង។

---

[14] មាត្រា៦៤ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[15] *សូមមើល* មេរៀន នីតិព្រហ្មទណ្ឌ, សាស្ត្រាចារ្យ ហ៊ី សោភា, ទំព័រ ៨០ ដល់ ៨៣

[16] *សូមមើល* មេរៀនចិត្តវិទ្យាវ័យជំទង់ គឹម ចាន់ណា, ឆ្នាំ២០១០

ក្នុងករណីនេះទើបក្រមព្រហ្មទណ្ឌ បានកំណត់ថាប្រសិនជាអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ ទើបចៅក្រមអាចប្រកាសផ្តន្ទាទោសទៅលើអនីតិនោះបាន។

**របបតាមវេជ្ជសាស្ត្រ**

ស្ថាននៅក្នុងរបបនេះគេត្រូវពិចារណាទៅលើស្ថានភាពនៃជម្ងឺដែលនាំឱ្យអនីតិជននោះ មិនអាចយល់ដឹងបានដូចជា មនុស្សដែលស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំ។ មានន័យថា ជនដែលមានជម្ងឺសរសៃប្រសាទជាប្រចាំ ឬក៏ខ្សោយសតិបញ្ញា ឬជម្ងឺផ្សេងៗទៀតដែលបណ្តាលឱ្យមានភាពរឹករវក្នុងសកម្មភាពនៃសរសៃប្រសាទនេះតែម្តង។ ជម្ងឺសរសៃប្រសាទជាប្រចាំ (វិកលចរិត) អាចមានរូបភាពជាក់ស្តែងខុសៗគ្នាដែលនាំមកនូវលទ្ធផលសភាពជាប្រចាំ ឬយូរអង្វែង ហើយចំពោះសភាពរឹករវក្នុងសតិបញ្ញាជាបណ្តោះអាសន្នស្តែងឡើងភ្លាមៗក្នុងរយៈពេលខ្លីធ្វើឱ្យមានការបាត់បង់នូវការយល់ដឹងទាំងស្រុង ឬមួយផ្នែកនៃករណីដែលកើតឡើងក្នុងពេលវេលាដែលជម្ងឺបានបញ្ចេញសកម្មភាព។ រីឯស្ថានភាពជម្ងឺផ្សេងៗ គឺជាប្រភេទជម្ងឺដែលពុំមែនកើតឡើងក្នុងប្រព័ន្ធសរសៃប្រសាទជាប្រចាំ ឬម្តងម្កាលឡើយ អាចសំដៅលើស្ថានភាពជម្ងឺប្រហាក់ប្រហែលទៅនឹងស្ថានភាពជម្ងឺសរសៃប្រសាទដូចជាករណីប្រើប្រាស់អាភៀន ឬថ្នាំញៀនជាដើម (ដល់ពេលដែលត្រូវជក់ ឬចាក់សារធាតុញៀន)។

ដោយស្ថិតក្នុងករណីខាងលើដែរ ប្រសិនបើរកឃើញថា អនីតិជន នោះមានបញ្ហាស្មារតី ដូចជាស្ថិតក្នុងស្ថានភាពវិបល្លាសជាដើម គឺតុលាការត្រូវពិចារណាឱ្យអនីតិជនរួចផុតពីការទទួលទោស ផ្ទុយមកវិញការដែលរកឃើញថាអនីតិជននោះបានប្រើប្រាស់អាភៀន ឬថ្នាំញៀននោះ គឺតុលាការអាចពិចារណាចាត់វិធានការផ្សេងៗ ឬក៏សម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនតែម្តង។

ត្រឡប់មកវិញថា លក្ខខណ្ឌដែលបានរៀបរាប់ខាងលើនេះ គឺជាលក្ខខណ្ឌដែលតុលាការលើកយកមកពិចារណា ក៏ដូចជាពិនិត្យថ្លឹងថ្លែងក្នុងករណីដែលមានបទល្មើសប្រព្រឹត្តឡើងដោយអនីតិជន។

# ជំពូកទី២
# ការទទួលបានយុត្តិធម៌នៅគ្រប់
# ដំណាក់កាលនៃនីតិវិធីសម្រាប់កុមារ

# ជំពូកទី២
# ការទទួលបានយុត្តិធម៌នៅគ្រប់ដំណាក់កាលនៃនីតិវិធីសម្រាប់កុមារ

ទាក់ទងនឹងនីតិវិធីដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ក៏មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនផងដែរ។ ដោយហេតុថានីតិវិធីនេះតម្រូវឱ្យមានការឆ្លងកាត់ពីដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះធ្វើឡើងនៅក្នុងសវនាការជាអាទិ៍។ នៅគ្រប់ដំណាក់កាលទាំងអស់ ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ និងត្រូវគិតគូរពីឧត្តមប្រយោជន៍របស់អនីតិជនជាទីបំផុត ដែលតាមរយៈនេះដែរ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានចែងទាក់ទងនឹងនីតិវិធី ដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន មុនពេលឈានទៅដល់ការសម្រេចដាក់ទោសអនីតិជន។ បានជាច្បាប់យកចិត្តទុកដាក់ចំពោះ អនីតិជន ព្រោះថាអនីតិជន គឺជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតឡើយ ហេតុដូច្នេះត្រង់ចំណុចនេះហើយទើបច្បាប់បានពិចារណាទៅលើការយល់ដឹងរបស់ពួកគេ ទើបតម្រូវឱ្យមាននូវការអនុវត្តនីតិវិធីយ៉ាងពិសេសមួយចំនួនចំពោះអនីតិជននេះឯង។

## ផ្នែកទី១ ដំណាក់កាលស៊ើបអង្កេតដោយនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាភ្នាក់ងារដែលមានសមត្ថកិច្ចដំបូងគេបង្អស់ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស ហើយមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចស៊ើបអង្កេតលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលពាក់ព័ន្ធទៅនឹងជនសង្ស័យដែលជាអនីតិជន[17]។ រាល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងក្រោមការដឹកនាំ និងសម្របសម្រួលសកម្មភាពដោយព្រះរាជអាជ្ញា[18]។ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចក្នុងការចាប់ខ្លួន ឆែកឆេរខ្លួន ឬឃាត់ខ្លួន អនីតិជនដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសពីកន្លែងកើតហេតុមកអង្គភាពនគរបាលយុត្តិធម៌បាន ម្យ៉ាងទៀតនៅក្នុងដំណើរការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីកំណត់ពីប្រភេទនៃបទល្មើស អត្តសញ្ញាណ ប្រមូលភស្តុតាងដែលពាក់ព័ន្ធដើម្បីឃាត់ខ្លួន ឬចាប់ខ្លួនអ្នកប្រព្រឹត្តក្នុងករណីណាដែលចាំបាច់។ ទន្ទឹមនឹងនេះដែរ ការស៊ើបអង្កេតដែលទាក់ទងនឹងរឿងក្តីអនីតិជន គឺត្រូវធ្វើឡើងដោយមន្ត្រីជំនាញ ដែលបានទទួលបានការបណ្តុះបណ្តាលពីច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិកុមារក្នុងគោលដៅ ដើម្បីអាចឱ្យការអនុវត្តនោះប្រព្រឹត្តទៅដោយមានលក្ខណៈនីតិវិធីកុមារមេត្រី។

ដូចនេះការស៊ើបអង្កេតត្រូវបង្ហាញ និងប្រព្រឹត្តទៅតាមដំណាក់កាលនៃនីតិវិធីដូចខាងក្រោម៖

[17] មាត្រា ១២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[18] មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ១.១.ការចាប់ខ្លួន

ក្នុងករណីពិសេសនៃការចាប់ខ្លួន គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការចាប់ខ្លួនបានចំពោះតែអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមជាក់ស្តែងតែប៉ុណ្ណោះ[19]។ ទាក់ទងនឹងការអនុវត្តការចាប់ខ្លួនអនីតិជន នគរបាលយុត្តិធម៌ត្រូវជៀសវាងដាច់ខាតក្នុងការធ្វើឱ្យអនីតិជនអាម៉ាសមុខ និងបាត់បង់សេចក្តីថ្លៃថ្នូរដល់អនីតិជន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រើប្រាស់កម្លាំងក្នុងកម្រិតស្រាលបំផុតតាមដែលអាចធ្វើទៅបាន និងជៀសវាងនូវការប្រើប្រាស់ឧបករណ៍មួយចំនួនដែលមានលក្ខណៈបង្ខំដូចជាដាក់ខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែល ។ ម្យ៉ាងទៀត នគរបាលយុត្តិធម៌ត្រូវតែបញ្ជូនអនីតិជនទៅឱ្យផ្នែក ឬអង្គភាពនគរបាលយុត្តិធម៌ជំនាញទាក់ទងនឹងអនីតិជនដែលនៅជិតបំផុត ហើយមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរទៅលើខ្លួនបុគ្គលដែលជាអនីតិជនដែលមានភេទដូចគ្នាតែប៉ុណ្ណោះ ក្នុងករណីដែលគ្មានជម្រើសទេមន្ត្រីនគរបាលអាចអនុញ្ញាត និងធ្វើការចាត់តាំងនីតិជនដែលមានភេទដូចគ្នាណាម្នាក់មកធ្វើការឆែកឆេរលើអនីតិជន តែត្រូវប្រាកដថាអ្នកដែលធ្វើការឆែកឆេរនោះមិនមែនជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំធ្លាប់មានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីដែលមិនអាចជៀសវាងបាន [20] ។ បន្ទាប់ពីធ្វើការចាប់ខ្លួនអនីតិជនភ្លាមមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់នូវសិទ្ធិក្នុងនីតិវិធីមួយចំនួនទៅកាន់អនីតិជន។

## ១.២. ការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនបានប្រសិនបើជឿជាក់ថា អនីតិជនអាចរត់គេចខ្លួន និងបង្កផលប៉ះពាល់ទៅដល់ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ។ ក្នុងករណីដែលអនីតិជន មានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចធ្វើការឃាត់ខ្លួនអនីតិជនបានឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅកាន់តំណាងដែលច្បាប់បានកំណត់។

ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងដំណើរការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងដើម្បីការពារសុវត្ថិភាពអនីតិជននោះ។ ទាក់ទងនឹង

[19] មាត្រា ១៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[20] មាត្រា ១៦ នៃព្រះរាជក្រមយោងខាងលើ

ការឃាត់ខ្លួន អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៦ (ដប់ប្រាំមួយ) គឺអាចធ្វើការឃាត់ខ្លួនបានក្នុងករណីដែលអនីតិជនរូបនោះមានចេតនាក្នុងការប្រព្រឹត្តបទល្មើស។

ជាងនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬជួយឱ្យមានការប្រព្រឹត្តបទល្មើស ហើយត្រូវរាយការណ៍ភ្លាមៗជូនទៅព្រះរាជអាជ្ញា ឬដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញាពោលគឺ រាល់ការឃាត់ខ្លួនអនីតិជនត្រូវរាយការណ៍ទៅព្រះរាជអាជ្ញាភ្លាម[21]។ ចំពោះការឃាត់ខ្លួនអនីតិជន ត្រូវដាក់ដោយឡែកពីនីតិជន និងទៅតាមភេទ ហើយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធានាឱ្យបាននូវសុវត្ថិភាពរបស់អនីតិជន ដោយមិនត្រូវឱ្យអនីតិជនទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុត ការបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់អនីតិជនឡើយ។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌មានបំណងចង់យកអនីតិជនមកដាក់ជាជួរបាន លុះត្រាតែមានការយល់ព្រមពីសាមីខ្លួនដែលជាអនីតិជនផ្ទាល់ ឬអាចពិគ្រោះយោបល់ជាមួយនឹងមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនជាមុនសិន ហើយក្នុងករណីនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុក ត្រូវធ្វើកំណត់ហេតុ ជាលាយលក្ខណ៍អក្សរ និងផ្តិតស្រាមដៃ។

ជាគោលការណ៍ រយៈពេលនៃការឃាត់ខ្លួនអនីតិជនមិនអាចពន្យាពេលបានឡើយ ហើយការឃាត់ខ្លួនត្រូវតែអនុវត្តដោយជាក់លាក់តាមការកំណត់ដូចខាងក្រោម[22]៖

១. អនីតិជនដែលបានប្រព្រឹត្តបទមជ្ឈឹម មានអាយុចាប់ពី ១៤ (ដប់បួន ) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនឱ្យហួសពីរយៈពេល ២៤ម៉ោងឡើយ។ អនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនឱ្យហួសពីរយៈពេល ៣៦ ម៉ោងឡើយ។

២. អនីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនឱ្យហួសពីរយៈពេល ៣៦ ម៉ោងឡើយ។ អនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវឃាត់ឱ្យហួសពីរយៈពេល ៤៨ ម៉ោងឡើយ។

សូមបញ្ជាក់ដែរថា ថិរវេលានៃការឃាត់ខ្លួនអនីតិជនខាងលើ ត្រូវគិតចាប់ពីពេលដែលបានបញ្ជូនខ្លួនអនីតិជននោះមកដល់អង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ។

[21] មាត្រា ១៧ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា ៩៦ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ១.៣. ភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការជូនដំណឹង

ក្រោយពីបាននាំខ្លួនអនីតិជនមកដល់អង្គភាពនគរបាលយុត្តិធម៌ហើយ មន្ត្រីដែលទទួលបន្ទុកអនីតិជនត្រូវធ្វើការជូនដំណឹងអំពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជនទៅដល់បុគ្គល ដែលមានកាតព្វកិច្ចពាក់ព័ន្ធនឹងអនីតិជនឱ្យបានឆាប់ និងក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន។

តាមរយៈនេះដែរ បុគ្គលដែលពាក់ព័ន្ធនឹងអនីតិជនមានដូចខាងក្រោម[23]៖

- អ្នកតំណាងដែលច្បាប់បានកំណត់ហើយក្នុងករណីដែលមិនអាចទាក់ទងបានទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងរកអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកជ្រើសរើសដោយមានការយល់ព្រមច្បាស់លាស់ពីអនីតិជន
- ភ្នាក់ងារសង្គមកិច្ច ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជន
- មេធាវីរបស់អនីតិជន ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឱ្យអនីតិជនធ្វើការជ្រើសរើស ឬអាចជ្រើសតាំងមេធាវីឱ្យអនីតិជន ប្រសិនបើអនីតិជននោះគ្មានមេធាវី
- អ្នកបកប្រែភាសា ក្នុងករណីដែលអនីតិជនមិនមែនជាជនជាតិខ្មែរ ឬមិនចេះភាសាខ្មែរ។

ចំពោះការជូនដំណឹងនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន ប្រភេទនៃបទល្មើស ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ និងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវី អ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី[24]។

## ១.៤.ការស្តាប់ចម្លើយ

នៅមុនពេលចាប់ផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនពីសិទ្ធិជាមូលដ្ឋាន និងសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវីដូចនៅនឹងនីតិវិធីអនុវត្តចំពោះបុគ្គលដែលជានីតិជនផងដែរ[25]។ ការស្តាប់ចម្លើយអនីតិជន គឺត្រូវធ្វើឡើងជាលក្ខណៈឯកជន និងជាការសម្ងាត់ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី និងចាំបាច់ត្រូវមានមេធាវី ហើយចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចមានសិទ្ធិក្នុងការផ្តល់ជំនួយដល់អនីតិជន និងចូលរួមក្នុងការស្តាប់ចម្លើយអនីតិ

[23] មាត្រា ១៨ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[24] មាត្រា ១៨ នៃព្រះរាជក្រមយោងខាងលើ

[25] មាត្រា ២១ កថាខណ្ឌទី១ នៃព្រះរាជក្រមយោងខាងលើ

ជនបានផងដែរ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចបដិសេធពីការចូលរួមរបស់អ្នកទាំងនោះបានប្រសិនបើយល់ថា វត្តមានរបស់អ្នកទាំងនោះអាចធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន[26]។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជនផ្ទាល់ ហើយនៅពេលដែលមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច ដែលបានអវត្តមាននៅក្នុងពេលស្តាប់ចម្លើយ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមាន[27]។ បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយ អនីតិជន មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច មានសិទ្ធិក្នុងការអានកំណត់ហេតុស្តាប់ចម្លើយ បន្ថែមពីនេះអនីតិជនក៏អាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយនៅលើកំណត់ហេតុស្តាប់ចម្លើយបានមុននឹងធ្វើការចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុដែលបានចុះនិទ្ទេសនោះ បន្ទាប់មកទៀតគឺអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវតែចុះហត្ថលខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះផងដែរ[28]។

ក្រោយពីបានធ្វើកំណត់ហេតុ និងពិនិត្យផ្ទៀងផ្ទាត់ដោយអនីតិជនរួចហើយមន្ត្រីនគរបាលយុត្តិធម៌ជំនាញបញ្ចប់នីតិវិធីរបស់ខ្លួនរួចបញ្ជូនសំណុំរឿង ឯកសារ ភស្តុតាងផ្សេងៗ ដែលពាក់ព័ន្ធព្រមអនីតិជនទៅកាន់តំណាងអយ្យការឱ្យបានឆាប់បំផុត ស្របតាមបញ្ញត្តិមាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ១.៥. បញ្ជីស្តីពីការឃាត់ខ្លួន និងកំណត់ហេតុស្តីពីការឃាត់ខ្លួន

ជាគោលការណ៍រាល់ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចុះបញ្ជីស្តីពីការឃាត់ខ្លួន និងកំណត់ហេតុនៃការឃាត់ខ្លួន។ ក្នុងករណីដែលមេធាវីរបស់អនីតិជនស្នើសុំឱ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់នូវកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្តល់ច្បាប់ចម្លងនៃកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនឱ្យទៅកាន់មេធាវី។ ជាទូទៅនៅតាមអង្គភាពនគរបាលយុត្តិធម៌នីមួយៗត្រូវមានបញ្ជីដោយឡែកស្តីពីការឃាត់ខ្លួនអនីតិជន ហើយចំនុចសំខាន់ៗដែលត្រូវចុះក្នុងបញ្ជីឃាត់ខ្លួនរួមមាន ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន រួមជាមួយនឹងអត្តសញ្ញាណរបស់បុគ្គលដែលបានឃាត់ខ្លួន ក៏ដូចជាថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមធ្វើការឃាត់ខ្លួន និងឈ្មោះ ឋានៈរបស់ចៅក្រមដែលអនុញ្ញាតឱ្យឃាត់ខ្លួន និងឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលដែលត្រូវឃាត់ខ្លួន និងប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការពេលផុតកំណត់

[26] មាត្រា ២១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[27] មាត្រា ២១ កថាខណ្ឌទី៣ នៃ នៃព្រះរាជក្រមយោងខាងលើ

[28] មាត្រា ២១ នៃព្រះរាជក្រមយោងខាងលើ

ការឃាត់ខ្លួនហើយចំពោះបញ្ជីនេះ ត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការទៅតាមតម្រូវការ[29]។

## ផ្នែកទី២ ដំណាក់កាលអយ្យការ និងការចោទប្រកាន់

បន្ទាប់ពីទទួលបានសំណុំរឿងបន្តពីមន្ត្រីនគរបាលយុត្តិធម៌រួច តំណាងអយ្យការត្រូវបន្តពិនិត្យសំណុំឯកសារ និងបណ្តឹងដែលបានទទួលពីមន្ត្រីនគរបាលមកពិនិត្យផ្ទៀងផ្ទាត់ឱ្យបានច្បាស់អំពីអាយុរបស់អនីតិជនមុននឹងសម្រេចចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងបញ្ជូនអនីតិជននោះទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាលវិញហើយព្រះរាជអាជ្ញាក៏អាចបញ្ជូនអនីតិជនទៅកាន់មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របតាមសុខុមាលភាព និងស្ថានភាពរបស់អនីតិជនបានដែរ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងការថែទាំជាអាទិ៍។ យោងតាមការកំណត់នៃច្បាប់តំណាងអយ្យការដែលទទួលបន្ទុករឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទបញ្ញត្តិផ្សេងៗទៀតដែលទាក់ទងនឹងយុត្តិធម៌អនីតិជន។

### ២.១.ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

ស្ថិតនៅក្នុងដំណាក់កាលអយ្យការ ជាបឋមគឺត្រូវពិនិត្យទៅលើអាយុអនីតិជនឱ្យបានច្បាស់លាស់ដើម្បីអាចបញ្ជាក់ថា អនីតិជនពិតជាមានអាយុក្រោម ឬលើស ១៤ (ដប់បួន) ឆ្នាំ ដែលអាចឱ្យមកទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ទាក់ទងនឹងការបញ្ជាក់អាយុរបស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសនេះផងដែរតំណាងអយ្យការត្រូវពិនិត្យទៅលើឯកសារផ្លូវការមួយចំនួនដែលអាចជឿទុកចិត្តបាន ដែលឯកសារទាំងអស់នោះអាចជាសំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬឯកសារផ្សេងៗទៀតដែលមានទាក់ទងនឹងការកំណត់អំពីអាយុរបស់អនីតិជន។

ស្របតាមស្មារតីនៃ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏បានផ្តល់ដំណោះស្រាយក្នុងការកំណត់អាយុរបស់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការផងដែរ។ យោងតាមមាត្រា ៩ នៃច្បាប់នេះ បានចែងអំពី ***ការកំណត់អាយុ*** ថាភស្តុតាងនៃអាយុអនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងៗដែលអាចបញ្ជាក់បានអំពីកំណើត[30]។ ដោយឡែកក្នុងករណីពុំមានឯកសារ ឬនៅមានវិមតិសង្ស័យពាក់ព័ន្ធនឹងអាយុរបស់អនីតិជន តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតជាបឋមឱ្យបានឆាប់រហ័សបំផុតទាក់ទងនឹងការស្វែងរកឱ្យបានច្បាស់លាស់អំពីអាយុរបស់អនីតិជន ហើយប្រសិនបើការស៊ើបអង្កេតនោះមិនអាចឈានដល់ការសន្និដ្ឋាន

[29] មាត្រា ១០១ នៃនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា ៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរ[31]។

ក្នុងករណីដែលតំណាងអយ្យការពិនិត្យឃើញថា អនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំគិតចាប់ពីថ្ងៃដែលគេត្រូវបានសង្ស័យថាអនីតិជននោះបានប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការ និងប្រគល់អនីតិជននោះទៅកាន់តំណាងដែលច្បាប់បានកំណត់[32]។

## ២.២.ការស្តាប់ចម្លើយអនីតិជន

បន្ទាប់ពីទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ និងផ្ទៀងផ្ទាត់លើអាយុរបស់អនីតិជនរួចរាល់ តំណាងអយ្យការនឹងធ្វើការសួរចម្លើយរបស់អនីតិជននោះ ហើយមុននឹងធ្វើការសាកសួរអនីតិជននោះទៀតសោត តំណាងអយ្យការត្រូវតែជូនដំណឹងទៅកាន់ឪពុក ម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលរបស់អនីតិជន។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកដែលបានចូលរួមស្តាប់ចម្លើយអំពីសិទ្ធិដែលអនីតិជនទទួលបាន ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដោយប្រើប្រាស់ភាសា អាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុននឹងធ្វើការស្តាប់ចម្លើយ។ ក្នុងការស្តាប់ចម្លើយរបស់អនីតិជន ត្រូវធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ហើយរាល់ការស្តាប់ចម្លើយ ត្រូវមានវត្តមានរបស់មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច ឬអ្នកទំនុកបម្រុងរបស់អនីតិជន ក្នុងនោះដែរបើសិនជាគ្មានការជ្រើសរើស ព្រះរាជអាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឱ្យអនីតិជននោះ[33]។

ក្នុងករណីអ្នកតំណាងដែលបានកំណត់ ធ្វើឱ្យប៉ះពាល់ ឬធ្វើឱ្យខូចឧត្តមប្រយោជន៍របស់អនីតិជន ព្រះរាជអាជ្ញាមានសិទ្ធិមិនអនុញ្ញាតឱ្យអ្នកតំណាងដែលបានកំណត់នោះ មិនអាចចូលរួមក្នុងការស្តាប់ចម្លើយបាន ប៉ុន្តែការមិនអនុញ្ញាតនេះដែរ គឺត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជនផងដែរ ហើយប្រសិនបើការស្តាប់នេះ អវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។ បន្ទាប់ពីស្តាប់ចប់ភ្លាម អនីតិជនមានសិទ្ធិក្នុងការអានកំណត់ហេតុស្តាប់ចម្លើយនោះ តែបើអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបានទេ គឺក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានទូវកំណត់ហេតុស្តាប់ចម្លើយនោះឱ្យអនីតិជនស្តាប់ ហើយអនីតិជនអាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយលើចម្លើយបានមុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ[34]។ ក្នុងនោះដែរព្រះរាជអាជ្ញាត្រូវអនុញ្ញាតឱ្យមេធាវី ឬឪពុកម្តាយរបស់អនីតិជន ឬអ្នកអាព្យាបាលសម្រាប់អនីតិជន ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គម

[31] មាត្រា ២៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[32] មាត្រា ២៧ កថាខណ្ឌទី១ នៃព្រះរាជក្រមយោងខាងលើ

[33] មាត្រា ២៦ កថាខណ្ឌទី១ នៃព្រះរាជក្រមយោងខាងលើ

[34] មាត្រា ២៦ កថាខណ្ឌទី៤ នៃព្រះរាជក្រមយោងខាងលើ

កិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន[35]។ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ហើយក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ គឺព្រះរាជអាជ្ញាត្រូវត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ[36]។

ក្នុងនោះដែរតំណាងអយ្យការក៏មានអំណាចក្នុងការបង្វែរ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបានប្រព្រឹត្តបទលហុ ឬបទមជ្ឈឹម។ ចំពោះការបង្វែរនេះផងដែរ ព្រះរាជអាជ្ញាត្រូវពិចារណាទៅលើការបង្វែរដែលបានកំណត់ក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជនក្នុងជំពូកទី១០ ហើយព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច រួចបង្គាប់ប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្តដើម្បីទទួលការគ្រប់គ្រង និងថែរក្សាអនីតិជន។

## ២.៣. ការបង្វែរក្នុងដំណាក់កាលអង្គការអយ្យការ

ក្នុងដំណាក់កាលអយ្យការក្រោយពីបានស្តាប់ចម្លើយរួចហើយ ក្នុងករណីដែលពិនិត្យឃើញថា លក្ខខណ្ឌអប្បបរមានៃការបង្វែរ និងលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ ត្រូវបានបំពេញនោះព្រះរាជអាជ្ញាអាចធ្វើការពិចារណាជាបឋមទៅលើការផ្ទេររឿងក្តីនេះចេញពីនីតិវិធីបានដោយអនុវត្តទៅតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលកំណត់ពីនីតិវិធីនៃការបង្វែរ និងអ្នកទទួលបន្ទុកក្នុងការបង្វែរ។

ការបង្វែរ គឺជាការផ្ទេររឿងក្តីកម្រិតស្រាល ឬមិនធ្ងន់ធ្ងរ (បទលហុ-បទមជ្ឈឹម) ចេញពីនីតិវិធីតុលាការព្រហ្មទណ្ឌដោយបញ្ជូនអនីតិជននោះទៅរកជំនួយ ការគាំទ្រពីសហគមន៍ ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស[37]។ ជាមួយគ្នានេះដែរអាជ្ញាធរដែលមាននូវសិទ្ធិអំណាចក្នុងការបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[38]។

### ២.៣.១. លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ដើម្បីអាចធ្វើការពិចារណាទៅលើការបង្វែរបាន គឺត្រូវគោរពទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរមួយចំនួនដូចជា៖

- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន
- អនីតិជនបានសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត និងមានការសុំទោសដល់ជនរងគ្រោះ

---

[35] មាត្រា ២៦ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[36] មាត្រា ២៦ កថាខណ្ឌទី៦ នៃព្រះរាជក្រមយោងខាងលើ

[37] មាត្រា ៦០ នៃព្រះរាជក្រមយោងខាងលើ, និងបទបង្ហាញស្តីពី "ការបង្វែរ" របស់លោកមេធាវី អុប វិបុល ថ្ងៃទី១ និងទី២

[38] មាត្រា ៦១ នៃព្រះរាជក្រមយោងខាងលើ

- បទល្មើសដែលអនីតិជនបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម
- អនីតិជនយល់ព្រមឱ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវី អំពីសិទ្ធិរបស់អនីតិជន និងពិចារណាអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ[39]។

**២.៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការបង្វែរ**

អាជ្ញាធរដែលទទួលបន្ទុកបង្វែរ មុននឹងសម្រេចថាបង្វែរ ឬមិនបង្វែរ គឺត្រូវពិចារណាទៅលើកត្តាមួយចំនួនផងដែរបើទោះបីជាមានការបំពេញតាមលក្ខខណ្ឌខាងលើបានត្រឹមត្រូវក៏ដោយ កត្តាមួយចំនួនដែលច្បាប់បានកំណត់នោះរួមមាន កាលៈទេសៈនៃបទល្មើស ស្ថានភាពនៃបទល្មើស បុគ្គលិកលក្ខណៈរបស់អនីតិជន ដែលគេសម្គាល់លើកម្រិតនៃការយល់ដឹង បញ្ញាស្មារតី អាយុ និងអត្តចរិតរបស់អនីតិជន ម្យ៉ាងទៀតគឺការទទួលរងឥទ្ធិពល ពីគ្រួសារ និងបរិយាកាសជុំវិញនៃការរស់នៅរបស់អនីតិជន បូករួមជាមួយនឹងសុវត្ថិភាព និងព្យសនកម្មជនរងគ្រោះ សហគមន៍ និងសង្គមផងដែរ[40]។

**២.៣.៣. នីតិវិធីក្នុងការបង្វែរ**

នៅពេលដែលរៀបចំផែនការបង្វែរ ព្រះរាជអាជ្ញាត្រូវប្រគល់អនីតិជនទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំដោយរង់ចាំអនុវត្តផែនការបង្វែរ។ ក្នុងករណីដែលអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំប្រព្រឹត្តបទលហុ ឬបទមជ្ឈឹម ព្រះរាជាអាជ្ញាត្រូវពិចារណាក្នុងការបង្វែរជាមុន ហើយបើព្រះរាជអាជ្ញាសម្រេចបង្វែរ ឬផ្ទេររឿងក្តីអនីតិជនចេញពីនីតិវិធីតុលាការព្រហ្មទណ្ឌ គឺនីតិវិធីនៃការចោទប្រកាន់ទាំងអស់ត្រូវបានផ្អាកដោយដីកាសម្រេច។ នៅពេលដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោមសម្រាប់ឱ្យអនីតិជនបំពេញជាកាតព្វកិច្ចៈ

- ចំណុចមួយ ឬច្រើនស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ
- ឱ្យអនីតិជនទៅរៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ខែ
- តម្រូវឱ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងថិរវេលាមិនលើសពី ៦ខែ
- ធ្វើការងារសហគមន៍មិនឱ្យលើសពី ១០០ ម៉ោង (ការងារសហគមន៍នេះសម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំឡើងទៅ ហើយការងារនេះត្រូវមានលក្ខណៈបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ជូនអនីតិជនទៅរស់នៅក្នុងសង្គម

[39] មាត្រា ៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[40] មាត្រា ៦៥ នៃនៃព្រះរាជក្រមយោងខាងលើ

- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍សម្រាប់ជួយអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើសសារជាថ្មី
- ឱ្យស្នាក់នៅកន្លែងណាមួយជាកំណត់មានពេលវេលាជាក់លាក់
- ជួសជុលសំណងខូចខាតដល់ជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញក្នុងគោលបំណងបង្វែរ។

ក្នុងករណីដែលការបង្វែរនេះទទួលបានជោគជ័យ ដោយយោងលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាជាមួយភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកបង្វែរ គឺព្រះរាជអាជ្ញាចេញដីកាតម្កល់រឿងទុកឥតចាត់ការ។ ប៉ុន្តែក្នុងករណីដែលការបង្វែរនេះមិនទទួលបានជោគជ័យព្រះរាជាអាជ្ញាអាចសម្រេចចេញបង្វែរថ្មីម្តងទៀត ឬក៏បន្តនីតិវិធីចោទប្រកាន់[41]។

**២.៣.៤. ការបង្កើតផែនការបង្វែរ**

បន្ទាប់ពីទទួលបានដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំនូវផែនការបង្វែរ។ ជាគោលការណ៍ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ខែ គិតពីថ្ងៃទទួលដំណឹងអំពីការសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេស ដែលមិនអាចជម្នះបាន។ ក្នុងការធ្វើផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាម្នាក់ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាលើកត្តាមួយចំនួនដូចខាងក្រោម៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស និងភាពសមស្របនៃការបង្វែរដែលត្រូវបានស្នើ
- សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសទៅនឹងស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម
- តម្រូវការអភិវឌ្ឍ និងអាយុរបស់អនីតិជន[42]។

ជាគោលការណ៍ផែនការបង្វែរ គឺត្រូវបានរៀបចំឡើងសម្រាប់ផ្តល់នូវអត្ថប្រយោជន៍ដល់អនីតិជន និងធ្វើឱ្យអនីតិជន បានយល់ដឹងអំពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស ក៏ដូចជាជនដទៃទៀតដែលរងនូវផលប៉ះពាល់ ដើម្បីឱ្យអនីតិជននោះចេះកែប្រែនូវកំហុសឆ្គង ដែលបង្កឡើងដោយអំពើល្មើស។ បន្ថែមពីនេះ បានផ្តល់ឱ្យអនីតិជនមានភាពងាយស្រួល ព្រោះអនីតិជន អាចអនុវត្តនៅកន្លែងដែល

[41] មាត្រា ២៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[42] មាត្រា ៦៦ កថាខណ្ឌទី២ នៃព្រះរាជក្រមយោងខាងលើ

អាចអនុវត្តបាន ម្យ៉ាងដើម្បីជៀសវាងការកេងប្រវ័ញ្ច ឬបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់អនីតិជន ជាពិសេសគឺមិនធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់អនីតិជន ក្នុងករណីដែលអនីតិជនកំពុងសិក្សា និងមិនមានការដកហូតសិទ្ធិសេរីភាព និងការដាក់ទោសណាមួយដល់អនីតិជនបានឡើយ[43]។

បន្ទាប់ពីផែនការបង្វែរត្រូវបានបង្កើតរួចហើយ ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការនោះទៅកាន់អាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីធ្វើការពិនិត្យ និងសម្រេចលើផែនការបង្វែរនោះ។ ក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបង្វែរត្រូវចេញដីកាសម្រេចឱ្យអនុវត្តនូវផែនការ ដែលមានអានុភាពធ្វើឱ្យភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកទទួលផែនការបង្វែរ ត្រូវអនុវត្តសេចក្ដីសម្រេចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជននោះ។ ជាគោលការណ៍បុគ្គលទទួលបន្ទុកបង្វែរត្រូវធ្វើរបាយការណ៍ស្ដីពី លទ្ធផលជោគជ័យ បរាជ័យ ឬឧបសគ្គដែលកើតមានឡើងនៅក្នុងផែនការបង្វែរជូនភ្នាក់ងារសង្គមកិច្ច។ ចំពោះភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះ រួមទាំងយោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច។

ជាមួយគ្នានេះដែរ ក្នុងផែនការបង្វែរក៏ត្រូវមានការចុះនិទ្ទេសផងដែរ ហើយនិទ្ទេសដែលត្រូវចុះក្នុងផែនការបង្វែរមាន[44]៖

- វិធានការបង្វែរណាមួយ និងរយៈពេលនៃការអនុវត្តផែនការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្ដល់ឱ្យអនីតិជន
- បញ្ជាក់ឱ្យបានច្បាស់លាស់ពីបុគ្គល ឬអង្គការដែលផ្ដល់សេវា និងជំនួយ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់របស់អនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ទៅកាន់អាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ (អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជា នគរបាល ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍)
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ច ដែលទទួលបន្ទុកត្រួតពិនិត្យ តាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់ពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ។

[43] មាត្រា ៦៦ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[44] មាត្រា ៦៧ នៃនៃព្រះរាជក្រមយោងខាងលើ

*ផែនការបង្វែរត្រូវចុះ៖*

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃបុគ្គលពាក់ព័ន្ធ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវធ្វើការរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ហើយនៅក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរ មិនយល់ស្របចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវបង្គាប់ឱ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី។ ផែនការបង្វែរត្រូវសម្រេចនៅក្នុងអំឡុងពេលមិនលើសពី ១ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពដែលមិនអាចជម្នះបាន។

ក្នុងអំឡុងពេល អនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬទៅតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍ដល់អនីតិជនដែលការកែប្រែត្រូវសម្រេចនៅក្នុងរយៈពេល៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីអាជ្ញាធរបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ហើយការកែប្រែផែនការបង្វែរមិនត្រូវបានចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរទេ។

### ២.៣.៥. ការបរាជ័យក្នុងផែនការបង្វែរ

ការបរាជ័យក្នុងវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានបំពេញ និងគោរពទៅតាមការអនុវត្តក្នុងវិធានបង្វែរ ឬនៅក្នុងវិធានការបង្វែរត្រូវបានកែប្រែ។ ជាមួយគ្នានេះដែរ ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនបានគោរពកាតព្វកិច្ចដែលកំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត។

បន្ទាប់ពីបានពិនិត្យរបាយការណ៍ខាងលើរួចអាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់កំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការ និងមេធាវីរបស់អនីតិជនប្រសិនបើមាន ឱ្យចូលមកបង្ហាញខ្លួនក្នុងថិរវេលាមិនលើសពី ១៥ថ្ងៃ ហើយអាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះ មិនគោរពវិធានការបង្វែរ។ ក្រោយពីបានពិចារណាអំពីការយល់ឃើញរបស់អនីតិជន អ្នកតំណាងដែលច្បាប់កំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារ

សង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន[45]។

ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ។ ក្នុងករណីនេះដែរព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមៗដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅកាន់អនីតិជន ហើយប្រសិនបើយល់ថាសមស្រប ត្រូវជូនដំណឹងនេះតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីត្រៀមរៀបចំមធ្យោបាយក្នុងការការពារអនីតិជននោះ[46]។ យោងទៅតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា ៣០ បានចែងថា ប្រសិនបើព្រះរាជអាជ្ញា ពិនិត្យសំណុំរឿងឃើញថា អ្នកប្រព្រឹត្តនោះមានសហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងនីតិជនផង ព្រះរាជអាជ្ញាអាចចេញសម្រេចចេញនូវដីកានៃការបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នាបាន។

## ផ្នែកទី៣ ដំណាក់កាលចៅក្រមស៊ើបសួរ

នៅក្នុងដំណាក់កាលស៊ើបសួរ ជាដំណាក់កាលមួយដែលមានសារៈសំខាន់ ក្នុងដំណើរការជំនុំជម្រះក្ដីនៃរឿងក្ដីព្រហ្មទណ្ឌ ដែលចៅក្រមស៊ើបសួរធ្វើការប្រមូលនូវភស្តុតាងចាំបាច់ដែលពាក់ព័ន្ធសម្រាប់សម្រេចសេចក្ដីចំពោះការចោទប្រកាន់មុននឹងបិទបញ្ចប់ការស៊ើបសួរ។ នៅក្នុងការស៊ើបសួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងរឿងក្ដីរបស់អនីតិជន គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន [47] ។ ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្ដីព្រហ្មទណ្ឌរបស់អនីតិជនយកមកចាត់ការជាអាទិភាព ជាពិសេសគឺរឿងក្ដីអនីតិជនដែលកំពុងជាប់ឃុំបណ្ដោះអាសន្ន ហើយការស៊ើបសួរត្រូវតែអនុវត្តភ្លាមក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការហើយនៅពេលបើកការស៊ើបសួរ អនីតិជនដែលជាប់សង្ស័យត្រូវតែមានមេធាវីអមជានិច្ច[48]។

ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ យើងឃើញថាក៏មានកិច្ចមួយចំនួនផងដែរ ដែលជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវបំពេញ ហើយកិច្ចទាំងនោះយើងឃើញមានចែងផងដែរផ្អែកតាមបទដ្ឋានគតិយុត្តសំខាន់ដែលមានចែងក្នុងបញ្ញត្តិ ក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្ដីយុត្តិធម៌អនីតិជនជាដើម។

[45] មាត្រា ៧១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[46] មាត្រា ២៩ នៃព្រះរាជក្រមយោងខាងលើ

[47] មាត្រា ២៨ នៃព្រះរាជក្រមយោងខាងលើ

[48] មាត្រា ១៤ កតិកាសសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

## ៣.១. ការជូនដំណឹងអំពីការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការពិនិត្យ

ក្រោយពីទទួលបានដីកាបញ្ជូនសំណុំរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការបើកការស៊ើបសួរភ្លាម ហើយអនីតិជនដែលជាជនត្រូវចោទ ត្រូវមានមេធាវីក្នុងអំឡុងពេលស្តាប់ចម្លើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈមេធាវី ហើយចៅក្រមស៊ើបសួរត្រូវទុកអំឡុងពេលសមរម្យមួយដើម្បីឱ្យមេធាវីធ្វើការសិក្សាទៅលើសំណុំរឿង និងពិភាក្សាជាមួយអនីតិជនមុនដំណើរការកិច្ចសួរចម្លើយ។

នៅដែលពេលអនីតិជនបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យទៅលើអត្តសញ្ញាណរបស់អនីតិជនរួចត្រូវប្រាប់ឱ្យដឹងពីរឿងរ៉ាវដែលចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសដែលច្បាប់បានកំណត់ និងសិទ្ធិជាមូលដ្ឋាន របស់អនីតិជននៅក្នុងនីតិវិធីផងដែរ[49]។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ [50] ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះនឹងនាំឱ្យមោឃភាពនីតិវិធី[51]។

## ៣.២. ការស្តាប់ចម្លើយ និងជំនួយរបស់មេធាវី

ការស្តាប់ចម្លើយទៅលើជនសង្ស័យ ឬជនត្រូវចោទ ដែលជាអនីតិជនត្រូវធ្វើឡើងជាសម្ងាត់ និងអនុវត្តទៅតាមនីតិវិធីកុមារមេត្រី[52]។ ការស្តាប់ចម្លើយនេះទៀតសោត គឺត្រូវស្តាប់ដោយចៅក្រមស៊ើបសួរផ្ទាល់រួមជាមួយនឹងក្រឡាបញ្ជីម្នាក់ជាជំនួយការក្នុងការកត់ត្រាផងដែរ។

ទាក់ទងនឹងនីតិវិធីកុមារមេត្រី ជានីតិវិធីដែលមានលក្ខណៈលើកទឹកចិត្តឱ្យអនីតិជនចូលរួមក្នុងរឿងក្តីតាមរយៈការប្រើភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់ដឹងបានស្របទៅដោយបរិយាកាសដែលធានាឱ្យអនីតិជនមានសុវត្ថិភាព សន្តិភាព និងតម្រូវការជាមូលដ្ឋាន[53]។ ស្ថិតក្នុងចំណុចខាងលើនេះដែរចង់សំដៅដល់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីក្នុងរឿងក្តីអនីតិជន តុលាការត្រូវអនុវត្តជានិច្ចនូវនីតិវិធីកុមារមេត្រីនិងជាសម្ងាត់ តួយ៉ាងដូចក្នុងកិច្ចស៊ើបសួរដែលមានដូចជា ការសាកសួរចម្លើយជាដើម ហើយរាល់ការស្តាប់ចម្លើយរបស់អនីតិជន ត្រូវតែមានវត្តមានរបស់មេធាវីការពារសិទ្ធិដែលអមជាមួយអនីតិជន។ ក្នុងនោះដែរអ្នកតំណាងដែលច្បាប់កំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច ក៏ត្រូវមានវត្តមានដូចគ្នា តែបើវត្តមានរបស់បុគ្គល

[49] មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[50] មាត្រា ៣៣ នៃព្រះរាជក្រមយោងខាងលើ

[51] មាត្រា ៣៣ នៃព្រះរាជក្រមយោងខាងលើ

[52] មាត្រា ៣៥ នៃព្រះរាជក្រមយោងខាងលើ

[53] មាត្រា ៤ ចំណុចទី៧ នៃព្រះរាជក្រមយោងខាងលើ

ដែលបានរៀបរាប់ខាងលើ ធ្វើឱ្យប៉ះពាល់ ឬខូចឧត្តមប្រយោជន៍របស់អនីតិជន នោះចៅក្រមអាចមិនអនុញ្ញាតឱ្យអ្នកតំណាងដែលច្បាប់កំណត់មិនអាចចូលរួមស្តាប់ចម្លើយបាន ហើយចំពោះការមិនអនុញ្ញាតនេះ ត្រូវពិភាក្សាជាមុនជាមួយនឹងមេធាវី ឬភ្នាក់ងារសង្គមកិច្ចព្រមជាមួយនឹងសាមីខ្លួនដែលជាអនីតិជនផ្ទាល់ផងដែរ[54]។

ក្រោយពីបានបញ្ចប់ការសួរចម្លើយភ្លាម អនីតិជនមានសិទ្ធិក្នុងការអានកំណត់ហេតុស្តាប់ចម្លើយ ឬស្នើសុំឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួនបាន ប្រសិនបើអនីតិជនពុំអាចអានបានដោយខ្លួនឯង ហើយការដែលអាននូវកំណត់ហេតុស្តាប់ចម្លើយមុនបែបនេះ ព្រោះដើម្បីឱ្យអនីតិជនអាចផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួនមុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃទទួលស្គាល់នូវកំណត់ហេតុនោះ ហើយមួយទៀតនោះគឺ មេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចក៏ត្រូវបានអនុញ្ញាតឱ្យអានកំណត់ហេតុស្តាប់ចម្លើយបានផងដែរប្រសិនបើមានការស្នើសុំ[55]។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុទេ ចៅក្រមត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ។

វិធានការនៃការសាកសួរចម្លើយទៅលើអនីតិជន គឺត្រូវតែមានវត្តមានរបស់មេធាវីការពារសិទ្ធិអមមកជាមួយអនីតិជនជានិច្ច ក្នុងករណីដែលអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមស្តាប់ចម្លើយ។ ក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ បាត់បង់តម្រុយនៃភស្តុតាង កាលៈទេសៈបន្ទាន់ គឺត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ[56]។

ជាគោលការណ៍ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យគ្រឹះស្ថានសិក្សា ឬនិយោជកធ្វើការព្យួរការងារ ឬការសិក្សារបស់អនីតិជនក្នុងករណីដែលអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវបានអនុវត្តវិធានការបង្វែរ ហើយចំពោះការព្យួរការងារ ឬការសិក្សារបស់អនីតិជន គឺត្រូវព្យួររហូតដល់មានសេចក្តីសម្រេចជាស្ថាពរពីតុលាការ។ តាមរយៈនេះដែរបើតុលាការសម្រេចសេចក្តីថា អនីតិជនគ្មានទោសទេនោះ គ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឱ្យអនីតិជនចូលរៀន និងធ្វើការធម្មតា។

### ៣.៣.អំណាចលើការបង្វែរ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការអនុវត្តវិធានការបង្វែរជាពិសេសគឺ ក្នុងរឿងក្តីដែលមានជនត្រូវចោទជាអនីតិជន។ ក្នុងករណីដែលអនីតិជន ត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានស្ថានទម្ងន់ទោស ចៅក្រមស៊ើបសួរត្រូវតែធ្វើការពិចារណាជាអាទិភាព

[54] មាត្រា ៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[55] មាត្រា ៣៥ កថាខណ្ឌទី៤ នៃព្រះរាជក្រមយោងខាងលើ

[56] មាត្រា ៣៦ នៃព្រះរាជក្រមយោងខាងលើ

ទៅលើការប្រើប្រាស់នូវវិធានការបង្វែរជាមុន មុននឹងសម្រេចប្រើវិធានការដទៃ។ ក្នុងករណីដែលត្រូវបង្វែររឿងក្តីអនីតិជនចេញពីតុលាការ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីដោយដីកាសម្រេច និងបង្គាប់ឱ្យដោះលែងអនីតិជននោះ ប្រសិនបើអនីតិជនត្រូវបានជាប់ឃុំបណ្តោះអាសន្ន។ ក្នុងនោះដែរ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរដែលទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ។ ជាមួយគ្នានេះដែរបើការបង្វែរដែលបានរៀបចំឡើងនោះ ទទួលបានជោគជ័យ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ ដោយផ្អែកលើរបាយការណ៍ដែលបានបញ្ជាក់ពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកបង្វែរ។ ផ្ទុយមកវិញបើការបង្វែរនេះ មិនបានជោគជ័យទេនោះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្វែរថ្មីបានដោយពិចារណា ពីមូលហេតុដែលបរាជ័យ ឬបន្តនីតិវិធីស៊ើបសួរ[57]។

## ៣.៤. ថិរវេលានៃការឃុំខ្លួនអនីតិជន

ក្នុងករណីដែលលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ មិនត្រូវបានបំពេញទេ ហើយថែមទាំងតុលាការមានសំអាងគ្រប់គ្រាន់ ដើម្បីធ្វើការឃុំខ្លួន នោះតុលាការអាចសម្រេចឃុំខ្លួនអនីតិជនត្រូវចោទជាបណ្តោះអាសន្នបាន ហើយការឃុំខ្លួននេះត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន និងដីកាបង្គាប់ឱ្យឃុំខ្លួន។

ជាគោលការណ៍អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺមិនត្រូវបានឃុំបណ្តោះអាសន្នទេ ក្នុងករណីដែលចៅក្រមស៊ើបសួរពិនិត្យទៅឃើញថាអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឱ្យទៅ ឪពុកម្តាយ អ្នកអាណាព្យាបាល ឬប្រគល់ទៅមជ្ឈមណ្ឌលអប់រំបណ្តោះអាសន្នដើម្បីរង់ចាំការសម្រេចពីតុលាការ។ ក្នុងករណីដែលអនីតីជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈឹម ចៅក្រមអាចសម្រេចឃុំអនីតិជននោះបាន ហើយចំពោះថរិវេលានៃការឃុំខ្លួនបណ្តោះអាសន្នដែលត្រូវយកមកអនុវត្តលើអនីតិជនមានដូចខាងក្រោម៖

**ចំពោះអនីតិជនដែលប្រព្រឹត្តបទឧក្រិដ្ឋ[58]៖**

១. អនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នឱ្យហួសពី ៤ (បួន) ខែ។

២. អនីតិជនអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នឱ្យហួសពី ៦ (ប្រាំមួយ) ខែ។

---

[57] មាត្រា ៣៤ នៃច្បាប់ពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[58] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ចំពោះអនីតិជនដែលប្រព្រឹត្តបទមជ្ឈិម[59]៖**

១. អនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នឱ្យហួសពី ២ (ពីរ) ខែ ។

២. អនីតិជនអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចឃុំខ្លួនបណ្តោះអាសន្នឱ្យហួសពី ៤ (បួន) ខែ។

ជាមួយនឹងបទមជ្ឈិមនេះដែរ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺមិនត្រូវឱ្យលើសពីពាក់កណ្តាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។

ឧទាហរណ៍៖ អនីតិជនអាយុ ១៧ (ដប់ប្រាំពីរ) ឆ្នាំ ម្នាក់បានប្រព្រឹត្តបទឃាតកម្ម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ បើយោងទៅតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ដោយស្ថិតក្នុងចំណុចនេះដែរ គឺត្រូវបានគេពិចារណា ទៅលើមូលហេតុនៃអាយុរបស់ជនត្រូវចោទ ដែលនាំឱ្យមូលទោសនោះបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ទៅ ៧ (ប្រាំពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ បើយោងទៅតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះទោសដែលអនីតិជននោះប្រព្រឹត្ត ជាបទឧក្រិដ្ឋ ដែលជាហេតុនាំឱ្យមានការឃុំខ្លួនអនីតិជនបណ្តោះអាសន្នបាន ហើយការឃុំខ្លួននេះមិនអាចលើសពី ៧ ខែបានឡើយ។

## ៣.៥. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រោយពីមានការចោទប្រកាន់របស់តំណាងអយ្យការ ចៅក្រមស៊ើបសួរអាចដាក់អនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេល។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន ព្រោះការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជន គឺសម្រាប់តែវិធានការចុងក្រោយបង្អស់ដែលចៅក្រមស៊ើបសួរនឹងធ្វើការពិចារណាប្រើប្រាស់[60]។ ចំពោះការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមបន្ថែមចំណុចពិសេសមួយចំនួនដូចជា[61]៖

- ការដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុក ម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកទំនុកបម្រុង ឬក្រុមគ្រួសារណាមួយសមស្រប
- ការដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងថែទាំក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទា និងការមើលថែទាំអនីតិជន

---

[59] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[60] មាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[61] មាត្រា ៤០ នៃព្រះរាជក្រមយោងខាងលើ

- មិនឱ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ថាសមស្រប។

### ៣.៦. ការបង្គាប់ដោះលែងឱ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរ អាចបង្គាប់ដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួនតែត្រូវជូនដំណឹងទៅកាន់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ត្រឡប់មកវិញក្នុងរយៈពេលខ្លីបំផុត[62]។ ក្នុងករណីបន្ទាន់ដែលចាំបាច់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងអនីតិជនភ្លាមដោយពុំចាំបាច់រង់ចាំយោបល់ពីព្រះរាជអាជ្ញាឡើយ ដោយចៅក្រមស៊ើបសួរគ្រាន់តែបញ្ជាក់ពីមូលហេតុបន្ទាន់នៅក្នុងដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរ[63]។

បន្ទាប់ពីបានដោះលែងអនីតិជនឱ្យនៅក្រៅឃុំរួចហើយ ចៅក្រមស៊ើបសួរ ត្រូវបង្គាប់ឱ្យប្រគល់អនីតិជននោះទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ ឬបញ្ជូនអនីតិជនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ទៅតាមស្ថានភាពជាក់ស្តែងរបស់អនីតិជន[64]។

បន្ថែមពីនេះ ក្រៅពីការសម្រេចដោះលែងឱ្យនៅក្រៅឃុំដោយការផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរហើយនោះព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន អាចស្នើសុំទៅចៅក្រមស៊ើបសួរឱ្យដោះលែងអនីតិជនឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ ជាមួយគ្នានេះដែរ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំ[65]។

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរនឹងជូនព័ត៌មាននេះទៅដល់ព្រះរាជអាជ្ញា និងភាគីជាប់ពាក់ព័ន្ធដូចជា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកតំណាងដែលច្បាប់បានកំណត់ ឬមេធាវីជាដើម មុននឹងចៅក្រមស៊ើបសួរសម្រេចចេញដីកាដំណោះស្រាយ គឺចៅក្រមអាចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដែលចៅក្រមស៊ើបសួរសម្រេចក្រោយពីបិទការស៊ើបសួរ[66]។

គួរបញ្ជាក់ផងដែរថា ចំពោះរឿងក្តីត្រូវចោទដែលជាអនីតិជន មានលក្ខណៈពិសេសត្រង់ថា មុនចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណា ទៅលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាល

[62] មាត្រា ៤១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[63] មាត្រា ៤១ កថាខណ្ឌទី១ នៃព្រះរាជក្រមយោងខាងលើ

[64] មាត្រា ៤១ កថាខណ្ឌទី៣ នៃព្រះរាជក្រមយោងខាងលើ

[65] មាត្រា ៤១ កថាខណ្ឌទី៦ នៃព្រះរាជក្រមយោងខាងលើ

[66] មាត្រា ២៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ភាព និងស្ថានភាពសង្គមរបស់អនីតិជនពីភ្នាក់ងារសង្គមកិច្ចជាមុនផងដែរ[67]។

### ៣.៧. ការលើកលែងការចោទប្រកាន់

ជាគោលការណ៍ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងការចោទប្រកាន់នៅក្នុងករណីដូចដែលអំពើប្រព្រឹត្តនោះ ពុំមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ហើយមិនស្គាល់ជនដែលបានប្រព្រឹត្តអំពើនោះ ក៏ដូចជាគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ[68]។ អានុភាពនៃដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ គឺនាំឱ្យមានការដោះលែងអនីតិជនដែលបានជាប់ឃុំទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ[69]។

ចៅក្រមស៊ើបសួរ ត្រូវប្រគល់អនីតិជនទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ តែប្រសិនបើករណីដែលស្ថានភាពរបស់អនីតិជននោះតម្រូវឱ្យមានកិច្ចការពារ និងការថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីដែលពាក់ព័ន្ធនឹងការព្យួរ ការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ព្រមទាំងសិទ្ធិអាណាព្យាបាលលើអនីតិជន ត្រូវបានធ្វើឡើងដោយការដាក់ពាក្យស្នើសុំទៅតុលាការ ដើម្បីឱ្យតុលាការធ្វើសម្រេច[70]។

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា អំពើល្មើសនោះជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ ចៅក្រមស៊ើបសួរនឹងសម្រេចបញ្ជូនជនត្រូវចោទជាអនីតិជនទៅចំពោះមុខតុលាការជំនុំជម្រះ តាមរយៈដីកាបញ្ជូនរឿងឱ្យជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ គឺត្រូវបានរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសដែលអនីតិជនបានប្រព្រឹត្តដោយទៅតាមច្បាប់។

## ផ្នែកទី៤ ដំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ

ក្នុងករណីមានការជំនុំជម្រះលើរឿងក្ដីអនីតិជន គឺត្រូវធ្វើឡើងដោយមានចៅក្រមជំនុំជម្រះមានជំនាញទាក់ទងនឹងអនីតិជន និងមានសមាសភាពចៅក្រមជំនុំជម្រះចំនួន ០៣ (បី) រូប ដើម្បីធ្វើការពិភាក្សា និងសម្រេចឱ្យបានច្បាស់លាស់ថា អនីតិជននោះមានទោស ឬគ្មានទោស[71]។ តាមរយៈការពិភាក្សាដេញដោល និងការប្រកាសសាលក្រមលើរឿងក្ដីអនីតិជនត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ [72] ហើយមានតែបុគ្គលដែលមាន

[67] មាត្រា ៤២ កថាខណ្ឌទី៦ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[68] មាត្រា ២៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69] មាត្រា ៤២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[70] មាត្រា ៤២ កថាខណ្ឌទី៥ និងទី៦ នៃព្រះរាជក្រមយោងខាងលើ

[71] មាត្រា ៤៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[72] មាត្រា ៤៧ នៃព្រះរាជក្រមយោងខាងលើ

សិទ្ធិ និងកាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការបាន។ បន្ថែមពីនេះទៅទៀត អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ ប៉ុន្តែប្រសិនបើការចូលរួមរបស់បុគ្គលទាំងនោះ មិនបានបម្រើដល់ឧត្តមប្រយោជន៍របស់អនីតិជនទេ តុលាការអាចមិនអនុញ្ញាតឱ្យចូលរួមបាន។

នៅគ្រប់ដំណាក់កាលនៃរឿងក្តីអនីតិជនមិនថានៅពេលសវនាការ ក៏តុលាការត្រូវប្រើនីតិវិធីកុមារមេត្រី[73]។ មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។ ក្នុងកាលៈទេសៈនេះផងដែរ ជំនួយរបស់មេធាវី ពិតជាមានសារៈសំខាន់ណាស់ក្នុងសវនាការ ដូចនេះជំនួយមេធាវីដែលការពារសិទ្ធិឱ្យអនីតិជន ត្រូវមានជាដាច់ខាត បើទោះបីជាគ្មានការជ្រើសរើសដោយអនីតិជនក៏ដោយ ក៏មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមរយៈការផ្តួចផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីផងដែរ។

### ៤.១.សមត្ថកិច្ចក្នុងការជំនុំជម្រះ

ជាគោលការណ៍ ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម ត្រូវធ្វើការជំនុំជម្រះដោយចៅក្រម ០៣ (បី) រូបដើម្បីធ្វើការពិភាក្សា និងសម្រេចចំពោះរឿងក្តីអនីតិជនឱ្យបានត្រឹមត្រូវ។ រីឯបទលហុ វិញ គឺត្រូវបានជំនុំជម្រះដោយចៅក្រមម្នាក់ដើម្បីធ្វើការសម្រេចសេចក្តី។ ជាមួយគ្នានេះដែរតុលាការត្រូវលើកយករឿងក្តីពាក់ព័ន្ធនឹងអនីតិជនជារឿងក្តីអាទិភាព ពិសេសនោះគឺរឿងក្តីអនីតិជនកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន។

ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ការរងចាំជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព ហើយចំពោះរឿងក្តីដែលត្រូវបានលើកពេលជំនុំជម្រះតុលាការក៏ត្រូវពិចារណាអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាពឡើងវិញដូចគ្នា [74] ។ ជាមួយគ្នានេះដែរ ក្នុងករណីដែលតុលាការរកឃើញថា អនីតិជន ដែលជាប់ចោទនោះ មានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលដែលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ក៏ដូចជាដោះលែងអនីតិជនដែលជាប់ឃុំនោះជាបន្ទាន់ បើទោះបីជាមានការប្តឹងពីព្រះរាជអាជ្ញាក៏ដោយ។ បន្ទាប់ពីសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ តុលាការត្រូវប្រគល់អនីតិជនទៅកាន់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជននោះ ។

[73] មាត្រា ៤៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[74] មាត្រា ៤៥ នៃព្រះរាជក្រមយោងខាងលើ

## ៤.២.នីតិវិធីមុនពេលសវនាការលើរឿងក្តីអនីតិជន

មុនពេលចាប់ផ្តើមសវនាការ តុលាការត្រូវធ្វើការពិនិត្យទៅលើរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព រួមទាំងស្ថានភាពសង្គមរបស់អនីតិជនដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច[75]។

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានទាក់ទងនឹងសិទ្ធិមួយចំនួនដូចខាងក្រោម[76]៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះ
- សិទ្ធមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ
- សិទ្ធិប្តឹងឧទ្ធរណ៍

វិធានការបង្វែរ គឺត្រូវបានយកមកពិចារណាក្នុងដំណាក់កាលនៃការជំនុំជម្រះដោយមានលក្ខណៈដូចគ្នាទៅនឹងដំណាក់កាលនៃព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ។

ក្នុងករណីដែលអនីតិជនអាចសារភាពនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តក្នុងពេលជំនុំជម្រះនៅតុលាការត្រូវពិនិត្យថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពដែលទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង និងគ្មានការបង្ខិតបង្ខំផងដែរ។ ប្រសិនបើចម្លើយសារភាពរបស់អនីតិជនផ្ទុយទៅបញ្ញត្តិខាងលើនេះ គឺមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ទាក់ទងនឹងការសារភាពទទួលយកផែនការបង្វែរ មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដទៃដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់ឡើយ[77]។

សាលក្រមអាចធ្វើការប្រកាសនៅពេលសវនាការក្រោយពីការពិភាក្សាដេញដាល ឬនៅពេលសវនាការលើកក្រោយ ដែលការប្រកាសនេះទៀតសោតត្រូវធ្វើឡើងជាអសាធារណៈ នៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច រួមជាមួយភាគីដែលមានប្រយោជន៍ក្នុងរឿងក្តី។ បន្ថែមពីនេះសាលក្រមអាចប្រកាសកំបាំងមុខអនីតិជន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចប្រយោជន៍អនីតិជន។

---

[75] មាត្រា ៤៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[76] មាត្រា ៥១ នៃព្រះរាជក្រមយោងខាងលើ

[77] មាត្រា ៥៣ នៃព្រះរាជក្រមយោងខាងលើ

# ជំពូកទី៣

# វិធានការអនុវត្តទោសចំពោះ

# អនីតិជន

# ជំពូកទី៣
# វិធានការអនុវត្តទោសចំពោះអនីតិជន

## ផ្នែកទី១ វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

ចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ហើយត្រូវបានគេជឿជាក់ថាពិតជាបានប្រព្រឹត្តបទល្មើសនោះ វិធានការទូទៅដែលត្រូវបានលើកយកមកអនុវត្តចំពោះអនីតិជនបាន គឺជាវិធានការទណ្ឌកម្មព្រហ្មទណ្ឌ និង វិធានការបង្វែរដូចដែលបានរៀបរាប់ខាងលើ។ ដោយឡែកវិធានការទណ្ឌកម្មព្រហ្មទណ្ឌ គឺត្រូវតែជាវិធានការចុងក្រោយបំផុត ដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន។

### ១.១. ទណ្ឌកម្មព្រហ្មទណ្ឌ

ជាគោលការណ៍អនីតិជនក៏អាចទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌដូចគ្នាទៅនឹងអនីតិជនផងដែរ។ ប៉ុន្តែអ្វីដែលខុសគ្នាពីនីតិជន នោះគឺរបបនៃទោសដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន គឺមិនដូចគ្នាទៅនឹងរបបនៃទោសដែលអនុវត្តចំពោះនីតិជនឡើយ ពោលគឺអនីតិជនមាននូវរបបគតិយុត្តពិសេសមួយដាច់ដោយឡែកពីនីតិជន។ តាមរយៈរបបនៃទោសនេះគឺមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌចាប់ពីបញ្ញត្តិនៃមាត្រា ១៦០ ដល់មាត្រា ១៦៦ បន្ថែមពីនេះ ដោយហេតុថាអនីតិជនមានសមត្ថភាពយល់ដឹងខាងអំពើរបស់ខ្លួន នៅមានកម្រិតនៅឡើយ កាលបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃអនីតិជនតម្រូវ តុលាការក៏អាចសម្រេចឱ្យអនីតិជនទទួលបាននូវការសម្រាលទោសផងដែរ។ ជាមួយគ្នានេះដែរ របបនៃទោសដែលអាចលើកយកមកអនុវត្តចំពោះអនីតិជនបានមានដូចខាងក្រោម៖

### ១.២. ទោសដែលអាចអនុវត្តចំពោះអនីតិជន

គេសង្កេតឃើញថាទោស គឺមានការប្រែប្រួលទៅតាមបុគ្គលដែលបានប្រព្រឹត្តបទល្មើសហើយ ការប្រែប្រួលនេះទៀតសោត គឺនាំឱ្យគេថា អាចបណ្តាលមកពីមូលហេតុនៃការវិវត្តរបស់ជនដែលបានប្រព្រឹត្តបទល្មើស។ ដោយផ្អែកទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យក និងបែងចែកប្រភេទនៃទោសនេះជា ០៣ (បី) ប្រភេទគឺ៖

#### ១.២.១. មូលទោស

មូលទោស គឺជាទោសដែលគេយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ក្នុងនោះដែរមូលទោសត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌដែលរួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[78]។ ក្នុងករណីនេះដែរ បើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)

[78] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ និងត្រូវបានចៅក្រមពិនិត្យ និងពិចារណាទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជននោះឃើញថាមានលក្ខណៈតម្រូវគ្រប់គ្រាន់ហើយ ដូចនេះច្បាប់បានផ្តល់នូវឆន្ទានុសិទ្ធិដល់ចៅក្រមអំពីការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបាន។ ក្នុងករណីដែលចៅក្រមសម្រេចផ្តន្ទាទោសចំពោះអនីតិជន ពោលគឺចៅក្រមត្រូវលើកយកនូវមូលទោសដែលមានចែងក្នុងបញ្ញត្តិនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌមកអនុវត្តលើអនីតិជននោះ។

សូមបញ្ជាក់ផងដែរថាក្នុងករណីដែលចៅក្រមសម្រេចថាប្រកាសទោសចំពោះអនីតិជន នោះគឺជាជម្រើសចុងក្រោយបំផុតដោយហេតុថា ស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជននោះ ច្បាស់ណាស់ថាប្រាកដជាមានលក្ខណៈសាហាវ ឬអាចជាហេតុនាំឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមធ្ងន់ធ្ងរណាស់ ទើបនាំឱ្យមានការសម្រេចប្រកាសយ៉ាងដូច្នេះ។

ឧទាហរណ៍៖ អនីតិជនម្នាក់មានអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ បានប្រព្រឹត្តបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរ ប៉ះពាល់ខ្លាំងដល់សណ្តាប់ធ្នាប់សង្គម ពោលគឺ អនីតិជនរូបនោះបានធ្វើសកម្មភាពឆក់កាបូប នារីម្នាក់ដែលកំពុងតែជិះម៉ូតូតាមផ្លូវ ដែលការឆក់នេះបានធ្វើឱ្យនារីដែលជាជនរងគ្រោះ ដួលម៉ូតូបោកត្រូវក្បាលធ្ងន់ធ្ងរ រហូតធ្វើឱ្យនារីម្នាក់នោះបាត់បង់ជីវិតនៅកន្លែងកើតហេតុភ្លាមៗ។ ដោយស្ថិតក្នុងករណីបែបនេះ ចៅក្រមប្រហែលជាមិនអាចពិចារណាដាក់ឱ្យប្រើប្រាស់វិធានការផ្សេងក្រៅពីការដាក់ទោសលើអនីតិជនរូបនោះទេ តែទោះបីជាមានការផ្តន្ទាទោសលើអនីតិជនបែបនេះក៏ដោយ ក៏ចៅក្រមមិនអាចសម្រេចផ្តន្ទាទោសអនីតិជនដូចទៅនឹងនីតិជនបានឡើយ។

សម្រាប់មូលទោសដែលអនុវត្តចំពោះអនីតិជន គឺច្បាប់បានកំណត់នៅក្នុងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយបានចែងអំពីមូលទោសថា មូលទោសដែលអនុវត្តចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅដូច្នេះកាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌ ទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ដប់បួន (ឆ្នាំ) ឡើងទៅ មូលទោសលើបទល្មើសដែលត្រូវចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល។

ឧទាហរណ៍៖ ក ជាអនីតិជនដែលមានអាយុ ១៧ (ដប់ប្រាំពីរ) ឆ្នាំ បានប្រព្រឹត្តបទល្មើសមនុស្សឃាតដោយអចេតនា ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ យោងទៅតាមមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ។ ក្នុងបញ្ញត្តិនៃមាត្រានេះតម្រូវឱ្យបន្ថយនូវមូលទោសពីបទល្មើស ដែលត្រូវចោទប្រកាន់ពោលគឺអតិបរមានៃទោស ៣ (បី) ឆ្នាំ ត្រូវបន្ថយពាក់កណ្តាលមកត្រឹម ១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ ចំណែកឯអប្បបរមានៃទោសវិញគឺ ១ (មួយ) ឆ្នាំ ក៏ត្រូវបន្ថយពាក់កណ្តាលផងដែរ គឺមកត្រឹម ៦ (ប្រាំមួយ) ខែ។ ហេតុដូច្នេះទោស

ដែល ក ត្រូវទទួលការផ្តន្ទាទោសនោះគឺ ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ សម្រាប់បទល្មើសមនុស្សឃាតដោយអចេតនា។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

ឧទាហរណ៍៖ កុមារឈ្មោះ ក ជាសិស្សនៃវិទ្យាល័យមួយ ដែលមានអាយុ ១៦ ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើស "ឃាតកម្មគិតទុកជាមុន" ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត យោងទៅតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។ ដោយមូលហេតុជនសង្ស័យចាំពួនស្ទាក់នៅព្រៃស្ងាត់ ដើម្បីសម្លាប់ជនរងគ្រោះដែលមានទំនាស់នឹងគ្នាបន្ទាប់ពីជនរងគ្រោះចេញពីសាលារៀន ដែលក្នុងករណីនេះ អតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត ត្រូវបន្ថយមកត្រឹម ២០ (ម្ភៃ) ឆ្នាំ ដូច្នេះដោយយោងទៅលើមូលហេតុអាយុនៃជនល្មើស ហើយតុលាការមិនអាចប្រកាសទោសលើសពីនេះបានទេ។

៣. អប្បបរមា នៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាលប្រសិនបើអប្បបរមានោះ លើសពី១ (មួយ) ថ្ងៃ។

ឧទាហរណ៍៖ ក្នុងករណីដែលទោសជាប់ពន្ធនាគារ ត្រូវទទួលរងគឺ ៤ (បួន) ថ្ងៃ ដូចនេះអប្បបរមាចំពោះបទលហុអនីតិជនត្រូវទទួលរង គឺ ២ (ពីរ) ថ្ងៃជាអប្បបរមា។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ឧទាហរណ៍៖ ក អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ បានប្រព្រឹត្តបទល្មើសឆបោក ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល បើយោងតាមក្រមព្រហ្មទណ្ឌ។ នៅក្នុងករណីនេះទោសដែលត្រូវផ្តន្ទាទោសចំពោះ អនីតិជនត្រូវបន្ថយទាំងអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ផងដែរ។ ដូច្នេះទោសដែលត្រូវយកមកអនុវត្តចំពោះអនីតិជនគឺ ទោសដាក់ពន្ធនាគារ ពីបទឆបោក ដែលត្រូវផ្តន្ទាទោសពី ៣ (បី) ខែ ទៅ ១ (មួយ) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)រៀល ទៅ ៣.០០០.០០០ (បីលាន) រៀល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រាមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នោះ គឺនៅតែជាបទឧក្រិដ្ឋមិនអាចប្តូរមកជាបទមជ្ឈិមនោះទេ។

សូមបញ្ជាក់ដែរថា នេះគ្រាន់តែជាការរំលឹកនូវវិធានដែលចែងទាក់ទងនឹងប្រភេទនៃបទល្មើសពុំកែប្រែដោយ

ការបន្ថយស្របច្បាប់នៃទោសជាប់ពន្ធនាគារដែលយកមកអនុវត្តចំពោះអនីតិជនឡើយ។ បើយើងពិនិត្យទៅលើមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់ចំណុចទី២ គឺបានចង្អុលបង្ហាញយ៉ាងច្បាស់ថា បទឧក្រិដ្ឋ ទោសដែលជាប់ពន្ធនាគារត្រូវទទួលរងគឺមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ។ ដូចនេះទាក់ទងនឹងការបន្ធូរបន្ថយទោសស្របច្បាប់ គឺចែងឡើងដើម្បីជាប្រយោជន៍ដល់អនីតិជន ហើយក្នុងករណីនេះដែរបើអនីតិជនប្រព្រឹត្តបទឧក្រិដ្ឋ ហើយរយៈពេលតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទឧក្រិដ្ឋក៏ពុំត្រូវបានផ្លាស់ប្ដូរប្រភេទគតិយុត្តដើមជាបទឧក្រិដ្ឋនៃបទល្មើសឡើយ ពោលគឺនៅតែជាបទឧក្រិដ្ឋដដែល។

គួរពិចារណាផងដែរថា ទោះបីជាអនីតិជនដែលមានអាយុលើស ១៤ (ដប់បួន) ឆ្នាំ ហើយក៏ដោយ ក៏តុលាការគួរតែអនុគ្រោះដល់ការប្រកាសនូវវិធានការតាមដាន ឧបត្ថម្ភ អប់រំ និងការពារ ជាអាទិ៍ដើម្បីបានជាប្រយោជន៍ជូនទៅដល់អនីតិជនផងដែរ ព្រោះថាការដែលផ្ដន្ទាទោសអនីតិជនឱ្យនៅក្នុងពន្ធនាគារ គឺពិតជាបង្កគ្រោះថ្នាក់ និងផលប៉ះពាល់ដល់ស្មារតី ក៏ដូចជាប៉ះពាល់ទៅដល់អនាគតរបស់អនីតិជនទៅថ្ងៃខាងដូចគ្នា។

ការប្រកាសមូលទោសនៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង តុលាការអាចប្រកាស[79] ៖

- ទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ជាមួយគ្នា
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

### ១.២.២.ការប្រកាសទោសបន្ថែម

ទោសបន្ថែម សំដៅដល់ប្រភេទទោសមួយដែលបន្ថែមទៅលើមូលទោស[80]។ ក្នុងន័យនេះដែរជាទូទៅនៅពេលដែលចៅក្រមប្រកាសអំពីមូលទោស ហើយក្នុងករណីដែលលក្ខខណ្ឌច្បាប់ចែងថា អនុញ្ញាតឱ្យមានការផ្ដន្ទាទោសបន្ថែមទៀតនោះ ចៅក្រមអាចសម្រេចទោសបន្ថែមដើម្បីទៅលើមូលទោសនោះទៀតបាន។ បើពិនិត្យទៅលើបច្ចេកទេសក្នុងការអនុវត្តទោសបន្ថែមចំពោះទណ្ឌិតដែលជាអនីតិជន គឺមិនមានលក្ខណៈអ្វីខុសប្លែកពីការអនុវត្តទោសចំពោះនីតិជនឡើយ។ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺត្រង់ថាទោសបន្ថែមដែលអាចអនុវត្តចំពោះនីតិជនគឺមានរហូតទៅដល់ ១៩ចំណុចឯណោះ។

យោងតាមក្រមព្រហ្មទណ្ឌត្រង់បញ្ញត្តិនៃមាត្រា ១៦១ បានចែងអំពីទោសដែលអាចលើកយកមកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ៖

១. ការរឹបអូសសម្ភារ ឬវត្ថុដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស

[79] មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩

[80] *សូមមើល* មេរៀន នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ, ទំព័រ ៣០៦

២. ការរឹបអូសវត្ថុ ឬមូលនីធិដែលជាកម្មវត្ថុនៃបទល្មើស

៣. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

៤. ការរឹបអូសឧបករណ៍ភោគភណ្ឌសម្ភារ ឬចលនវត្ថុនៅកន្លែងប្រព្រឹត្តបទល្មើស

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

តាមរយៈការរៀបរាប់ខាងលើនេះ ទោសបន្ថែមគឺមានត្រឹមតែ ៥ ប៉ុណ្ណោះដែលអាចអនុវត្តបានចំពោះអនីតិជន ហើយក្នុងចំណោមទោសបន្ថែមទាំងនេះមានទោសបន្ថែមទី៤ គឺវិធានការរឹបអូសនូវទ្រព្យសម្បត្តិដែលមានទំនាក់ទំនងជាមួយនឹងបទល្មើស ចំណែកឯទោសបន្ថែមទី៥ វិញគឺគ្រាន់តែជាការហាមឃាត់ មិនឱ្យកាន់កាប់គ្រាប់រំសេវ ឬប្រដាប់អាវុធ និងគ្រឿងផ្ទុះប៉ុណ្ណោះ។

ដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ក៏ដូចជាអនីតិភាពនៃជនល្មើសចៅក្រមអាចពិនិត្យពិចារណាទៅលើស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសដើម្បីជៀសវាងការអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនវិញ។ ការងារសហគមន៍ដែលយើងកំពុងសិក្សានេះ គឺគ្មានកម្រៃសម្រាប់ផ្តល់ឱ្យអនីតិជននោះទេ ដូច្នេះការណ៍ដែលច្បាប់កំណត់ត្រឹមអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំនេះគឺជាការល្អប្រសើរបំផុតណាស់។

### ១.២.៣. ការងារសហគមន៍

ទោសការងារសហគមន៍ដែលអនុវត្តចំពោះអនីតិជន គឺមានលក្ខណៈខុសប្លែកគ្នាពីទោសការងារសហគមន៍ដែលអនុវត្តចំពោះនីតិជន។ យោងតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ១៦២ លក្ខខណ្ឌដែលអាចលើកយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ៖

១. លក្ខខណ្ឌអាយុ លុះត្រាតែអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំទើបអាចលើកយកមកអនុវត្តបាន (អនុសញ្ញាអន្តរជាតិ ស្តីពីនីតិការងារ)។

២. ថិរវេលាដែលត្រូវអនុវត្ត ចំពោះថិរវេលាដែលអាចអនុវត្តគឺ មិនឱ្យលើសពី១០០ ម៉ោងនោះទេ មានន័យថាថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជននេះ គឺច្បាប់បានកំណត់ត្រឹមតែពាក់កណ្តាលនៃថិរវលាដែលត្រូវអនុវត្តចំពោះអនីតិជនតែប៉ុណ្ណោះ។ ដូចនេះ ថិរវេលាត្រូវកម្រិតមកត្រឹមអប្បបរមាចំនួន ១០០ (មួយរយ) ម៉ោង ដែលតិចជាងបីសប្តាហ៍នៃការមិនទទួលយកកម្រៃ។

៣. ត្រូវសម្របសម្រួលទៅលើអនីតិជន ពោលគឺសំដៅទៅលើស្ថានភាពដែលទាក់ទងនឹងការជ្រើសរើសការងារមួយដ៏សមស្របសម្រាប់អនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល ការកែប្រែ ការអប់រំ និងការសម្រួលដល់ការបញ្ជូនខ្លួនអនីតិជនឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ។

***ចំណុចគួរកត់សម្គាល់៖*** បើពិនិត្យមើលទៅលើច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ត្រង់បញ្ញត្តិនៃមាត្រា ១៧៧ បានចែងអំពីការកំណត់អាយុ គឺត្រឹមតែអាយុ ១៥ (ដប់ប្រាំ) ឆ្នាំប៉ុណ្ណោះ ដែលអាចធ្វើការ ជាកម្មករនិយោជិតបាន "ការងារសម្រាប់ក្មេង" ហើយដោយហេតុថាការងារនេះ គឺជាការងារមួយដែលឱ្យអនីតិជនធ្វើហើយ គឺអាចផ្តល់នូវផលកម្រៃតបស្នងចំពោះអនីតិជននោះវិញ កម្រៃដែលទទួលបាននោះអាចយកទៅចិញ្ចឹមគ្រួសារ និងអនីតិជនខ្លួនឯងបានផងដែរ។ ដោយឡែកផ្សារភ្ជាប់ជាមួយនឹងការងារសហគមន៍ដែលយើងកំពុងតែសិក្សានេះ គឺគ្មានកម្រៃសម្រាប់ផ្តល់ឱ្យអនីតិជននោះទេ ដូចនេះបានជាច្បាប់កំណត់ត្រឹមអាយុ ១៦ ឆ្នាំ។

### ១.២.៤.ស្ថានសម្រាលទោសចំពោះអនីតិជន

យោងតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ គឺតុលាការអាចសម្រេចឱ្យជនជាប់ចោទទទួលបាននូវស្ថានសម្រាលទោស។ បើពិនិត្យទៅលើបទបញ្ញត្តិនៃមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ស្ថានសម្រាលទោសខាងលើនេះអាចយកទៅអនុវត្តលើគ្រប់បទល្មើសបានទាំងអស់[81]។

ស្ថានសម្រាលទោស គឺជាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទដែលញ៉ាំងឱ្យតុលាការសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស មានន័យថា ស្ថានសម្រាលទោស គឺជាការគិតគួររបស់តុលាការដោយផ្អែកទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះតម្រូវ ហើយការពិចារណានេះអាចតាមរយៈសាវតា ចំណេះដឹង អាកប្បកិរិយា ស្ថានភាពគ្រួសារ ឬមួយការសារភាពទទួលស្គាល់ទោសកំហុសដោយខ្លួនឯង និងគ្មានការបង្វិតបង្វំណាមួយឡើយ។ ដោយយោងទៅតាមមាត្រា ១៦៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពី ការទទួលប្រយោជន៍ ពីស្ថានសម្រាលទោស ដែលតុលាការបានសម្រេចឱ្យអនីតិជនបានទទួលនូវស្ថានសម្រាលទោសនោះ អប្បបរមានៃមូលទោសលើអនីតិជន ចំពោះបទឧក្រិដ្ឋ ឬមជ្ឈិមត្រូវបន្ថយ។ ក្នុងករណីនេះ តុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ[82] ៖

១. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ។

ឧទាហរណ៍៖ បទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ យោងទៅតាមមាត្រា ១៩៩ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជា អនីតិជន ដែលមានអាយុចាប់ពី ១៤

[81] *សូមមើល* មេរៀននីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ, ទំព័រ ៣៨៤

[82] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២២៦, ២៤

(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឱ្យតុលាការបន្ថយនូវ អប្បបរមានៃមូលទោសទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់ មានន័យថាអប្បបរមានៃទោស ១០ (ដប់) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ដូច្នេះ នៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ១ (មួយ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ សម្រាប់បទឃាតកម្ម។

២. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ។

ឧទាហរណ៍៖ បទល្មើសរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ យោងទៅតាមមាត្រា ២៣៩ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដោយយោងតាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ តម្រូវឱ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសលើបទល្មើសដែលត្រូវបានចោទប្រកាន់។ មានន័យថា អប្បបរមានៃទោស ៥ (ប្រាំ) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ៦ (ប្រាំមួយ) ខែ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ដូច្នេះ នៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ៦ (ប្រាំមួយ) ខែ ទៅ ១០ (ដប់) ឆ្នាំ សម្រាប់បទរំលោភសេពសន្ថវៈ។

៣. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំនោះ អប្បបរមាត្រូវបន្ថយមកត្រឹម ៣ (បី) ខែ។

ឧទាហរណ៍៖ បទគំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ) ឆ្នាំ យោងតាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឱ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់មានន័យថា អប្បបរមានៃទោស ២ (ពីរ) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ៣ (បី) ខែ ចំណែកឯអតិបរមានៃមូលទោសគឺ នៅដដែល។ ហេតុដូច្នេះនៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវយកមកផ្តន្ទាទោសគឺ ៣ (បី) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ សម្រាប់បទគំហែងយក។

៤. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ។

ឧទាហរណ៍៖ បទរំលោភលើលំនៅឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល យោងតាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឱ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោស ទៅលើបទល្មើស

ដែលត្រូវបានចោទប្រកាន់មានន័យថាអប្បបរមានៃទោស ១ (មួយ) ខែ ត្រូវបន្ថយ មកនៅត្រឹម ១ (មួយ) ថ្ងៃ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ហេតុដូច្នេះនៅពេលដែល ជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ១ (មួយ) ថ្ងៃ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១.០០០ (មួយពាន់) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល សម្រាប់បទរំលោភលើលំនៅឋាន[83]។

៥. អប្បបរមានៃទោសពិន័យត្រូវបន្ថយពាក់កណ្តាល។

សូមបញ្ជាក់ថានេះ គឺជាខ្នាតមួយដែលច្បាប់បានធ្វើការកម្រិត និងបញ្ញត្តិទុកសម្រាប់ឱ្យចៅក្រមយកទៅអនុវត្តលើករណីដែលអនីតិជនត្រូវទទួលបាននូវស្ថានសម្រាលទោស។ មូលហេតុដែលច្បាប់បានពង្រីកដែនអនុវត្តនូវស្ថានសម្រាលទោសទៅដល់អនីតិជនបែបនេះព្រោះថា នីតិករបានពិចារណាទៅលើអនីតិភាពនៃអនីតិជននេះឯង ដោយក្នុងគោលបំណងដើម្បីឱ្យអនីតិជនអាចទទួលបាននូវប្រយោជន៍គ្រួតគ្នាពីការកាត់បន្ថយទោសដោយស្វ័យប្រវត្តិ និងមានអានុភាពនៃការអនុវត្តដោយចៅក្រមនូវស្ថានសម្រាលទោសដូចគ្នាទៅនឹងខ្នាតដែលបានកម្រិតខាងលើ។

ក្នុងចំណុចនេះដែរគួរឱ្យកត់សម្គាល់ថា ទោះបីតុលាការរកឃើញថាអនីតិជន នោះបានប្រព្រឹត្តបទល្មើសដែលៗ ដោយស្ថិតក្នុងលក្ខខណ្ឌនៃការមិនរាងចាលក៏ដោយ ក៏តុលាការមិនអាចអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលដែរ ពោលគឺអនីតិជននោះនៅតែត្រូវទទួលបាននូវស្ថានសម្រាលទោសដដែល។ បន្ថែមពីនេះទៀតបទបញ្ញត្តិស្តីពីការមិនរាងចាល មិនត្រូវលើកយកមកអនុវត្តលើអនីតិជនបានឡើយ[84] មានន័យថា ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមិនរាងចាលក៏ដោយ ក៏តុលាការមិនអាចយកស្ថានទម្ងន់ទោសនេះមកអនុវត្តលើអនីតិជនបានឡើយ។

## ផ្នែកទី២ ការអនុវត្តទោស និងការផ្តល់នីតិសម្បទាអនីតិជនឡើងវិញ

### ២.១. ការអនុវត្តទោសចំពោះអនីតិជន

ការអនុវត្តទោស គឺជាដំណើរការនៃការអនុវត្តតាមនីតិវិធីដែលតុលាការបានធ្វើការផ្តន្ទាទោសចំពោះជនល្មើសពោលគឺ ក្រោយពីតុលាការធ្វើការប្រកាសទណ្ឌកម្មចំពោះទណ្ឌិតរួចហើយ។ ដោយយោងទៅតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន រាល់ការអនុវត្តទោសចំពោះអនីតិជនគឺត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទាដល់អនីតិជននោះតែប៉ុណ្ណោះ ហើយអនីតិជនមិនអាចត្រូវបានធ្វើការឃុំខ្លួន ឬអនុវត្តទោសដូចទៅនឹងនីតីជននោះទេ។ រាល់ការឃុំខ្លួនអនីតិជន គឺត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទា ការ

[83] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២០៣

[84] មាត្រា ៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឱ្យអនីតិជនក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[85]។

ក្នុងនោះដែរយើងឃើញថា មណ្ឌលយុវនីតិសម្បទាដែលត្រូវបានដាក់សម្ពោធកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ នៅឃុំបាគូរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កន្លងមកនេះឃើញថា ទទួលបានភាពល្អប្រសើរជាងមុនព្រោះថា មានកន្លែងច្បាស់លាស់សម្រាប់ដាក់អនីតិជន ម្យ៉ាងទៀតក៏មានគម្រោងនឹងផ្ទេរទណ្ឌិតជាអនីតិជនជាង ១ពាន់នាក់ទៅមណ្ឌលយុវនីតិសម្បទា ដើម្បីឱ្យអនីតិជនទទួលបានការបណ្តុះបណ្តាល និងការស្តារនីតិសម្បទារបស់អនីតិជនឡើងវិញ ហើយចំពោះការប្រកាសផ្ទេរទណ្ឌិតជាអនីតិជនក្នុងលក្ខណៈទ្រង់ទ្រាយធំនេះ គឺធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក **ស ខេង**[86]។ ជាមួយគ្នានេះដែរ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនក៏បានបញ្ញត្តិផ្តល់សិទ្ធិដល់តុលាការនៅក្នុងការប្រកាសទោស ចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសក្នុងស្ថានភាពបែបនេះផងដែរ ដែលមានបញ្ញត្តិត្រង់មាត្រា ៨៨ កថាខណ្ឌទី១ ដែលមានខ្លឹមសារក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលនីតិសម្បទា។ ដូចនេះការអនុវត្តទោសចំពោះអនីតិជនក្នុងស្ថានភាពបច្ចុប្បន្ន និងប្រព្រឹត្តទៅមានលក្ខណៈដូចខាងក្រោម៖

### ២.១.១. ការអនុវត្តទោសដាក់ពន្ធនាគារ

ពន្ធនាគារ សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ ដែលរួមមាន មណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែ[87]។ ការដាក់ពន្ធនាគារអនីតិជន ដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការចុងក្រោយបង្អស់ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ។ គោលបំណងចំពោះការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារ គឺដើម្បីធ្វើការអប់រំកែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាដល់ទណ្ឌិតដែលជាអនីតិជនតែប៉ុណ្ណោះ[88]។ ការដែលធ្វើបែបនេះ គឺក្នុងគោលដៅដើម្បីក្រោយពីការអនុវត្តទោសត្រូវបានបញ្ចប់រួច អាចឱ្យអនីតិជននោះចូលមករស់នៅក្នុងសង្គមដូចដើមវិញ។

---

[85] មាត្រា ៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[86] *សូមមើល* រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង លោកបានថ្លែងដូច្នេះក្នុងពិធីសម្ពោធមជ្ឈមណ្ឌលកាល នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

[87] មាត្រា ៤ ចំណុច ១ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[88] មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (វិធានជាបទដ្ឋានអប្បបរមានសំរាប់គ្រប់គ្រងវិស័យយុត្តិធម៌ ឆ្នាំ១៩៨៥)

### ២.១.២.សិទ្ធិរបស់អនីតិជនអំឡុងពេលអនុវត្តទោស

ក្នុងពេលអនុវត្តទោស អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ[89]៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្មរួមមាន ការដាក់ឱ្យនៅឯកា ការដាក់កំហិត ឬ បដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់ពិន័យ ដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុងអំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ឬការដោះលែង ទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខលក្ខណៈឯកជនពីសមាជិកគ្រួសារ ឬមិត្តភក្តិ[90]
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធិភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

### ២.១.៣. ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ

ការឃុំឃាំងក្នុងពន្ធនាគារ គឺជានីតិវិធីមួយដែលធ្វើការឃុំអនីតិជន ឱ្យជាប់ឃុំឃាំងក្នុងបន្ទប់ឃុំឃាំង ហើយការដែលឃុំឃាំងនេះទៀតសោតត្រូវបានបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំឃាំងនីមួយៗនោះផងដែរ។ ជនដែលជាប់ឃុំឃាំង សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួនក្នុងពន្ធនាគារ តាមដីកាឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ[91]។ ជនជាប់ឃុំជាអនីតិជន ដែលជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជនត្រូវដាក់បំបែកពីជនជាប់ឃុំ ជាទណ្ឌិត[92]។

---

[89] មាត្រា ៨០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[90] មាត្រា ៥៥ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[91] មាត្រា ៤ ចំណុច៣ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[92] មាត្រា ២៦ នៃព្រះរាជក្រមយោងខាងលើ

ក្រៅពីនេះ ជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកពីជនជាប់ឃុំជាបុរស និងចំពោះជនជាប់ឃុំដែលមានជម្ងឺឆ្លង ក៏ត្រូវដាក់បំបែកដោយឡែក ពីជនជាប់ឃុំដទៃទៀតផងដែរ។ គួរកត់សម្គាល់ដែរថា ការបែងចែកការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារទៅតាមប្រភេទដូចខាងលើនេះ គឺមានលក្ខណៈខុសពីគ្នា ត្រង់ការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ដោយការអនុវត្តចំពោះអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបានបែកចែកជាបីផ្នែកដូចខាងក្រោមវិញគឺ[93]

១. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន

២. ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលយកកម្មវិធីស្តារនីតិសម្បទា

៣. ផ្នែកសម្រាប់ដោះលែងអនីតិជន ដើម្បីទទួលយកកម្មវិធីសមាហរណកម្ម

មួយវិញទៀតក្រៅពីបែងចែកផ្នែកសម្រាប់គ្រប់គ្រងអនីតិជនហើយ ក៏ត្រូវរក្សាអនីតិជនដាច់ដោយឡែកពីនីតិជនផងដែរ ពោលគឺត្រូវដាក់ក្នុងទីតាំងដាច់ដោយឡែកទៅតាមភេទផ្សេងៗគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់អនីតិជននោះ។ ក្នុងករណី អនីតិជនជា ភេទស្រីវិញ គឺត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលដែលមានភេទស្រីដូចគ្នា ហើយចំពោះអនីតិជនដែលមានជំងឺឆ្លងវិញ ត្រូវដាក់នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកពីអនីតិជនផ្សេងៗផងដែរ។ បន្ថែមពីនេះទៀត ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវរក្សាទុកក្នុងមណ្ឌលយុវនីតិសម្បទាបន្តរហូតដល់អាយុ ២៤ (ម្ភៃបួន) ឆ្នាំ។ ក្នុងពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរឱ្យអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំឃាំងសម្រាប់នីតិជនវិញ[94]។ ដោយឡែកអ្វីដែលបានលើកឡើងខាងលើអំពីការអនុវត្តទោសចំពោះអនីតិជន ក្នុងមណ្ឌលយុវនីតិសម្បទានេះ គឺជាសញ្ញាណថ្មីមួយនៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ដែលនឹងត្រូវលើកយកមកអនុវត្តចំពោះអនីតិជននៅពេលខាងមុខ។

ជាក់ស្តែងស្ថានភាពបច្ចុប្បន្នសង្កេតឃើញថា មណ្ឌលយុវនីតិសម្បទា ដែលកំពុងដំណើរការសាកល្បង គឺមានតែមួយប៉ុណ្ណោះ ដែលមានទីតាំងស្ថិតនៅក្នុងទឹកដីខេត្តកណ្តាល។ ជាបន្ទាប់មកទៀតនេះ យើងនឹងអាចសិក្សាបន្តពីការផ្តល់នីតិសម្បទា ក៏ដូចជាការបង្កើតមណ្ឌលយុវនីតិសម្បទាសម្រាប់គ្រប់គ្រងអនីតិជន ។

[93] មាត្រា ៧៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[94] មាត្រា ៨២ កថាខណ្ឌទី២ នៃព្រះរាជក្រមយោងខាងលើ

## ២.២. ការផ្តល់ និងការស្តារនីតិសម្បទា

បន្ទាប់ពីអនីតិជន បានអនុវត្តទោសរួចរាល់ចប់សព្វគ្រប់ហើយនោះ ឬពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឱ្យមានលក្ខខណ្ឌនៃការផ្តល់ និងការស្តារនីតិសម្បទាឡើងវិញ ចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើសដែលមានដូចតទៅៈ

### ២.២.១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

យោងតាមមាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានចែងថាពាក្យសុំឱ្យមាននីតិសម្បទាឡើងវិញ អាចដាក់ជូនសភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ពិនិត្យបានដោយទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន ឬធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលទណ្ឌិតជាអនីតិជន[95] ។ តាមរយៈការលើកឡើងនេះដែរ គឺការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឱ្យ ឬមិនត្រូវបានផ្តល់ឱ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។ លក្ខខណ្ឌលើរយៈពេលទាក់ទងទៅនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ អាចដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាន លុះត្រាតែផុតរយៈពេលដូចខាងក្រោមៈ

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម និង១ (មួយ) ខែ ចំពោះបទលហុ។

រយៈពេលនេះ ត្រូវចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬទោសត្រូវបានផុតអាជ្ញាយុកាល[96]។ ពាក្យសុំនេះអាចត្រូវបានធ្វើឡើងដោយ ទណ្ឌិតជានីតិជន ដែលបានប្រព្រឹត្តបទល្មើស នៅពេលខ្លួនជាអនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន។

អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវធ្វើពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។ ត្រូវធ្វើការចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួន ត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ។

បន្ទាប់ពីបានទទួលពាក្យសុំហើយនោះ ព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែង។ ជាមួយគ្នាដែរព្រះរាជអាជ្ញា សុំឱ្យគេប្រគល់មកខ្លួននូវៈ

- លិខិតចម្លង នៃសេចក្តីសម្រេចផ្តន្ទាទោស
- លិខិតជូនដំណឹង អំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

[95] មាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[96] មាត្រា ៧៤ កថាខណ្ឌទី ២ នៃព្រះរាជក្រមយោងខាងលើ

- ព្រឹត្តបត្រលេខ ១ នៃបញ្ជីថ្កោលទោស។

ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿង ដោយមានយោបល់ និងសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់ពីអគ្គព្រះរាជអាជ្ញា បានទទួលការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាហើយនោះ អគ្គព្រះរាជអាជ្ញា ប្ដឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ហើយជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្ដឹង និងមេធាវី។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងពីអគ្គព្រះរាជអាជ្ញា តុលាការត្រូវ សម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា[97]។ បន្ថែមពីនេះទៀត បើពាក្យសុំនោះត្រូវបានតុលាការបដិសេធ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល ២ (ពីរ) ឆ្នាំបានឡើយ។ ក្នុងករណីដែលពាក្យសុំលើកទីមួយត្រូវបានតុលាការធ្វើការបដិសេធដោយសារការមិនគ្រប់រយៈពេលដូចដែលមានចែងក្នុងមាត្រា ៧៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន នោះពាក្យសុំអាចធ្វើថ្មីបានចាប់ពីការផុតកំណត់រយៈពេលនោះ។

### ២.២.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

រយៈពេលនៃការចាប់ផ្ដើមនីតិសម្បទា គឺគិតចាប់ពីការអនុវត្តទោសរួច ឬនៅពេលដែលទោសត្រូវបានផុតអាជ្ញាយុកាល។ យោងទៅតាមមាត្រា ៧៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានបញ្ញត្តិថាការមាននីតិសម្បទាឡើងវិញតាមច្បាប់កំណត់គឺនៅពេលផុតរយៈពេល[98]៖

- ៣ (បី) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

ដូចក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទឃាតកម្ម នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ហើយត្រូវបានតុលាការប្រកាសឱ្យអនុវត្តទោស ២ឆ្នាំ ៦ខែ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ហើយអនីតិជនបានអនុវត្តទោសចប់សព្វគ្រប់ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៩។ ដូច្នេះ ការទទួលបាននីតិសម្បទាឡើងវិញដោយតាមលក្ខណៈច្បាប់មិនតម្រូវឱ្យអនីតិជននោះ ឬអ្នកតំណាងដែលច្បាប់កំណត់ដាក់ពាក្យសុំទៅសភាព្រហ្មទណ្ឌនោះទេ ដោយគ្រាន់តែទុកឱ្យផុតរយៈពេល ៣ឆ្នាំ, ១ឆ្នាំ, ៣ខែ ចំពោះបទល្មើស ដែលអនីតិជនបានប្រព្រឹត្ត គិតចាប់ពីថ្ងៃអនុវត្តទោសរួច ឬពេលទោសផុតអាជ្ញាយុកាល។

- ១ (មួយ) ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី) ខែ ចំពោះបទលហុ។

ជាគោលការណ៍អនីតិជនដែលទទួលបាននីតិសម្បទាឡើងវិញគឺ ត្រូវបានលុបលាងចោលទណ្ឌកម្ម

[97] មាត្រា ៥៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[98] មាត្រា ៧៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ព្រហ្មទណ្ឌទាំងអស់ ហើយត្រូវបានគេលុបចេញពីបញ្ជីថ្កោលទោសផងដែរ។ ទាក់ទងនឹងកំណត់ហេតុ និងសំណុំរឿងឯកសារផ្សេងៗដែលពាក់ព័ន្ធអនីតិជន ត្រូវបានរក្សាជាការសម្ងាត់។

### ២.២.៣. សមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

មណ្ឌលយុវនីតិសម្បទាត្រូវបង្កើតនៅតាម រាជធានី ខេត្ត សម្រាប់ធ្វើការគ្រប់គ្រងអនីតិជន ហើយមណ្ឌលយុវនីតិសម្បទានេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។ ចំពោះការបែងចែកការគ្រប់គ្រងអនីតិជន ក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែក ដាច់ដោយឡែកពីគ្នា[99]៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជន បណ្ដោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជន ដើម្បីទទួលកម្មវិធីស្ដារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

គ្រប់មណ្ឌលយុវនីតិសម្បទាត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ការចុះឈ្មោះ និងគ្រប់គ្រងអនីតិជនព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាសុវត្ថិភាព។ បន្ថែមពីនេះបញ្ជី និងនីតិវិធីដោយឡែកនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យ សង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

បែបបទនៃការគ្រប់គ្រងអនីតិជន ក្នុងមណ្ឌលយុវនីតិសម្បទាដែលជាប់ឃុំ និងនីតិវិធីនៃការផ្ទេរ ឬការប្រគល់ និងការទទួលអនីតិជនត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[100]។

គួរកត់សម្គាល់ដែរថា ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា[101]។

### ២.២.៤. ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា

ភ្នាក់ងារដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា មន្ត្រីយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្ដុះបណ្ដាលត្រឹមត្រូវ អំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្ដីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព។

---

[99] មាត្រា ៧៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦

[100] មាត្រា ៨៨ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦

[101] មាត្រា ៨៨ កថាខណ្ឌទី១ នៃព្រះរាជក្រមយោងខាងលើ

ចំពោះមន្ត្រី ឬបុគ្គលិកមណ្ឌលយុវនីតិសម្បទាមិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឱ្យដាក់ ពិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសឡើយ។ បន្ថែមពីនេះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួន ត្រូវបានអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ[102]។

លើសពីនេះទៅទៀតអនីតិជនដែលកំពុងជាប់ឃុំក្នុងមណ្ឌលយុវនីតិសម្បទា ក៏ត្រូវបានទទួលនូវសេវាដែលផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកនៅមណ្ឌលយុវនីតិសម្បទាទាំងអស់ដូចខាងក្រោម[103]៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ
- សុខភាពផ្លូវកាយ និងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ដោយត្រូវចុះក្នុងសំណុំរឿងរបស់អនីតិជនជាប់ឃុំនៃព័ត៌មានអំពីស្នាមរបួស ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត[104]
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង និងលើកទឹកចិត្តឱ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឱ្យមានអាកប្បកិរិយា និងជំនាញដែលជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួន ក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម និងអាចជួយឱ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញ បន្ទាប់ពីបានដោះលែង។

## ២.៣. ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវបានផ្តល់ឱ្យទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា។ ក្នុងនោះដែរដើម្បីលើកឡើងឱ្យមានការដោះលែងដោយមានលក្ខខណ្ឌនេះ យកមកអនុវត្តបាន គឺច្បាប់ត្រូវកំណត់ដោយឱ្យបុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌរួមមានទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌល

[102] មាត្រា ៨៥ នៃយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[103] មាត្រា ៨១ នៃព្រះរាជក្រមយោងខាងលើ

[104] មាត្រា ២៤ វាក្យខណ្ឌទី ២ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

យុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជន ឬបេសកកម្មទូត ឬកុងស៊ុលបរទេសក្នុងករណីអនីតិជនជាជនបរទេស[105]។

ដើម្បីអាចឱ្យមានការដោះលែងដោយមានលក្ខខណ្ឌអាចយកមកអនុវត្តបាននោះ ច្បាប់បានកំណត់អំពីលក្ខខណ្ឌ និងអាជ្ញាធរដែលមានសមត្ថកិច្ច ដូចតទៅនេះ៖

**លក្ខខណ្ឌទាក់ទងនឹងបុគ្គល**

បុគ្គល ដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជន ដោយមានលក្ខខណ្ឌរួមមាន ៖

- ទណ្ឌិត ដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា
- ភ្នាក់ងារសង្គមកិច្ច ដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស[106]។

**លក្ខខណ្ឌទាក់ទងនឹងគំនិត មារយាទ និងការទទួលរងទោស**

គ្រប់ទណ្ឌិតដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមួយ ឬច្រើនអាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមាននីតិសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ លើសពីនេះ ការដោះលែងដោយមានលក្ខខណ្ឌអាចផ្ដល់ទៅឱ្យទណ្ឌិតជាអនីតិជន ដែលបានទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោស តិចជាង ឬស្មើ ១ឆ្នាំ
- ចំនួនពាក់កណ្ដាលនៃទោស ក្នុងករណីផ្សេងទៀត[107]។

**អាជ្ញាធរមានសមត្ថកិច្ច ដែលផ្ដល់ការដោះលែងដោយមានលក្ខខណ្ឌ**

ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្ដល់ដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងត្រូវបញ្ជូនទៅគណៈកម្មការជាតិនូវ ៖

១. ពាក្យសុំ

២. សាលក្រម ឬសាលដីកាផ្ដន្ទាទោស

[105] មាត្រា ៧២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[106] មាត្រា ៧៣ នៃព្រះរាជក្រមយោងខាងលើ

[107] មាត្រា ៧២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

៣. ជាយថាហេតុ សាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន

៤. ព្រឹត្តប័ត្រលេខ ១ នៃបញ្ជីថ្កោលទោស

៥. យោបល់ព្រះរាជអាជ្ញា និងគ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍។

គណៈកម្មការជាតិ បញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយោបល់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម[108]។

សូមបញ្ជាក់ដែរថា សមាជិកគណៈកម្មការជាតិរួមមាន[109]៖

- សមាជិក ២ រូប ចាត់តាំងដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ១ រូបជាប្រធាន
- ប្រធានពន្ធនាគារ ឬតំណាងជាសមាជិក។

[108] មាត្រា ៥១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[109] មាត្រា ៥១៤ នៃព្រះរាជក្រមយោងខាងលើ

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សា ស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទស្តីពី "**យុត្តិធម៌សម្រាប់អនីតិជនអាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទល្មើស**" យ៉ាងក្បោះក្បាយរួចមកបានបង្ហាញឱ្យយើងឃើញថា អនីតិជន គឺជាជនដែលស្ថិតនៅវ័យមួយដែលកំពុងលូតលាស់ទាំងផ្នែកសរីរាង្គ និងផ្នែកបញ្ញាស្មារតី គឺនៅមានកម្រិត ដែលជាហេតុធ្វើឱ្យអនីតិជនមិនមែនសមត្ថភាពគិតពិចារណាទៅលើមជ្ឈដ្ឋានជុំវិញខ្លួន ក៏ដូចជាផលអវិជ្ជមានដែលកើតមានឡើងចំពោះខ្លួនបានច្បាស់លាស់ផងដែរ។ ដោយហេតុថា អនីតិជនពុំទាន់មានលក្ខណៈវិនិច្ឆ័យទៅលើអំពើដែលខ្លួនបានប្រព្រឹត្តបែបនេះ ទើបតុលាការ បានធ្វើការពិចារណាក៏ដូចជាផ្តល់សិទ្ធិការពារពិសេសដែលធានាដោយច្បាប់ ក្នុងករណីអនីតិជនបានប្រព្រឹត្តអំពើល្មើសណាមួយ។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែពិនិត្យ និងពិចារណាទៅលើកត្តាទាំងអស់នោះឱ្យបានច្បាស់លាស់ដើម្បីធ្វើការសន្ទត់ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ក៏ដូចជាធ្វើការអនុវត្តដាច់ខាតទៅតាមនីតិវិធីកុមារមេត្រី ក្នុងការស្រាវជ្រាវ និងពិនិត្យអំពីបទល្មើសដែលប្រព្រឹត្តដោយអនីតិជន។

ដើម្បីឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់អនីតិជន យើងឃើញថា កម្ពុជា បានបង្កើតឱ្យមានច្បាប់ស្តីពីយុត្តិធម៌អនីតិជនឡើងក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍ និងផ្តល់ឱកាសសម្រាប់អនីតិជន កសាងខ្លួនចូលទៅក្នុងសង្គមជាថ្មី។ ជាងនេះទៅទៀត ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានផ្តល់អាទិភាព និងការការពារដល់អនីតិជនជាចម្បងទាក់ទងនឹងនីតិវិធីនៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសតាំងពីដំណាក់កាលនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលជំនុំជម្រះ ឬអាចនិយាយបានម្យ៉ាងទៀតថា នីតិវិធីដែលអនុវត្តចំពោះអនីតិជនគឺជានីតិវិធីដែលមានលក្ខណៈកុមារមេត្រី និងជានីតិវិធីដែលល្អបំផុតសម្រាប់យកអនុវត្តលើរឿងក្តីអនីតិជន។

នីតិវិធីកុមារមេត្រីបានផ្តល់ឱ្យអនីតិជន ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពិសេសគឺផ្តោតសំខាន់ទៅដល់ការបង្វែរអនីតិជនចេញពីប្រព័ន្ធតុលាការ ព្រោះថាកាលណាបើអនីតិជនត្រូវបានតុលាការសម្រេចឱ្យទទួលខុសត្រូវលើអំពើល្មើសវាអាចនឹងផ្តល់ព្យសនកម្មធ្ងន់ធ្ងរដល់សភាពផ្លូវចិត្ត ក៏ដូចជាអាចធ្វើឱ្យអនីតិជនរូបនោះប៉ះពាល់ដល់អនាគតទៅថ្ងៃមុខផងដែរ ហេតុដូចនេះហើយបានជាច្បាប់តម្រូវឱ្យមានការពិចារណាជាមុនទៅលើវិធានការបង្វែរមុននឹងសម្រេចចិត្តផ្តន្ទាទោសទៅលើអនីតិជន ។ ក្រឡេកមកមើលវិធានការបង្វែរវិញ គឺជាវិធានការដែលបង្វែរអនីតិជនដែលបានប្រព្រឹត្តបទល្មើស ចេញពីតុលាការដោយការប្រគល់អនីតិជននោះទៅកាន់អ្នកមានអំណាចមេបា ឬអ្នកដែលមានសម្បទាក្នុងការគ្រប់គ្រងអនីតិជន ដើម្បីឱ្យអនីតិជនអាចកែប្រែខ្លួនទទួលយកកំហុស ក៏ដូចឱ្យអនីតិជនអាចបន្តការសិក្សា ការងារ ហើយពិសេសនោះគឺ អនីតិជនក៏នឹងមិនមែនឈ្មោះក្នុងកំណត់ត្រាថ្កោលទោសផងដែរ ប្រសិនបើអនីតិជនត្រូវបានផ្តល់ឱ្យនូវវិធានការបង្វែរ។

ជាមួយគ្នានេះក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយត្រូវបានតុលាការពិចារណា និងពិនិត្យទៅឃើញថា កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃអនីតិជននោះតម្រូវ គឺតុលាការអាចសម្រេចឱ្យអនីតិជនទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានប្រព្រឹត្ត ហើយការសម្រេចដាក់ទណ្ឌកម្មនេះ គឺត្រូវតែជាវិធានការចុងក្រោយដែលអាចយកមកអនុវត្តលើអនីតិជន។

នីតិវិធីដែលអនុវត្តទោសព្រហ្មទណ្ឌចំពោះអនីតិជន ក៏មានលក្ខណៈពិសេសខុសពីនីតិជនផងដែរ ដោយហេតុថា នៅពេលដែលតុលាការប្រកាសទោសឱ្យជាប់ពន្ធនាគារ ទោសដែលអាចអនុវត្តចំពោះអនីតិជនបានគឺត្រូវស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុត ឬត្រូវតែកម្រិតមកត្រឹមពាក់កណ្តាលនៃទោសដែលត្រូវអនុវត្តចំពោះនីតិជន។ ទន្ទឹមនឹងនេះដែរ យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានលើកទឹកចិត្តក្នុងការយកអនីតិជនទៅរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាដែលមានលក្ខណៈដាច់ដោយឡែកពី នីតិជន ហើយស្ថិតនៅអគារដោយមានការបែងចែកច្បាស់លាស់ ទៅតាមភេទ ប្រភេទ ស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ជាជាងការយកអនីតិជនដាក់ក្នុងពន្ធនាគារ ។ បច្ចុប្បន្ននេះ យើងក៏បានដឹងដែរថា មណ្ឌលយុវនីតិសម្បទា ទើបតែដាក់សម្ពោធឱ្យប្រើប្រាស់កាលពីឆ្នាំកន្លងទៅមិញ កំពុងតែគ្រោងដាក់ អនីតិជនដែលបានប្រព្រឹត្តបទល្មើសជាង ១០០០ នាក់ យកទៅរក្សានៅទីនោះ ។ បើទោះបីជា មណ្ឌលយុវនីតិសម្បទាទើបតែសាងសង់ហើយថ្មីៗ និងកង្វះខាតតម្រូវការផ្សេងៗក៏ដោយ ក៏មណ្ឌលយុវនីតិសម្បទា បានជួយសម្រួលច្រើនទៅលើការយកអនីតិជនចេញពីពន្ធនាគារ ឱ្យមករក្សានៅទីកន្លែងដែលសមស្របសម្រាប់អនីតិជន។

ចំណុចដែលបានរៀបរាប់ខាងលើ បានបង្ហាញអំពីការយកចិត្តទុកដាក់របស់តុលាការចំពោះ សិទ្ធិ និងការអនុវត្តនីតិវិធីទៅតាមដំណាក់កាល ក៏ដូចជាការអនុវត្តទោសចំពោះកុមារក្នុងករណីប្រព្រឹត្តបទល្មើសបានសមស្រប និងបានគិតគូរអំពីការរីកលូតលាស់របស់អនីតិជន ដើម្បីផ្តល់ឱ្យអនីតិជនមានឱកាសក្នុងការកសាង និងកែប្រែខ្លួន មកក្លាយជា ពលរដ្ឋល្អ កូនល្អ សិស្សល្អ និងជាធនធានដែលប្រកបដោយសមត្ថភាពសម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិឱ្យមានការរីកចម្រើន។

# អនុសាសន៍

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថាការអនុវត្តច្បាប់នៅប្រទេសកម្ពុជា គឺមានការវិវត្តពីមួយដំណាក់កាលទៅមួយដំណាក់កាលក៏ដូចជាឃើញថា ការអនុវត្ត គឺមានភាពល្អប្រសើរជាងមុនផងដែរ ព្រោះថាដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះអនីតិជន ជាពិសេសក្នុងបញ្ជីថ្កោលទោសគឺ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងគិតគូរដល់សិទ្ធិកុមារ ដោយបានផ្តល់ជាគោលការណ៍ ក្នុងការដឹកនាំតាក់តែងឱ្យមានច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះឡើង។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦ សំដៅលើប្រព័ន្ធយុត្តិធម៌ដែលផ្តោតសំខាន់លើការបង្វែរ ជាជាងការដាក់ទណ្ឌកម្មឱ្យជាប់ឃុំ ដើម្បីផ្តល់ឱកាសសម្រាប់អនីតិជន កសាងអនាគត និងក្លាយខ្លួនជាពលរដ្ឋល្អទៅថ្ងៃមុខ ហើយក៏មានការទទួលស្គាល់ជាអន្តរជាតិផងដែរថាការបង្វែរចេញពីប្រព័ន្ធព្រហ្មទណ្ឌ ចេញពីកន្លែងឃុំឃាំង គឺជាយន្តការដ៏ល្អប្រសើរសម្រាប់កុមារមិនឱ្យប្រព្រឹត្តបទល្មើសសារជាថ្មីម្តងទៀត។ មិនត្រឹមតែប៉ុណ្ណោះ អនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានតុលាការធ្វើការផ្តន្ទាទោសតាមរយៈការដាក់ក្នុងពន្ធនាគារ ឬក៏ក្នុងមណ្ឌលយុវនីតិសម្បទា ឬមានទណ្ឌកម្មផ្សេងទៀត ត្រូវបានច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ បានផ្តល់ឱ្យនូវសិទ្ធិយ៉ាងច្រើនសន្ធឹកសន្ធាប់តាមរយៈក្រមព្រហ្មទណ្ឌ ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ រួមនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ផ្សេងទៀតៗ ជាពិសេសនោះគឺ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដូចដែលបានរៀបរាប់ខាងលើ។

យើងសង្កេតឃើញថា ទោះបីជាតុលាការបានធ្វើការអនុវត្តទោសលើអនីតិជនដោយយោងទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ជាពិសេសនោះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីការពារនូវឧត្តមប្រយោជន៍របស់អនីតិជនយ៉ាងណាក៏ដោយ ក៏ការអនុវត្តទាំងអស់នោះ គឺនៅតែមានភាពខ្វះចន្លោះ ឬកង្វះខាតមួយចំនួនផងដែរ។

ក្នុងនោះយើងសង្កេតឃើញថា កង្វះខាតទាំងអស់នោះរួមមាន កត្តាសម្ភារ កត្តាធនធានមនុស្ស ការយល់ដឹងពាក់ព័ន្ធនឹងអនីតិជន និងយន្តការក្នុងការអនុវត្តឱ្យមានប្រសិទ្ធិភាពទៅលើអនីតិជន ដែលត្រូវបានរកឃើញថាបាន ឬមិនបានប្រព្រឹត្តបទល្មើស។

រាល់បញ្ហាដែលបានរៀបរាប់ខាងលើនេះ គឺទាមទារឱ្យមានដំណោះស្រាយយ៉ាងល្អប្រសើរ និងម៉ត់ចត់មួយចំនួនដូចជា៖

- ពង្រីកការផ្សព្វផ្សាយផ្នែកច្បាប់ដែលពាក់ព័ន្ធទៅនឹងអនីតិជនឱ្យបានទូលំទូលាយទៅដល់មជ្ឈដ្ឋានទាំងអស់ ទាំងអាជ្ញាធរ អង្គការក្នុងស្រុក រួមទាំងប្រជាពលរដ្ឋដើម្បីឱ្យមានការយល់ដឹង
- ជំរុញឱ្យមានកម្មវិធីអប់រំទាក់ទងនឹងប្រព័ន្ធយុត្តិធម៌ក្នុងប្រព័ន្ធអប់រំដើម្បីញ៉ាំងឱ្យពួកគេមានការយល់ដឹងកាន់តែច្បាស់អំពីកម្រិតនៃបទល្មើស

- ពង្រឹងនូវការអនុវត្តនីតិវិធីទៅតាមដំណាក់កាលនីមួយៗ ដើម្បីធានាថា គ្រប់ដំណាក់កាលដែលប្រព្រឹត្តទៅពិតជាសមស្របតាមលក្ខណៈនីតិវិធីកុមារមេត្រី
- ជំរុញឱ្យមានការបង្កើតមណ្ឌលឃុំនីតិសម្បទានៅតាមបណ្តារាជធានី ខេត្ត ឱ្យបានគ្រប់គ្រាន់ ពិសេសគឺទៅតាមខេត្តនីមួយៗ
- ជំរុញឱ្យមានការបង្កើតតុលាការជំនាញលើរឿងក្តីអនីតិជន
- ជំរុញឱ្យស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នតុលាការ ដែលជាស្ថាប័នមួយក្នុងការកំណត់បទល្មើស ពិរុទ្ធភាពនៃបទល្មើស តាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ស្តីពីយុត្តិធម៌អនីតិជនធ្វើការអនុវត្តដោយយកចិត្តទុកដាក់ជាទីបំផុតដោយស្របតាមការអនុលោមនៃច្បាប់
- បណ្តុះបណ្តាលដល់ជំនាញឯកទេស ស្តីពីការអនុវត្តនីតិវិធីបែបកុមារមេត្រីសម្រាប់នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងតុលាការ រួមទាំងស្ថាប័នពាក់ព័ន្ធនឹងអនីតិជន
- ជំរុញ និងលើកទឹកចិត្តដល់មន្ត្រីពន្ធនាគារដែលស្ថិតនៅតំបន់សមត្ថកិច្ចគ្រប់គ្រង យកចិត្តទុកដាក់ចំពោះសិទ្ធិរបស់អនីតិជន ដែលត្រូវបានជាប់ឃុំ។

# ឯកសារយោង

## ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះនៅថ្ងៃទៅ១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៤. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

៥. ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១

៦. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

៧. អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុម័តដោយអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩

៨. អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ដែលបោះពុម្ពដោយមូលនីធិប្រជាជាតិដើម្បីកុមារ

៩. កតិកាសសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦។

## ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ

១. មេរៀននីតិព្រហ្មទណ្ឌទូទៅ, លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ឆ្នាំ ២០១២

២. មេរៀននីតិវិធីព្រហ្មទណ្ឌ, លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ឆ្នាំ២០១៣-២០១៤

៣. មេរៀនទោសព្រហ្មទណ្ឌ, សាស្ត្រាចារ្យ កៅ សីហា, ឆ្នាំ០១១

៤. មេរៀនចិត្តវិទ្យាវ័យជំទង់, លោក គឹម ចាន់ណា, បោះពុម្ពលើកទី២ ឆ្នាំ២០១០

៥. មេរៀននីតិព្រហ្មទណ្ឌទូទៅ, លោកសាស្ត្រាចារ្យ ហ៊ី សោភា, បោះពុម្ពឆ្នាំ២០១២

៦. មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឆ្នាំ២០០៨

៧. សៀវភៅផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៨-២០១៩

៨. សៀវភៅស្តីពីជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារកុមារនៅកម្ពុជារបស់អង្គការជីវិតនៅកម្ពុជា

៩. ឯកឧត្តមរដ្ឋមន្ត្រី វង សូត អញ្ជើញចុះពិនិត្យ សមិទ្ធផលចំនួន៣ នៅឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០២១

១០. ភ្នំពេញប៉ុស្តិ៍បានសម្ភាសជាមួយលោក យុង ផានិត អនុប្រធាននាយកដ្ឋានការពារក្តីជនក្រីក្រនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

១១. ទិន្នន័យគាំទ្រលើអំណះអំណាងសម្រាប់ការអនុវត្តលើផែនការបង្វែរជំនួសឱ្យការដាក់ក្នុងពន្ធនាគារ

១២. សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១

១៣. បទបង្ហាញស្តីពី "*ការបង្វែរ* របស់លោកមេធាវី អ៊ុប វិបុល។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

១. កំណត់ហេតុចាប់យក

២. កំណត់ហេតុសួរចម្លើយ

៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

៤. ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

៥. ដីកាលើកលែងចោទប្រកាន់

៦. ដីកាសម្រេចបញ្ជូនសំណុំរឿងជំនុំជម្រះ

៧. គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

៨. សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

៩. ការបង្វែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

ក-1292/02-12-2015


អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខ 1324 អ.យ.ទ


# កំណត់ហេតុទទួលវត្ថុចាប់យក

ពីពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសាមសិប នាទី។

យើង ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាអ្នកទទួល។

លោក ជាមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ រួមជាមួយឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាជនសង្ស័យ។

បានពិនិត្យកិនកាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ឃើញដូចខាងក្រោម៖

✓១- ម៉ូតូមួយគ្រឿងម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់ ហើយមានតែតួ)

២- ញញួរចំនួន០២, ដែកដាប់ចំនួន០៣, ដែកគាស់ចំនួន០១, កន្ត្រៃចំនួន០៦, កូនកាំបិតចំនួន០២, កាំបិតប៉ុងតោចំនួន០៤, ដាវចំនួន០១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន០១។

៣- អង្កួចងចាំចំនួន០១។

យើងធ្វើកំណត់ហេតុនេះ ទុកជាភស្តុតាង ដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ តាមផ្លូវច្បាប់តទៅ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបី និងសែសិបប្រាំ នាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

| ជនជាប់សង្ស័យ | អ្នកប្រគល់ | អ្នកទទួល |
| --- | --- | --- |

បានឃើញ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

បានទទួលគម្រប់វត្ថុចាប់យក (ឃុំ)

ចុះថ្ងៃទី02-12-2015

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

## <u>កំណត់ហេតុសួរចម្លើយ</u>

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដឹកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (ស្លាប់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្តាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 កូរ៉េ ឆ្នើស ពណ៌ក្រហម ទៅឈ្មោះ ខ្ចីយកជិះទៅធ្វើសកម្មភាពគាស់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្តង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូមខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្តាប់ សាម៉ីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្តិតម្រាមដៃជាមួយយើង។

អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

## កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ . ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបររើសអេតចាយ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) ជាអនីតិជន ទោសពីមុនគ្មាន។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៣ និង ១៥ នាទីយប់រំលងអាធ្រាតចូលថ្ងៃទី ០៩.១០.២០១៥ ខ្ញុំបាទ និងបក្ខពួកប្អូននាក់ទៀតមានឈ្មោះ បង បង: បង ជិះម៉ូតូរ៉ឺម៉ក់អេតចាយ ទៅធ្វើសកម្មភាព គាស់សោរទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃប្រាកដមែន។ ហើយពួកខ្ញុំលួចបានទូដែកមួយមានប្រាក់ជាច្រើនមិនដឹងប៉ុន្មានទេ ហើយ ឈ្មោះ បានចែកប្រាក់អោយខ្ញុំបាទ ៦០០០ដុល្លារអាមេរិក ខ្ញុំបាទក៏បានផ្ញើទៅប្រពន្ធគាត់ ៤០០០ដុល្លារ ហើយទុក២០០០ដុល្លារចែកអ្នកជិតខាងផ្ទះ។ ចំពោះឯកសារនៅក្នុងទូដែកឈ្មោះ ចយ បានច្រកបាវ ដុតចោលអស់ហើយ ចំនែកទូដែក ខ្ញុំបាទពុំដឹងថានៅទីណាទេ។ រីឯអ្នកផ្សេងទៀត បានចំនែកម្នាក់[redacted]នៅប៉ុន្មានគឺឈ្មោះ យកទាំងអស់។

សួរ.ចម្លើយ៖ បក្ខពួករបស់ខ្ញុំខាងលើបានរត់គេចខ្លួនអស់ហើយ ខ្ញុំបាទពុំដឹងថាទៅទីណាទេ។

សួរ.ចម្លើយ៖ កន្លងមកខ្ញុំបាទធ្លាប់វាយសមត្ថកិច្ចប៉ូលីស ហើយត្រូវបានបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ និងប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៤៥៩៤ អ.យ.ទ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[1] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយពារអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្តីឈ្មោះ ហៅ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[2] ÷**

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក

---

[1] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[2] សេចក្តីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពយកទួរឡឺវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ បានយកប្រាក់ចំនួន ៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ ។ ចំណែកជនសង្ស័យឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ ឈ្មោះ ហៅចយ ឈ្មោះ ឈ្មោះ និងឈ្មោះ ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>ហេតុដូច្នេះសម្រេច</u>

- បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤]៖ ..............................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៥]៖

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- : ហៅ ភេទប្រុស (គេចខ្លួន)

៣- . ភេទប្រុស (គេចខ្លួន)

៤- . ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ៖ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- . ភេទស្រី ពីបទ ទទួលផលចោរកម្ម

- ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖
  - បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
  - ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
  - រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី <u>១៤</u> ខែតុលា ឆ្នាំ២០១៥

ជ. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

---

[៤] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០១.ឧសណ.សរ/១៤

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ២២៣ ដល់ មាត្រា ២៣០ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តមិនទាន់បានល្អប្រសើរ។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមស៊ើបសួរ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-ត្រូវគិតអំពីវិធានការនៃការត្រួតពិនិត្យ និងឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។

ករណីនេះ ចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាមួយដែលមានសមត្ថកិច្ច អាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ គប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

៣-ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមួយច្បាប់ ឲ្យដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬគ្រប់បុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលជនត្រូវចោទត្រូវទៅរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ច ក្រៅពីជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

៤-ត្រូវណែនាំជនត្រូវចោទ ដែលត្រូវបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យយកដីកាសម្រេចនេះ ទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនត្រូវទៅរស់នៅ។

៥-ត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបទប្បញ្ញត្តិ នៃមាត្រា ២២៧-២២៨-២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ-ព្រះរាជអាជ្ញា**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ពិនិត្យឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការស្នើសុំដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-បន្ទាប់ពីទទួលបានដីកាបង្គាប់ ដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចាត់វិធានការដូចខាងក្រោម ៖

-ណែនាំជនត្រូវចោទអំពីរបៀបដែលត្រូវអនុវត្តកាតព្វកិច្ច ដូចបានកំណត់ក្នុងដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

-ណែនាំដល់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរឲ្យត្រួតពិនិត្យ តាមដាននិងធ្វើរបាយការណ៍តាមការកំណត់ ។

៣-ក្នុងករណីចៅក្រមស៊ើបសួរ បង្គាប់ឲ្យជនត្រូវចោទទៅបង្ហាញខ្លួន នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវបង្គាប់ទៅអង្គភាពនោះឲ្យចាត់វិធានការដូចខាងក្រោម ៖

-រៀបចំឲ្យមានសៀវភៅសម្រាប់ចុះវត្តមានជនត្រូវចោទ ដែលត្រូវមកបង្ហាញខ្លួនតាមការកំណត់របស់ចៅក្រមស៊ើបសួរ

-ចាត់ភ្នាក់ងាររបស់ខ្លួនឲ្យតាមឃ្លាំមើលសកម្មភាពរបស់ជនត្រូវចោទ ក្នុងការបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ជនត្រូវចោទ (វត្តមាន និងសកម្មភាព) ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ជូនទៅព្រះរាជអាជ្ញា។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០១៤

អង្គ វង្សវឌ្ឍានា

<u>ចម្លងជូន</u> ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

35

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

មន្ទីរស៊ើបសួរ ( ៣ )

លេខ 210 ដជ

# <u>ដីកាលើកលែងចោទប្រកាន់</u>

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ......៦៤...... អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ក្រឡាបញ្ជី

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤១ ដ.ជ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នលេខ៦៩៤,៦៩១,៦៩០(ព)ដឃដ ចុះថ្ងៃទី....១៨.... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស <u>អាយុ១៨ឆ្នាំ</u> ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការ: គ្មាន។

ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការ: គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦
ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

# ជំពូកទី ២
## គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

### មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណាពល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្ដល់ឱកាសឲ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្ដីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្ដល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្ដី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្ដុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែក្នុងករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

### មាត្រា ៥៩.- ការពន្លាតវិធានដល់តុលាការជាន់ខ្ពស់

វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់ ។

## ជំពូកទី ១០
## ការបង្វែរ

### មាត្រា ៦០.- ការបង្វែរ

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

### មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

### មាត្រា ៦២.- គោលបំណងនៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្ដីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៣.- លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។

គ- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

ឃ- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ ។

## មាត្រា ៦៤.- លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងករណីរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក- កាលៈទេសៈនៃបទល្មើស ។

ខ- ស្ថានភាពនៃបទល្មើស ។

គ- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង- ព្យសនកម្មរបស់ជនរងគ្រោះ ។

ច- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

## មាត្រា ៦៥.- វិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងថិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្ដីពីការងារ និងអនុសញ្ញាអន្តរជាតិស្ដីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

## មាត្រា ៦៦._ ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្ដល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្ដាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

## មាត្រា ៦៧._ និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ

ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- វិធានការបង្វែរណាមួយដូចមានចែងក្នុងមាត្រា ៦៥ (វិធានការបង្វែរ) នៃច្បាប់នេះ និងរយៈពេលនៃការអនុវត្តវិធានការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្ដល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការដែលផ្ដល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ ។

ផែនការបង្វែរត្រូវចុះ ៖

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលពាក់ព័ន្ធ ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។

## មាត្រា ៦៨.- ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

## មាត្រា ៦៩.- ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវជានាប់រងអនុវត្តសេចក្ដីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

## មាត្រា ៧០.- ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្ដែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។

អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## មាត្រា ៧១.- បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។

ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងបរិវេលា មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្វែរ) ដល់ មាត្រា ៧០ (ការកែប្រែវិធានការបង្វែរ)ខាងលើនេះ ត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរចេញដីកាបង្វែរថ្មី ។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## ការដោះលែងដោយមានលក្ខខណ្ឌ

### មាត្រា ៧២.- ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ។

### មាត្រា ៧៣.- បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស ។

## ជំពូកទី ១២
## ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

### មាត្រា ៧៤.- លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ពាក្យសុំអាចត្រូវធ្វើឡើងដោយ ៖

- ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន ។

### មាត្រា ៧៥.- ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល ៖

- ៣ (បី)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ១ (មួយ)ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី)ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

លើសុខភាពផ្លូវចិត្តរបស់កុមារ (១៤នាក់) និងសុខភាពរាងកាយ (១០នាក់) ។

"ពន្ធនាគារមិនមែនជាកន្លែងល្អសម្រាប់កុមារទេ ពីព្រោះពន្ធនាគារមិនអាចធ្វើឲ្យពួកគេបានស្វែងយល់ពីផលវិបាកនៃសកម្មភាពរបស់ពួកគេឡើយ។ ពួកគេនៅមិនទាន់គ្រប់អាយុ និងកំពុងតែស្ថិតក្នុងវ័យលូតលាស់នៅឡើយ។ វាពិបាកសម្រាប់ពួកគេក្នុងការមើលឃើញថា អ្វីខុសអ្វីត្រូវ...ពន្ធនាគារអាចបំផ្លាញដល់អនាគតរបស់កុមារ អាចធ្វើឲ្យពួកគេមានភាពអាម៉ាស់ក្នុងចំណោមមិត្តភក្តិ និងសហគមន៍របស់ពួកគេ ហើយក៏នឹងអាចធ្វើឲ្យពួកគេបាត់បង់ឱកាសទទួលបាននូវការអប់រំដ៏ត្រឹមត្រូវមួយផងដែរ"។

វាក៏សំខាន់ផងដែរក្នុងការកត់សម្គាល់ថា មានតែសមាជិកសហគមន៍១៥% ដែលបានស្នង់មតិប៉ុណ្ណោះ ដែលគិតថា កុមារអាយុ១៤ឆ្នាំត្រូវដាប់ពន្ធនាគារបើពួកគេបានប្រព្រឹត្តបទល្មើស (៥១% និយាយថាពួកគេមិនដឹងទេ ហើយ៣៤% គិតថា កុមារអាយុ១៤ឆ្នាំអាចបញ្ជូនទៅពន្ធនាគារបាន)។ ឆ្លើយនឹងសំនួរថា តើពួកគេគិតថាក្មេងៗត្រូវបានគេដាក់នៅក្នុងបរិវេណដូចគ្នានឹងមនុស្សពេញវ័យនៅក្នុងពន្ធនាគារខេត្តសៀមរាបដែរឬទេ? មានតែ៥% ប៉ុណ្ណោះបានឆ្លើយថា ពួកដឹងរឿងនេះ ហើយ៣១%ទៀតគិតថា កុមារមិនត្រូវបានឃុំជាមួយមនុស្សពេញវ័យទេ និង៦២% ទៀតបាននិយាយថាមិនដឹងទេ។

សហគមន៍ក៏ត្រូវបានសួរផងដែរថា តើពួកគេគិតថាពន្ធនាគារល្អសម្រាប់កុមារយ៉ាងដូចម្តេច?។ ចម្លើយនោះគឺ មានមនុស្ស២១នាក់បាននិយាយថា ពន្ធនាគារបានផ្តល់ឲ្យកុមារនូវការអប់រំ ហើយ២០នាក់គិតថា ពន្ធនាគារបានបង្រៀនពួកគេអំពីអ្វីត្រូវអ្វីខុស។ អ្នកផ្សេងទៀតបាននិយាយថា ពន្ធនាគារបានបង្រៀនកុមារកុំឲ្យប្រព្រឹត្តបទល្មើសទៀត (៩នាក់) អ្នកផ្សេងទៀតនិយាយថា ពន្ធនាគារជួយពួកគេឲ្យរួចផុតពីគ្រឿងញៀននិងគ្រឿងស្រវឹង (៨នាក់) ហើយអ្នកផ្សេងទៀតនិយាយថា ពន្ធនាគារធ្វើឲ្យពួកគេមានការទទួលខុសត្រូវថែមទៀត (៧នាក់) ។ អ្នកចូលរួម ៥១% គិតថា កុមារដែលត្រូវបានបញ្ជូនទៅពន្ធនាគារទំនងជាមិនងាយនឹងប្រព្រឹត្តបទល្មើសជាថ្មីទៀតទេ នាពេលអនាគត។

គួរកត់សម្គាល់ថា មានអ្នកឆ្លើយតប១៣%តែប៉ុណ្ណោះ ដែលគិតថា កុមារដែលប្រព្រឹត្តបទល្មើសអហិង្សា គួរតែត្រូវបានបញ្ជូនទៅពន្ធនាគារ (៧៥% បាននិយាយថា ពួកគេមិនគួរត្រូវបានបញ្ជូនទៅពន្ធនាគារទេ ហើយ១២%ទៀតបាននិយាយថា ពួកគេមិនដឹងទេ) ។

"ពន្ធនាគារ គឺមិនល្អនោះទេសម្រាប់កុមារ ពីព្រោះពួកគេអាចរៀនរឿងអាក្រក់ៗពីអ្នកដទៃដែលនៅក្នុងពន្ធនាគារ។ ពួកគេខកខានមិនបានទៅសាលារៀន ហើយបន្ទាប់ពីពួកគេត្រូវបានដោះលែង ពួកគេនឹងមានកំណត់ត្រាថ្កោលទោសដែលបង្កការលំបាកដល់ពួកគេក្នុងការស្វែងរកការងារធ្វើ ហើយម្យ៉ាងទៀតពួកគេនឹងត្រូវទទួលរងការរើសអើង ... ខ្ញុំគិតថាពួកគេនឹងប្រព្រឹត្តបទល្មើសម្តងទៀត"។

» ទិន្នន័យនេះ គាំទ្រលើអំណះអំណាងសម្រាប់ការអនុវត្តលើវិធានការបង្វែរជំនួសឲ្យការដាក់កុមារទំនាស់នឹងច្បាប់ទៅក្នុងពន្ធនាគារដែលអាចប៉ះប៉ូវលើផលប៉ះពាល់អវិជ្ជមានដែលមានរយៈពេលវែងនៃការដាក់ពន្ធនាគារ ចំពោះសុខភាព ទំនាក់ទំនង និង ឱកាស

# ឯកឧត្តមរដ្ឋមន្ត្រី វង សូត អញ្ជើញចុះពិនិត្យសមិទ្ធិផលចំនួន ៣ នៅឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

បណ្ណាល័យរូបភាព | ព័ត៌មានថ្មីៗ

ខែឧសភា 26, 2021 | ចំនួនទស្សនា៖ 178

ណ្តាលៈនាព្រឹកថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការអមដំណើរពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមានការអញ្ជើញចូលរួម ពីសំណាក់ ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល អញ្ជើញចុះពិនិត្យមើលនូវសមិទ្ធផលធំៗចំនួន ៣នៅក្នុងភូមិសាសស្រ្តឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

សមិទ្ធិផលទាំងនោះរួមមាន៖ ទី១.ការបង្កើតមណ្ឌលថែទាំ និងស្តារនីតិសម្បទា ជនវិបល្លាសស្មារតី ដែលបានបើកដំណើរការមួយរយៈមកនេះ ទី.២ មណ្ឌលយុវនីតិសម្បទា ដែលទើបបញ្ចប់ការសាងសង់ និងសមិទ្ធផលទី៣ គឺមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលកំពុងស្ថិតក្រោមការសាងសង់នៅឡើយ។

ដោយឡែកមណ្ឌលយុវនីតិសម្បទា ជាមណ្ឌលទី១នៅកម្ពុជាដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់យុត្តិធម៌អនីតិជន ដើម្បីផ្ទេរអនីតិជនល្មើសច្បាប់អាយុក្រោម ១៨ឆ្នាំ ចេញពីពន្ធនាគារមករស់នៅ ទទួលបានការបណ្តុះបណ្តាលជំនាញផ្សេងៗដាច់ដោយឡែកពីអ្នកល្មើសច្បាប់ដែលមានអាយុចាប់ពីអាយុ១៨ឆ្នាំឡើងទៅ។ តាមគម្រោងនៃការផ្ទេរអនីតិជនល្មើសច្បាប់មកទីតាំងមណ្ឌលយុវនីតិសម្បទានេះ គឺអាចចាប់ផ្តើមឡើងក្នុងកំឡុងខែមិថុនាខាងមុខ នេះជាការបញ្ជាក់របស់លោក ឌីន បូរីប្រធាននាយកដ្ឋានយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ លោកបន្តថាក្នុងដំណាក់ដំណាក់កាលដំបូងនេះ គឺគ្រោងដាក់ចំនួន ១០០ ទៅ២០០នាក់ ដើម្បីសាកល្បង។ ចំណែកលទ្ធភាពផ្ទាល់របស់មណ្ឌលទាំងមូល គឺអាចទទួលអនីតិជនល្មើសច្បាប់ចំនួនរហូតដល់ ២០០០នាក់។ លោកពន្យល់បន្ថែមថា ការផ្ទេរអនីតិជនមកទីតាំងមណ្ឌលនេះគឺមានរយៈពេលកំណត់ ក្នុងករណីអនីតិជនល្មើសច្បាប់ត្រូវបន្តទោសបន្ថែមទៀត គឺពួកគេនឹងត្រូវបញ្ជូនត្រឡប់ទៅពន្ធនាគារវិញ៕